សមាគមបុគ្គលិកសិក្សាខ្មែរ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

* ចំណងមិត្តភាពនិងការរួបរួមគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សម្ភារៈ

៤៣

# ទស្សនាវដ្តី គ្រូបង្រៀន



សាលាបឋមសិក្សាព្រះប្រឡាយ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

**ឧសភា ឆ្នាំ ២០១៤**

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ២១៦ ១៨៤_០១២ ៦៣៨ ៨៨៩
អ៊ីម៉ែល : kta.amcek@gmail.com

# មាតិកា

## គណៈកម្មការរៀបរៀង និង និពន្ធ

- លោក ជ័យ សម្បត្តា
- លោក ទោង ចូវ៉ាន់
- លោកស្រី គុយ វណ្ណា
- លោកស្រី គ្រាក់ សុធីតា
- លោក ជុំ ឈាងលី
- លោក ទៅ ជឿង
- លោក ស្វាយ ពិស្យ
- លោកស្រី អ៊ឹម មុន្នារី
- លោក ហ៊ុំ សោភិត
- លោកស្រី ចាន់ រីសាវ៉ែ
- លោក អ៊ឹម ជា
- សមាជិកសមាជិកា ស.ប.ស.ខ

## គណៈកម្មការត្រួតពិនិត្យ

- លោក យស់ ម៉េង
- លោកស្រី ចន់ សារ៉ុម
- លោក ម៉ិច វេរ
- លោក រ៉ុន ហួត
- លោក សុខ សារុណ
- លោក ស៊ិន ច័ន្ទថន
- លោក ស៊ិន ស៊ីម

## ការីកុំព្យូទ័រ

កញ្ញា ធឿងចាន់ធញ្ញី

## ក្របខាងក្រៅ

- ពីមុខ : សាលាបឋមសិក្សាព្រះប្រឡាយ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ
- ពីក្រោយ : ព្រែកឧកញ៉ាផ្លុង


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| | **ពុទ្ធកិច្ច** | |
| ២ | ច្បាប់ស្តីពីការអប់រំ (ត) | ២ |
| | **ចំណេះទូទៅ** | |
| ៣ | ចម្រៀងនិងប្រយោជន៍ (ត) | ៤ |
| ៤ | ប្រភពនៃការអប់រំក្នុងពិភពលោក (ត) | ៦ |
| | **ចិត្តវិទ្យាអប់រំ** | |
| ៥ | ការបណ្តុះចិត្តទៅជាសកម្មភាព (តចប់) | ៨ |
| ៦ | មាតាបិតាពុំមែនជាតុលាការ ពុំមែនជាថ្នាំគុក គឺជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា | ១០ |
| | **ការអប់រំ និង គរុកោសល្យ** | |
| ៧ | អភិវឌ្ឍចំណេះដឹងនិងបំណិន (ត) | ១២ |
| ៨ | វេយ្យាករណ៍: របៀបប្រើពាក្យ (ត) | ១៥ |
| ៩ | សាលារៀនជាមជ្ឈដ្ឋានផ្សាយនូវវិជ្ជាទូទៅ(ត) | ១៧ |
| ១០ | គណិតវិទ្យា: ស្រាវជ្រាវរកព័ត៌មានដែលខ្វះដើម្បីឆ្លើយនឹងសំណួរ | ១៩ |
| | **កំណាព្យ និង កំសាន្ត** | |
| ១១ | អ្នកបួស | ២២ |
| ១២ | ពលរដ្ឋល្អ សិស្សល្អ កូនល្អ មិត្តល្អ ក្មេងល្អ | ២៣ |
| ១៣ | សីលប្រាំងាយចាំមិនភ្លេច សីលប្រាំជានិច្ចអ្នកសាងកុសល | ២៤ |
| | **វេទិកាសេរី** | |
| ១៤ | ពុទ្ធសាសនា និង សង្គមខ្មែរ | ២៥ |
| ១៥ | ឋានានុក្រមបព្វជិតពុទ្ធសាសនាខ្មែរ | ២៧ |
| ១៦ | វេទិកាស្ត្រី: គោលនយោបាយស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ នៅកន្លែងធ្វើការ (តចប់) | ២៩ |
| | **ព័ត៌មាន** | |
| ១៧ | អំពីសតភព | ៣២ |
| ១៨ | ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១២ (ត) | ៣៣ |
| ១៩ | ស្ថិតិសពខែ ឧសភា-សីហា ឆ្នាំ ២០១៣ | ៣៩ |


## ទូរស័ព្ទផ្ទះគ្រូបង្រៀន

| | |
|---|---|
| ភ្នំពេញ | :០៨៩ ៦៨៤ ០៨១ |
| ព្រះសីហនុ | :០១២ ៦៥៩ ៥៦០ |
| សៀមរាប | :០១២ ៦៧៥ ៦៤០ |
| កំពង់ចាម | :០១១ ៧៤២ ២២៤ |
| ស្វាយរៀង | :០៩៧ ២៦៥៥ ៩៨៧ |
| ព្រៃវែង | :០១២ ៦៧១ ៦៤០ |
| កំពត | :០១២ ៨៥៦ ៧២២ |
| កែប | :០៩៧ ៨ ៧២១៨៨០ |
| តាកែវ | :០៩៧ ៩៧៦១ ៥៨៨ |
| អេងអីរ | :០៩៧ ៩០៤២ ៥៨៤ |
| ព្រះវិហារ | :០១២ ២១៨២៨១ |

# វិចារណកថា

នៅសតវត្សទី៣មុនគ.ស. ព្រះចៅអធិរាជនៃមហាប្រទេសឥណ្ឌា អាសោកា ព្រះអង្គបានគាំទ្រដោយសេចក្តីថ្លៃថ្នូរនូវឱវាទរបស់ព្រះពុទ្ធទាក់ទងនឹងអំពើនៃបញ្ញត្តិលើផ្ទាំងសិលាដែលមានខ្លឹមសារថា ៖

« គេមិនត្រូវលើកតម្កើងសាសនាខ្លួនឯង ហើយផ្តន្ទាសាសនាដទៃទៀតទេ ។ ប៉ុន្តែគេត្រូវលើកតម្កើងសាសនាដទៃទៀតក្នុងហេតុផលនេះ ឬហេតុផលនោះ ។ តាមរយៈអំពើនេះ គេអាចជួយសាសនាខ្លួនឯងកាន់តែ រីកធំធាត់ជាមួយគ្នានេះ គេក៏អាចជួយសាសនាដទៃឱ្យរីកចម្រើនដែរ ។ ផ្ទុយទៅវិញបើគេធ្វើតែអំពើអាក្រក់ផ្តេសផ្តាស មិនគប្បីចំពោះសាសនាដទៃនោះគេប្រាកដជាជីកផ្នូរកប់សាសនាខ្លួនឯងជាពុំខាន ។ នរណាម្នាក់ដែលគោរព លើក តម្កើងតែសាសនាខ្លួនឯងនិងផ្តន្ទាសាសនាដទៃដោយអះអាងថាគេមានភក្តីភាពចំពោះសាសនាខ្លួនឯង  អ្នកនោះ ប្រាកដជាពុំបានលើកតម្កើងសាសនាខ្លួនឯងទេ ។ ប៉ុន្តែបើគេធ្វើដូច្នេះគេប្រាកដជា បំផ្លាញយ៉ាងធ្ងន់ធ្ងរចំពោះ សាសនាខ្លួនឯង ។ »

ដូច្នេះការស្រុះស្រួលគ្នាគឺជាអ្វីដែលល្អ និងត្រឹមត្រូវ ទាំងអស់គ្នាគប្បីស្តាប់ និងពិចារណាពីឱវាទនៃសាសនាដទៃទៀតផងដែរ ។

យើងត្រូវខិតខំស្វែងយល់ មិនត្រឹមតែឱវាទប្រៀនប្រដៅរបស់សាសនាប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវស្វែងយល់ ឱវាទប្រៀនប្រដៅរបស់ប្រទេសជាតិ គឺច្បាប់ទាំងលើទិដ្ឋភាពនយោបាយ វប្បធម៌ សង្គម ទាំងលើទិដ្ឋភាពសេដ្ឋកិច្ចផងដែរ ។

ការអត់ឱន ការប្រោសប្រណី និងការយល់ដឹងត្រឹមត្រូវរបស់ព្រះពុទ្ធសាសនា ចាប់តាំងពីគ្រាដំបូងរហូតមក ដល់បច្ចុប្បន្ននេះ គឺជាឧត្តមគតិដ៏ថ្លៃថ្លានៃវប្បធម៌ និងអរិយធម៌ របស់សាសនានេះ ។ ហេតុដូច្នេះទើបគេមិនឃើញ មាន សូម្បីតែការធ្វើទុក្ខបុកម្នេញ ឬការបង្ហូរឈាមក្នុងន័យជំរុញប្រជាជនឱ្យជឿព្រះពុទ្ធសាសនាឬក៏ការឃោសនា ក្នុងរយៈពេលជាង ២៥០០ឆ្នាំកន្លងទៅនេះ។ សព្វថ្ងៃនេះទ្វីបអាស៊ីមានពុទ្ធសាសនិកប្រមាណជាង ៥០០លាន នាក់។

គេចោទជាសំណួរថា តើព្រះពុទ្ធសាសនាជាសាសនា ឬជាទស្សនវិជ្ជា ។តាមពិត គេចង់ថា អ្វីក៏បានដែរ ។ ព្រះពុទ្ធសាសនានៅតែជាព្រះពុទ្ធសាសនាដដែល ។ ស្លាកសញ្ញាព្រះពុទ្ធសាសនាដែលផ្សារភ្ជាប់នឹងការប្រៀនប្រដៅរបស់ព្រះពុទ្ធពុំមានអ្វីជាសំខាន់នោះទេ ។ ឈ្មោះដែលគេហៅថាព្រះពុទ្ធសាសនា មិនមានអ្វីជាសារវន្តទេ ប្រៀបបីដូចជាផ្កា ទោះបីកុលាបក្តី ម្លិះក្តី តែសារៈសំខាន់របស់វា គឺក្លិនក្រអូបដែលមានអត្ថន័យសារវន្តបំផុត ។

៧មករា ១៩៧៩ ប្រទេសជាតិបានរួចផុតពីរបបប្រល័យពូជសាសន៍ ។ ប្រជាជនបានរស់រានមានជីវិតឡើងវិញទន្ទឹមនឹងការកកើតព្រះពុទ្ធសាសនា ឥស្លាមសាសនា គ្រិស្តសាសនា ... ដែលសាសនិកទាំងអស់បាននឹងកំពុងរស់នៅជាមួយគ្នា ដោយសុខដុមរមនា ក្រោមគោលនយោបាយត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាអំពី ជំនឿសាសនា ៕

គណៈកម្មាធិការកណ្តាល

# ច្បាប់ស្តីពីការអប់រំ(ត)

បង្រៀនបន្ថែមនៅក្នុងកម្មវិធីសិក្សាធម្មតា ដែលមិនមែនតាមកម្មវិធីសិក្សាពិសេសដោយឡែកទេ

-អ្នកសិក្សាពិការដែលមិនមានលទ្ធភាពចូលសិក្សាជាមួយសិស្ស ឬ និស្សិតទូទៅបាន មានសិទ្ធិទទួលបានការអប់រំពិសេសនៅក្នុងថ្នាក់រៀនពិសេសដោយឡែក ។ អ្នកសិក្សាពិការទាំងនេះ អាចចូលសិក្សានៅសាលារៀនក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួនបាន ។

**មាត្រា ៤០.- សិទ្ធិស្នើ សិទ្ធិតវ៉ា សិទ្ធិប្តឹង និងសិទ្ធិទទួលបានដំណោះស្រាយ**

មាតាបិតា ឬ អ្នកអាណាព្យាបាល អ្នកសិក្សា និងបុគ្គលិកអប់រំដែលត្រូវបានគេបំពានសិទ្ធិដូចមានចែងក្នុងច្បាប់នេះមានសិទ្ធិស្នើ ឬ តវ៉ាទៅអាជ្ញាធរអប់រំមានសមត្ថកិច្ចតាមឋានានុក្រម ព្រមទាំងសិទ្ធិប្តឹងទៅតុលាការ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំត្រូវចេញលិខិតបទដ្ឋាន ស្តីពីនីតិវិធីនៃការស្នើ ឬការតវ៉ា និងនីតិវិធីនៃដំណោះស្រាយនេះ ។

**មាត្រា ៤១.- សិទ្ធិរបស់អ្នកសិក្សា និងបុគ្គលិកអប់រំក្នុងការត្រួតពិនិត្យសុខភាព**

អ្នកសិក្សា និងបុគ្គលិកអប់រំនៃគ្រឹះស្ថានសិក្សា ដែលមានអាជ្ញាប័ណ្ណអប់រំ មានសិទ្ធិទទួលបាននូវការពិនិត្យសុខភាព ។

គោលការណ៍ណែនាំសម្រាប់ការត្រួតពិនិត្យសុខភាពនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងទទួលបន្ទុកវិស័យអប់រំ និងក្រសួងទទួលបន្ទុកវិស័យសុខាភិបាល ។

**មាត្រា ៤២.- សិទ្ធិផ្សព្វផ្សាយ ឃោសនាព័ត៌មានអប់រំ**

គ្រប់ខ្លឹមសារផ្សព្វផ្សាយ ឃោសនា ព័ត៌មានអប់រំ ត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យអប់រំ ។ គ្រប់ការបន្លំបោកប្រាស់ទោះជាតាមរូបភាពណាក៏ដោយ ត្រូវហាមឃាត់ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំបទប្បញ្ញត្តិ និងគោលការណ៍ណែនាំស្តីពីការផ្សព្វផ្សាយ ឃោសនាព័ត៌មានអប់រំនេះ ។

**មាត្រា ៤៣.- សិទ្ធិទទួលបានព័ត៌មានអប់រំ**

ព័ត៌មានអប់រំនៃគ្រប់ស្ថាប័នអប់រំ គ្រឹះស្ថានសិក្សាជាព័ត៌មានសាធារណៈ លើកលែងតែព័ត៌មានដែលទាក់ទងនឹងរូបវន្តបុគ្គល ។ ស្ថាប័នអប់រំ គ្រឹះស្ថានសិក្សា ត្រូវផ្តល់ព័ត៌មានដោយលម្អិត ឱ្យទៅអ្នកដែលមានផលប្រយោជន៍តាមការស្នើសុំ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

បែបបទស្តីពីការផ្តល់ព័ត៌មានអប់រំ ត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យអប់រំ ។

## ជំពូកទី ៨
## ធនធានសម្រាប់ការអប់រំ

**មាត្រា ៤៤.- ការចូលរួម ការកៀរគរ និងការគ្រប់គ្រងធនធានសម្រាប់ការអប់រំ**

រដ្ឋត្រូវជំរុញ និងផ្តល់ការលើកទឹកចិត្ត ចំពោះសប្បុរសជន តាមភាពសមស្រប និងចាំបាច់ ដោយទទួលស្គាល់ការអប់រំជាការវិនិយោគមួយដ៏ល្អបំផុត ។

បុគ្គល បព្វជិត គ្រួសារ សហគមន៍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នរដ្ឋ និង ឯកជនទាំងអស់ មានសិទ្ធិចូលរួម និង ផ្តល់ធនធានយ៉ាងពេញលេញទាំងធនធានមនុស្សទាំងសម្ភារៈ ឬ ថវិកា ក្នុងគោលបំណងដើម្បីគាំទ្រនិងអភិវឌ្ឍវិស័យអប់រំ ។

អ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សា មានសិទ្ធិក្នុងការកៀរគរធនធានស្របច្បាប់នានាពីគ្រប់ប្រភព ដើម្បីអភិវឌ្ឍគ្រឹះស្ថានសិក្សា ។ ការផ្តល់ធនធានត្រូវធ្វើតាមការស្ម័គ្រចិត្ត និងឥតលក្ខខណ្ឌ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវធានាឲ្យតម្លាភាព និងការទទួលខុសត្រូវចំពោះការគ្រប់គ្រងប្រភពធនធាននៃការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការអប់រំ ។

**មាត្រា ៤៥.- ការចុះកិច្ចសន្យា និង ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ**

នីតិបុគ្គលសាធារណៈ នីតិបុគ្គលឯកជន និងរូបវន្តបុគ្គលមានសិទ្ធិចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀងជាមួយអ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ដើម្បីចូលរួមអភិវឌ្ឍវិស័យអប់រំ ។ រាល់កិច្ចសន្យា ឬ កិច្ចព្រមព្រៀងត្រូវធ្វើឡើងស្របតាមច្បាប់ និងត្រូវបម្រើផលប្រយោជន៍របស់គ្រឹះស្ថានសិក្សា ។

អ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រង និងការប្រើប្រាស់ធនធានទាំងអស់ ដើម្បីជាផលប្រយោជន៍ដល់គ្រឹះស្ថានសិក្សា ។

បែបបទ និងនីតិវិធីនៃការចុះកិច្ចសន្យា ឬ កិច្ចព្រមព្រៀងត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យអប់រំ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

(នៅមានត)




# ចម្រៀង និងសារប្រយោជន៍(ត)

**ទំនុកសម្ដែងបំណងល្អចំពោះកូន**

ទំនុកច្រៀងមួយបែប ជាសម្រែកឆន្ទៈរបស់ម្ដាយឪពុកដែលប៉ងឱ្យកូនស្រីរបស់ខ្លួនបានសម្រេចប្រយោជន៍ល្អ ក៏បណ្ដាលឱ្យច្រៀង មានខ្លឹមសារដើមថា:

សកវាទ៍ផ្កាកំពីងពួយ កូនស្រីតែមួយ
ទុកឱ្យចិនចៅ បង្គាប់ផ្ទះក្បឿង
គ្រឿងឈើស្រឡៅ ទុកឱ្យចិនចៅ
ធ្វើដង្វៅធំ។

**ទំនុកសម្ដែងចំពោះគូសង្សារ**

ទំនុកច្រៀងមួយបែប ជាសម្រែកឆន្ទៈរបស់បុរសអ្នកចង់បានស្ត្រីណាមួយដែលខ្លួនត្រូវចិត្ត ក៏បណ្ដាលឱ្យច្រៀង មានខ្លឹមសារដើមថា:

អាំអើយស្រីអាំ ព្រះពុទ្ធលោកផ្ដាំ
ថាឱ្យអាំដោយបង បងដាំពោធិ៍មួយ
ពុំទាន់បានឆ្លង ឱ្យអាំដោយបង
ឆ្លងពោធិ៍ពីរនាក់។

**ទំនុកសម្ដែងសំណួររបស់បុរស**

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តសម្ដែងរបស់បុរសអ្នកចង់បានស្ត្រីណាដែលខ្លួនស្រឡាញ់ក៏បណ្ដាលឱ្យច្រៀងជាពាក្យដណ្ដឹងសួរស្ត្រីនោះ មានខ្លឹមសារដើមថា:

ស្រីសទ្រលុក មុខមាត់ប្រិមប្រិយ
បើបងចូលស្តី ស្រីព្រមឬទេ ?

តាមការសង្កេតទំនុកច្រៀងសម្រាប់បុរសនិងសម្រាប់ស្ត្រីខ្មែរយើងសម័យបុរាណឃើញថាប្លែកគ្នាខាងបុរសច្រើនប្រើទំនុកសំដែងសេចក្ដីលួងលោមស្រី ដូចស្រង់ទំនុកខ្លះមកពោលហើយខាងលើ ចំណែកខាងស្ត្រីវិញច្រើនតែប្រើទំនុកសំដែងសេចក្ដីបន្ទុះបង្អាប់បុរសជាដរាបមានឧទាហរណ៍ ដូចស្រង់មកពោលដោយសង្ខេបទៅនេះ៖

**ទំនុកសម្ដែងសេចក្ដីបន្ទាប់**

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់ស្ត្រីដែលដឹងថាបុរសណាត្រូវការខ្លួន តែខ្លួនមិនត្រូវការនឹងបុរសនោះក៏បណ្ដាលឱ្យច្រៀងសម្ដែងសេចក្ដីបន្ទុះបង្អាប់ មានខ្លឹមសារដើមថា:

ប្រុសអើយ ប្រុសប្រាណ! ឃើញស្រីចង់បានមិនមើលមាឌ
គន់មើលទៅមុខដូចកញ្ជប់ជាតុ គន់មើលមារយាទដូចឆ្កែក្រោមផ្ទះ។

**ទំនុកសម្តែងសេចក្តីរិះគន់**

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរស ឬស្ត្រី ដែលប្រកបដោយសេចក្តីរិះគន់ មានខ្លឹមសារដើមថា:

- កញ្ចាញ់ចេកអើយ! លោតទំចុងក្តាត
  មេម៉ាយរាប់បាត្រ លោកគ្រូចង់សឹក ។
- បាសកទៅឃាត់ លោកគ្រូថាទេ
  ចង់បានកូនគេ នៅខាងជើងក្តី ។
- លោកគ្រូចង់សឹក ប្រញឹកខ្លាំងណាស់
  បួសយូរខ្លាចចាស់ ខានបានប្រពន្ធ ។
- ទ្រលុកៗអើយ! កុំធ្វើបាបលោក
  កំលោះគរគោក ទុកលោកធ្វើបុណ្យ ។

**ទំនុកសម្តែងសេចក្តីលោភជាការចំអក**

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសដែលពោលផ្តោះផ្តងនឹងស្រី ដោយសេចក្តីលោភ ជាការចំអក មានខ្លឹមសារដើមថា:

ស្រីអើយបងនឹក ស៊ីបាយស្រូបទឹក ប្រាំគោមកន្លះ
ប្រាំពីរឆ្នាំងដី ប្រាំបីឆ្នាំងខ្ទះ ប្រាំគោមកន្លះ
ស៊ីសោះរមូល ។

**ទំនុកសម្តែងសេចក្តីត្រេកត្រអាល**

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសដែលពោលផ្តោះផ្តងនឹងស្ត្រី ដោយតម្រេក មានខ្លឹមសារដើមថា:

ឱ! ម្លប់ដូងអើយ ! ដែលបងអង្គុយ បងអត់ងងុយ
ចាំស្រីវវៃ វវៃរួចហើយ បំពេញសណ្តង់
ទម្រាំខែត្រង់ នាំអូនចូលគេង ។

**ទំនុកសម្តែងសេចក្តីសរសើរ**

ទំនុកច្រៀងមួយបែប ជាទំនុកសម្តែងសេចក្តីសរសើរ និងប្រៀបធៀប ឱ្យអ្នកស្តាប់កើតគំនិតដល់ឋានៈទាបខ្ពស់របស់ខ្លួន ថាមិនមែនមានតែខ្លួនម្នាក់ឯងគ្រាន់ជាងគេទេ មានគេឯទៀតគ្រាន់បើដែរ មានខ្លឹមសារដើមថា:

អញថាភ្នំស្រួច ស្រួចអីតែឯង
មានភ្នំកម្រែង វែងហើយស្រួចផង ។

**ទំនុកសម្តែងបំណង និងជំនឿ**

ទំនុកច្រៀងមួយបែប ជាទំនុកសម្តែងបំណង និង ជំនឿក្នុងអំណោយទាន មានខ្លឹមសារដើមថា:

ឱ!សត្វមហោរី យំស៊ីផ្លែជ្រៃ ធ្វើបុណ្យទានអ្វី
ឱ្យជ្រៃផ្លែទៀត ជ្រៃផ្លែពីមុន ផ្លែចោលបង់សៀត
ឱ្យជ្រៃផ្លែទៀត ដាក់ទានសព្វសត្វ។ល។

ទាំងបទទាំងទំនុកច្រៀងមហោរី គួរចាត់ទុកជាចម្រៀងថ្នាក់ខ្ពស់មួយបែបរបស់ខ្មែរផតនរណាកែប្រែបាន ដែលតាម ភាសាបារាំងហៅថាចម្រៀងក្លាស៊ិចរបស់ខ្មែរ ។ (នៅមានត)

ដកស្រង់ដោយលោក **ចែមឆាន**

# ប្រវត្តិនៃការអប់រំក្នុងពិភពលោក (ត)

**៤.ការអប់រំ នៅប្រទេសអេហ្ស៊ីបបុរាណ**

អេហ្ស៊ីបបុរាណ ដែលជាប្រទេសមួយមានអរិយធម៌ដំបូងបង្អស់ក្នុងពិភពលោកនោះ បានអភិវឌ្ឍដូចជាប្រជាជនសម័យដើមផ្សេងទៀត ជាវប្បធម៌ជ្រលងភ្នំ និងទន្លេ។ ដោយសារតែទឹក ដែលកំពុងតែទ្រទ្រង់ដល់ជីវិតនៃទន្លេនីលនោះ ក្រុមកសិកម្មបានបង្កើតការតាំងទីលំនៅជាភូមិតូចៗ រៀបចំទៅជារាជាណាចក្រតាមកុលសម្ព័ន្ធ នៅតាមច្រាំងទន្លេ។នៅប្រហែលជា៣០០០ឆ្នាំមុនគ.ស. រាជាណាចក្រទាំងនោះបានពង្រីកខ្លួនឱ្យទៅជាចក្រភពដ៏ធំមួយដែលតាមពិតក្លាយទៅជាប្រទេសដែលជាមជ្ឈមណ្ឌលសក្ដានុពលខាងនយោបាយ និងការរៀបចំដ៏ខ្ពង់ខ្ពស់។

**លោកធាតុដែលមិនប្រែប្រួល**

គោលការណ៍នយោបាយ និងសាសនាអេហ្ស៊ីបដ៏សំខាន់ អះអាងថា ផារ៉ាអុង (Pharaon)ដែលជារាជាធិរាជ (Emperor) នោះមានប្រភពពីអាទិទេព។ បញ្ញត្តិនៃរាជាធិរាជភាពផ្ដល់នូវស្ថិរភាពខាងនយោបាយ អប់រំ វប្បធម៌ និងសង្គមទៅដល់ចក្រភពអេហ្ស៊ីបដោយផ្ដល់នូវមូលដ្ឋានគ្រឹះយល់ស្របតាមអភិធម្មជាតិ ។ ចំណេះដឹង និងតម្លៃត្រូវបានគេមើលឃើញថា ជាការឆ្លុះបញ្ចាំងលោកធាតុអនន្តមិនផ្លាស់ប្ដូរ និងមានរបៀបរៀបរយ ។ បញ្ញត្តិនៃបព្វជិតរាជាក៏ផ្ដល់ផងដែរនូវឋានៈយ៉ាងខ្ពស់នៃវីរជន ដែលជាបព្វជិត និងអំណាចដ៏ខ្លាំងនៅក្នុងអេហ្ស៊ីប ។ប្រព័ន្ធអប់រំពង្រឹងឋានៈ និងអំណាចដោយបង្កើតឆ្មាំវរជន ដែលជាបុព្វជិតនៃវប្បធម៌របស់រដ្ឋ។

**៤-១ ការយកចិត្តទុកដាក់ខាងសាសនា និងអាណាចក្រ**

ទាក់ទិននឹងការអប់រំជនជាតិអេហ្ស៊ីបមានទំនាក់ទំនងនឹងលោកីយ៍ និងមិនមែនលោកីយ៍ ។ ទោះបីជាមានអភិធម្មជាតិពីមុន ពួកគេក៏បានអភិវឌ្ឍបច្ចេកវិទ្យា ដើម្បីនាំទឹកទន្លេនីល និងរៀបចំស្ថាបនាប្រាសាទពីរ៉ាមីតដ៏ច្រើន។ដើម្បីគ្រប់គ្រងនិងការពារចក្រភពដ៏ធំទូលាយរបស់គេ ពួកគេបានសិក្សាជំនាញក្នុងការគ្រប់គ្រងរដ្ឋ (statecraft)និងការយកចិត្តទុកដាក់របស់ពួកគេ លើការរក្សាសពមិនឱ្យរលួយ (mummification)ដែលបាននាំឱ្យពួកគេសិក្សាវេជ្ជសាស្ត្រ កាយវិភាគវិទ្យា និងការអប់សព (embalming)។ ជនជាតិអេហ្ស៊ីប ក៏បានអភិវឌ្ឍផងដែរនូវប្រព័ន្ធនៃការសរសេរអក្សរ គឺអក្សររូប(hieroglyphic script)ដែលជួយឱ្យពួកគេបង្កើតនិងផ្ទេរវប្បធម៌ការសរសេរអក្សរ ។

*ក-សាលារៀនតាមព្រះវិហារ និង វាំង*

ចក្រភពអេហ្ស៊ីប ទាមទារឱ្យមានការិយាធិបតេយ្យដែលមានការអប់រំ ដើម្បីប្រមូល និងកត់ត្រាបន្ទុក ។ ត្រឹមឆ្នាំ ២៧០០ មុនគ.ស. ជនជាតិអេហ្ស៊ីបមានប្រព័ន្ធសាលារៀនតាមព្រះវិហារ និងវាំងយ៉ាងធំទូលាយ ។ មុខងារសាលារៀនមួយ គឺត្រូវបណ្ដុះបណ្ដាលមនុស្សឱ្យចេះបង្កើតការកត់ត្រា(scribes)ដែលភាគច្រើននៃពួកគេគឺជាបព្វជិតក្នុងការអាន និងសរសេរ។ សាលារៀនជាផ្នែកមួយនៃអាគារជាច្រើនផ្គុំគ្នានៅតាមព្រះវិហារ ដែលធ្វើឱ្យរីកចម្រើនដល់ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងការអប់រំក្នុងប្រព័ន្ធនិងសាសនា[1] ។ក្រោយពេលទទួលបានការអប់រំជាលើកដំបូងក្មេងប្រុសបានសិក្សាអក្សរសាស្ត្រ ដែលសមស្របទៅនឹងវិជ្ជាជីវៈនាពេលអនាគតរបស់ពួកគេ ។ សាលារៀនជាន់ខ្ពស់ពិសេសបានបង្កើតឡើងសម្រាប់បព្វជិតពិតប្រាកដ មន្ត្រីរដ្ឋាភិបាលនិងគ្រូពេទ្យ ។

*ខ-ការអប់រំមនុស្សឱ្យចេះកត់ត្រា*

នៅក្នុងសាលារៀនដែលបង្ហាត់មនុស្សឱ្យចេះកត់ត្រាសិស្សរៀនសរសេរអក្សររូបតាមការចម្លងឯកសារនៅលើក្រដាសម្យ៉ាង ដែលផលិតចេញពីដើមត្រែងឬបបុសដែលដុះនៅតាមដងទន្លេនីល ។ គ្រូហៅឱ្យសិស្សកត់ត្រានូវអ្វីដែលគេ

[1] James Mulhem, A History of Education, A Sosial Interpretation (New York: Ronald Press, 1959 ),pp.55-79

បានឮ។ គោលដៅគឺត្រូវបង្កើតឡើងវិញនូវការកត់ត្រាអត្ថបទឱ្យបានត្រឹមត្រូវដូចដើម។ ជាញឹកញាប់សិស្សស្រែកសូរដដែលៗនូវអត្ថបទខ្លីៗ រហូតដល់គេចាំបានច្បាស់លាស់ ។អ្នកទាំងឡាយដែលបានរៀនពូកែត្រូវបានសិក្សាគណិតវិទ្យា តារាសាស្ត្រ សាសនា កំណាព្យ អក្សរសិល្ប៍ វេជ្ជសាស្ត្រ និងស្ថាបត្យកម្ម ។

**៤-២ វិវាទជាប្រវត្តិសាស្ត្ររបស់អេហ្ស៊ីប**

ក-ការបកស្រាយតាមប្រពៃណី

តួនាទីអេហ្ស៊ីបបុរាណក្នុងការបង្កើតអរិយធម៌លោកខាងលិច បានក្លាយទៅជាវិវាទ ។ នៅឆ្នាំ៣៣២មុនគ.ស. ប្រទេសអេហ្ស៊ីបត្រូវបានចូលលុកលុយដោយមហារាជអាឡិចសង់ (Alexander the Great)និងបានបង្កើតជាអរិយធម៌ហេលែន (Hellenistic) ដែលត្រូវបានបង្កើតដោយវប្បធម៌ក្រិចបុរាណ។ ការបកស្រាយប្រវត្តិសាស្ត្រដោយសន្មត គឺថា អរិយធម៌អេហ្ស៊ីបបុរាណ ជាការកាន់អំណាចផ្ដាច់ការដ៏យូរ ហើយកេរដំណែលវប្បធម៌ចម្បង គឺមានស្ថាបត្យកម្មដ៏ធំធេងរបស់ខ្លួន ។ ការបកស្រាយនេះបានបង្ហាញឱ្យឃើញវប្បធម៌របស់ក្រិច ជាពិសេសប្រជាធិបតេយ្យក្រុងអាថែន ជាទីកន្លែងចាប់កំណើតនៃអរិយធម៌លោកខាងលិច ។

ខ.ទ្រឹស្ដីរបស់ប៊ឺណាល (Bernal'sTheory)

ការបកស្រាយប្រកបដោយវិវាទជាខ្លាំងដោយប៊ឺណាល(Martin Bernal)[2]អះអាងថា ជនជាតិក្រិចបានខ្ចីបញ្ញត្តិជាច្រើនអំពីរដ្ឋាភិបាល ទស្សនវិជ្ជា សិល្បៈ និងវិទ្យាសាស្ត្រពីអេហ្ស៊ីបបុរាណ ។ លើសពីនេះទៀត ជនជាតិអេហ្ស៊ីបមានទីតាំងភូមិសាស្ត្រ នៅអាព្រិចខាងជើង គឺជាជនជាតិអាព្រិច និងជាប្រភពវប្បធម៌លោកខាងលិច គឺជាជនជាតិអាព្រិចនេះឯង ។ ថ្វីបើគេបានទទួលស្គាល់អន្តរកម្មរវាងជនជាតិអេហ្ស៊ីបនិងក្រិច ការរិះគន់របស់ប៊ឺណាល(Bernal) អះអាងការសង្កត់យ៉ាងធ្ងន់នៃឥទ្ធិពលរបស់អេហ្ស៊ីប ទៅលើក្រិចបុរាណ។ នៅពេលដែលប្រវត្តិវិទូបន្តពិភាក្សាបញ្ហានេះរបកគំហើញដែលគ្រាន់តែជាការស្មានស្មង់នោះ ចង្អុលបង្ហាញថា ទំនាក់ទំនងអេហ្ស៊ីប-ក្រិច ជាពិសេសនៅកោះក្រែត(Crete)នាំយកមកប្រើប្រាស់ដោយជនជាតិក្រិច ទៅជាចំណេះដឹងជនជាតិអេហ្ស៊ីប ដូចជា គណិតវិទ្យា ហើយនិងទម្រង់សិល្បៈអេហ្ស៊ីប។

គ.អតីតកាលជាប្រភពនៃអំណាច

វិវាទប្រវត្តិសាស្ត្រដែលគួរឱ្យចង់ដឹង មានខ្លឹមសារជាមនោគមវិជ្ជាដ៏សំខាន់ អ្នកណាក៏ដោយដែលបានបកស្រាយពីអតីតកាល ទទួលបានឥទ្ធិពលនៃការបំភ្លឺឱ្យច្បាស់លាស់ និងបង្កើតរូបរាងដល់បច្ចុប្បន្ន។ ក្នុងករណីពិសេសវិវាទមានទំនាក់ទំនងដល់ការពិភាក្សានាពេលបច្ចុប្បន្ន អំពីមជ្ឈមណ្ឌលអាព្រិចនិយម និងកម្មវិធីសិក្សាពីទ្វីបអាព្រិចនៅសាលារៀនទាំងឡាយ។ នៅផ្នែកបន្ទាប់មកទៀត យើងត្រឡប់ទៅមើលជនជាតិក្រិចបុរាណ ថាតើទទួលបានឥទ្ធិពលដោយផ្ទាល់ ឬមិនផ្ទាល់ ដោយជនជាតិអេហ្ស៊ីប ជនជាតិក្រិចបន្តការរក្សាទីកន្លែងដ៏សំខាន់ក្នុងប្រវត្តិនៃការអប់រំ។យ៉ាងណាក៏ដោយ ចូររក្សាក្នុងចិត្តថា វប្បធម៌ជាប្រវត្តិភាគច្រើនបំផុត បានខ្ចីពីគ្នាទៅវិញទៅមក តាមរបៀបជាច្រើនបែបហើយដើមកំណើតនៃគំនិតជនជាតិក្រិច អាចត្រូវបានរកឃើញនៅអេហ្ស៊ីប ឬកន្លែងផ្សេងទៀត ។

(នៅមានត)

(បកប្រែពីសៀវភៅ Foundations of Education-Allan C. Orstein et al 1996 - USA)

**អនុបណ្ឌិតសូសុធីរ**

---

[2]Martin Bernal, Black Athena: The Afroasiatic Roots of Classical Civilization: The Fabrication of Ancient Greece 1785 -1985 (New Brunswick, N. J.,: Rutgers University Press,1987 ),pp.2-3



# ចិត្តវិទ្យាអប់រំ

## ការបណ្ដុះចិត្តទៅជាសកម្មភាព (តចប់)

II. សកម្មភាព និង សកម្មភាពចម្បង

១. លំនាំនៃការបណ្ដុះបណ្ដាលនិងការអភិវឌ្ឍបាតុភូតចិត្ត និងបុគ្គលិកលក្ខណៈរបស់សិស្ស គឺលំនាំទទួលយកបទពិសោធសង្គមប្រវត្តិ ហើយបំប្លែងទៅជាសម្បត្តិផ្ទាល់ខ្លួន។

ឧទាហរណ៍ ៖ អ្នករៀនគូរដំបូងសិក្សាពីគ្រូ នៅពេលដែលគេចេះគូរហើយគេអាចគូរដោយខ្លួនឯង « ចំណេះដឹងផ្ទាល់ខ្លួន »។ លំនាំនេះប្រព្រឹត្តទៅក្នុងទំនាក់ទំនងមនុស្សនិងមនុស្ស មនុស្សនិងធម្មជាតិ មនុស្សនិងសង្គមរវាងមនុស្សជំនាន់មុន និងមនុស្សជំនាន់ក្រោយ មនុស្សនិងខ្លួនឯង «**ឥរិយាបថរបស់មនុស្ស** » ។

ក្នុងទំនាក់ទំនងនេះ ទំនាក់ទំនងរវាងគ្រូ និងសិស្សមានសារៈសំខាន់ជាងគេ ។

ទម្រង់សកម្មភាពរបស់សិស្ស មានចរិតលក្ខណៈដូចតទៅ

- គ្រប់សកម្មភាពទាំងអស់តម្រង់ឆ្ពោះទៅរកគោលដៅមួយជានិច្ច « វត្ថុ ឬ បាតុភូត បញ្ញត្តិ ទំនាក់ទំនង ... ដើម្បី បំពេញតម្រូវការផ្នែកសម្ភារៈស្មារតីរបស់ខ្លួននិងសង្គម » ។

- សកម្មភាពនីមួយៗ នឹងបានទៅដល់គោលដៅមួយជាក់លាក់ ។
- រចនាសម្ព័ន្ធរបស់សកម្មភាពនីមួយៗមាន៖
  - សកម្មភាពនីមួយៗ ត្រូវបានបង្កើតឡើងដោយអំពើច្រើនហើយអំពើត្រូវបានកំណត់ដោយចលនា។

ឧទាហរណ៍ ៖ សកម្មភាពបង្រៀនមានអំពើច្រើនដូចជា រៀបចំមេរៀន(កិច្ចតែងការបង្រៀន) ពន្យល់មេរៀន កែកិច្ចការត្រួតពិនិត្យ និងវាយតម្លៃសិស្ស ...។

- បង្រៀនមេរៀនមួយ គឺមានចលនាច្រើនដូចជា សរសេរ លុបក្ដារខៀន សង្កេតសិស្ស ដឹកនាំសិស្ស ។

២. ដំណាក់វ័យនីមួយៗ មានសកម្មភាពចម្បងមួយ ។ គឺជាសកម្មភាពមួយដែលមនុស្សត្រូវប្រើពេលវេលាច្រើនដើម្បីសម្រេច និងបង្កើតលក្ខណៈចិត្តថ្មីៗទៀត។

ឧទាហរណ៍៖ នៅមត្តេយ្យសិក្សា ល្បែងជាសកម្មភាពចម្បងរបស់កុមារ ។ នៅបឋមសិក្សាសកម្មភាពសិក្សា ជាសកម្មភាពចម្បងរបស់កុមារដោយហេតុថា នៅចុងដំណាក់នេះ «ចប់ថ្នាក់ទី ៤ » កុមារអាចចាប់ចេះគិតហើយ ។ នៅវ័យជំទង់ទំនាក់ទំនងក្លាយជាសកម្មភាពចម្បងមួយក្នុងចំណោមសកម្មភាពចម្បងទាំងឡាយដែលជំទង់ត្រូវរៀបចំខ្លួនឆ្លងចូលដល់យុវវ័យ ។

និយាយរួម រាល់សកម្មភាពប្រចាំថ្ងៃត្រូវបានបំប្លែងជាមូលដ្ឋាននៃបាតុភូតចិត្តរបស់ក្មេង នៅដំណាក់នៃការអភិវឌ្ឍនីមួយៗ ។

III. ទម្រង់សកម្មភាពរបស់សិស្សនៅមធ្យមសិក្សា

ជំទង់មានសកម្មភាពច្រើនដូចជា:

- សកម្មភាពសិក្សា
- សកម្មភាពពលកម្ម
- សកម្មភាពល្បែង។

ក្នុងនោះសកម្មភាពសិក្សា និងទំនាក់ទំនងជាសកម្មភាពចម្បង។

១. សកម្មភាពសិក្សា

ក្នុងសាលាចំណេះទូទៅ សកម្មភាពទាំងអស់ តម្រង់ឆ្ពោះទៅរកគោលបំណងជាក់លាក់មួយ គឺផ្ដល់ឱ្យមនុស្សជំនាន់ក្រោយនូវសមត្ថភាព ក្នុងការទទួលយកបទពិសោធសង្គមប្រវត្តិនៃមនុស្សជាតិ។ ចំណេះដឹង ជាលទ្ធផលចុងក្រោយនៃការសិក្សា ។

ក្នុងការសិក្សាគេត្រូវប្រើលំនាំចិត្តជាច្រើនដូចជា ឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ បម្រុងប្រយ័ត្ន រូបារម្មណ៍ការគិត និងភាសា ... ដែលជាលក្ខខណ្ឌចាំបាច់ដើម្បីទទួលយកចំណេះដឹង ។

ចំណេះដឹងត្រូវលេចឡើងដោយសារការគិតពិចារណារបស់មនុស្ស ក្នុងការគិតពីតថភាពបរានុម័ត ក្រោមទម្រង់ផ្សេងៗ ដែលប្រកបដោយចរិតលក្ខណៈសម្បូរបែប ។

ជាទូទៅចំណេះដឹងមានរចនាសម្ព័ន្ធដូចតទៅ ៖

- រូបភាពនៃបាតុភូតដែលគេសិក្សា
- បញ្ញត្តិ
- សម្បទា និងការប៉ិនប្រសប់
- ការពង្រឹងចំណេះដឹង
- ការសិក្សា និងការរីកចម្រើននៃបញ្ញា។

២. សកម្មភាពទំនាក់ទំនង

នៅដំណាក់វ័យជំទង់ ជានិច្ចកាលជំទង់ចូលចិត្តធ្វើសកម្មភាព។ ទំនាក់ទំនងជាមួយមិត្តភក្តិមានសារៈសំខាន់ណាស់ចំពោះជំទង់ ។ គឺចាប់ផ្ដើមចេញពីសកម្មភាពនេះហើយ ដែលជំទង់ក្ដាប់បាននូវខ្លឹមសារនៃជីវិតពិតប្រាកដ លក្ខ-ន្តិកៈ លក្ខណវិនិច្ឆ័យរបស់សង្គម ចំណេះដឹង ច្បាប់សង្គមសុជីវធម៌ ...។

សកម្មភាពដទៃទៀត ក៏ត្រូវបានផ្សារភ្ជាប់ជាមួយនឹងទំនាក់ទំនងនោះដែរ ។ សកម្មភាពទំនាក់ទំនង ក្លាយទៅជាកម្លាំងចលករយ៉ាងសំខាន់ ព្រមទាំងគ្របដណ្ដប់កម្លាំងដទៃទៀត ។

៣. សកម្មភាពពលកម្ម

សកម្មភាពពលកម្មគឺផ្ដល់ចំណេះដឹង និងសម្បទាជាមូលដ្ឋានចាំបាច់ដល់សិស្ស។ សកម្មភាពពលកម្ម គឺជាទម្រង់មួយនៃសកម្មភាពសិក្សា ។

ម្យ៉ាងទៀត សកម្មភាពពលកម្ម គឺជាទម្រង់នៃសកម្មភាពសិក្សា ។ សកម្មភាពពលកម្មសម្ដែងឡើងតាមរូបភាពច្រើនដូចជាសកម្មភាពសង្គម ការចូលរួមក្នុងចលនាយុវជន។

៤. សកម្មភាពល្បែង

ជំទង់ចាប់ផ្ដើមហាត់លេងកីឡានិងហាត់ប្រាណ ។ ក្រៅពីនេះ ជំទង់ចូលរួមក្នុងការសម្ដែងសិល្បៈ កម្មវិធីដើរកំសាន្ត ការចូលទៅទស្សនានូវសិល្បៈនានា ឬការអាននូវអត្ថបទកំសាន្ត ...។

**ឯកសារនាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ**

# មាតាបិតា ពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុកតែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា

**សេចក្ដីផ្ដើម**

មនុស្សសត្វក្តី កាលបើបានទៅជាមាតាបិតា ឬមេបាហើយនោះ គឺមានអត្ថន័យ និងភារកិច្ចដូចៗគ្នា ។ នៅពេលនោះអ្នកជាអ្នកគ្រប់គ្រងដ៏កំពូលក្នុងជីវិតរបស់អ្នក និងក្រុមគ្រួសារផ្ទាល់ ។ អ្នកនឹងមានកិច្ចការរាប់មិនអស់ ជាកាតព្វកិច្ចសម្រាប់ទ្រទ្រង់សមាជិករបស់ខ្លួន ។ ក្នុងនោះកិច្ចការអប់រំ ជាកាតព្វកិច្ចគ្រឹះ ។ រាល់អំពើទាំងឡាយដែលកំពុងសកម្មទាំងផ្លូវកាយ វាចា ចិត្ត ជាសកម្មភាពអប់រំយ៉ាងជាក់ប្រាកដណាស់ ។

ពីព្រោះអ្វី? តើអ្នកមានបានគិត ឬសង្កេតឃើញថា សកម្មភាពអប់រំ របស់អ្នកទៅលើបុត្រធីតា មានលទ្ធផលយ៉ាងណា? អ្វីខ្លះវិជ្ជមាន? អ្វីខ្លះអវិជ្ជមាន? តើសេចក្ដីប្រាថ្នានៅក្នុងជម្រៅដួងចិត្តគំនិតរបស់អ្នកពិតជាទទួលបានផលវិជ្ជមានជាមួយនឹងសកម្មភាពបង្ហាញចេញរបស់អ្នកដែរឬទេ? តើនរណាម្នាក់ដែលមិនប្រាថ្នាចង់បានឱ្យបុត្រធីតាប្រកបដោយគន្លងធម៌ និងឧត្តុង្គឧត្តម ? តើធ្វើដូចម្ដេចទៅ ?

**ពាក្យគន្លឹះ**

ដំបូងយើងគួរសិក្សាស្វែងយល់នូវពាក្យអប់រំ និងគ្រួសារមាតាបិតា បុត្រធីតា ។

អប់រំ (កិ) អប់បង្អប់ផ្សែង ឬបង្អប់ចំហាយ ។ ពាក្យប្រៀប ហាត់ចិត្ត បង្វឹកចិត្ត ជួសជុលចំពោះវិជ្ជាឬកិរិយាមារយាទហ្វឹកហាត់ឱ្យស្ទាត់ជំនាញជាងមុន កែឱ្យបានល្អជាលំដាប់ ខំប្រឹងបំពេញឧបនិស្ស័យឱ្យបរិបូណ៌ ខំកសាងសន្សំបុណ្យកុសល រក្សាទុកពុំឱ្យមានហ្មង មិនឱ្យមានថ្នាំងថ្នាក់ (វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ**ជួន ណាត**)។

គ្រួសារ(ន) ត្រកូល ឬប្រជុំត្រកូលមនុស្ស គឺមាតាបិតា បុត្រា បុត្រី (វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត**)។

បុត្រធីតា (ន) បុត្រា និង បុត្រី ឬ កូនប្រុស កូនស្រី ។

អប់រំ ជាពាក្យពីរមាត់ ងាយនឹងអានណាស់ តែន័យរបស់វាស្មើនឹងទំហំ នៃជីវិតរបស់យើងម្នាក់ៗ ។ ពីព្រោះការអប់រំ ជាប់ជំពាក់ស្អិតល្មួតទៅនឹងសកម្មភាពរបស់មនុស្ស សត្វ ដែលកំពុងប្រព្រឹត្តទៅ។ សកម្មភាពអប់រំ ស្ដែងចេញពីទង្វើពីរយ៉ាងគឺ

១. ពាក្យសម្ដី ២. កាយវិការ

ពាក្យសម្ដីបានមកពីពាក្យ និងសម្ដី មែនឬ ?

ពាក្យ មានប្រើប្រាស់ក្នុងការនិយាយផង និងក្នុងការសរសេរផង ។ ចំពោះពាក្យ ទោះឋិតក្នុងការនិយាយ ឬ សរសេរក្តី គឺជាកន្សោមន័យមួយកញ្ចប់មានខ្លឹមសារជាក់ប្រាកដ។ រីឯសម្ដី វាជាសូរនៃភាសាតែប៉ុណ្ណោះ នឹងអាចពុំមានន័យពេញលេញនិងមានទម្ងន់ន័យទៅតាមសូរសព្ទ (ធូន់ ស្រាល...)។ ពាក្យ និងសម្ដីនេះធ្វើប្រតិបត្តិការក្នុងពេលតែមួយជាប់ជាមួយគ្នា នៅពេលដែលអ្នកនិយាយ គេហៅថាពាក្យសម្ដី ឬសម្ដី ។

ពាក្យ (ន) ភាសា សម្ដី ប្រយោគសម្ដី .............(វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ**ជួន ណាត**)។

សម្ដី(ន)ពាក្យដែលស្ដី ដែលនិយាយ ភាសា..........(វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ**ជួន ណាត** ។

ពាក្យសម្ដីដែលបាននិយាយមានសូរសំឡេង តាមខ្លឹមសារ ឬតាមអត្ថន័យនៃពាក្យ ។ ជួនកាលអ្នកស្ដាប់សម្ដីន័យពាក្យរបស់គេមិនបាន តែសូរសំឡេងធ្វើឱ្យអ្នកកាត់យល់បាន គេច្រឡោតខឹង ឬគេមានភាពស្និទ្ធស្នាលរួសរាយ ។

ពាក្យសម្ដីដែលបាននិយាយចេញមក តើមានសូរសំឡេងតាមខ្លឹមសារន័យនៃពាក្យដែរឬទេ ? ចម្លើយ ឋិតនៅលើលោកអ្នក សាកល្បងដោយខ្លួនឯង នៅពេលនេះតែម្ដង ឧទាហរណ៍ បាទ! ចាស ! ម៉ែ! កូន!(បែបស្រទន់ និង បែបគំរោះគំរើយ)។

## ១. ពាក្យសម្ដីក្នុងការអប់រំកូន

### ១.១. អំពីសូរសំឡេង

- សូរសំឡេងអាចនឹងមានច្រើនយ៉ាង ច្រើនបែបបទ តាមការកត់សម្គាល់ក្នុងការប្រើនៅក្នុងគ្រួសារ អាចមានសូរបែបស្រទន់ និងមិនស្រទន់ តិច ខ្លាំង តឹង (តឹងសរសៃក)គ្រលរ ធ្នារ (ញ៉ៅ)ក្រអួន ក្រអៅ .......។ ល ។

ដើម្បីជាផលប្រយោជន៍ពិតប្រាកដ ក្នុងការធ្វើសកម្មភាពអប់រំបុត្រធីតាតើយើងគួរគប្បី ស្គាល់ យល់ និងធ្វើអ្វីខ្លះតាមរយៈសូរសំឡេងនេះ ។

- តើបានសង្កេតច្បាស់លាស់ពីទុក្ខកង្វល់របស់ខ្លួន ចំពោះការគ្រប់គ្រងបុត្រធីតាហើយឬនៅ ?

ការអប់រំ គឺជាមូលដ្ឋានគ្រឹះមួយក្នុងការគ្រប់គ្រងបុត្រធីតា ។ នេះជាទុក្ខកង្វល់មួយរបស់យើងជាមាតាបិតាដែលត្រូវមានការរិះគិតនិងកត់សម្គាល់យ៉ាងជាក់លាក់ ។

- តើគួរគប្បីស្វែងយល់ដឹងអំពីចរិតលក្ខណៈរបស់បុត្រធីតាជាមុនដែរឬទេ?

ក្នុងដំណើរការអប់រំ ចាំបាច់ត្រូវតែស្គាល់ច្បាស់អំពីចរិតលក្ខណៈ និងស្គាល់សមត្ថភាពរបស់បុត្រធីតា។ចំពោះចរិតលក្ខណៈរបស់បុត្រធីតាគ្រប់រូបមិនដូចគ្នាឡើយ សូម្បីកូនភ្លោះក៏ខុសគ្នាដែរ ។ លោកអ្នកនេះហើយដែលត្រូវស្គាល់ច្បាស់ចរិតលក្ខណៈ និងស្គាល់សមត្ថភាពរបស់បុត្រធីតាពីព្រោះ នៅជិតដិតបំផុតជាមួយពួកគេ ។

ក្នុងទង្វើពាក្យសម្ដីមានឥទ្ធិពលសំខាន់ក្នុងការអប់រំបុត្រធីតា មិនគប្បីយល់រំលងបានឡើយ។

- តើអ្នកមានបានគិតថាពាក្យសម្ដីណា (គំរាមកំហែង គំហក ឬ ភាពស្និទ្ធស្នាល ផ្អែមល្ហែម ) ដែលអ្នកធ្លាប់បានទទួលរង និងគិតថា កក់ក្ដៅ ឬក៏ភ័យខ្លាច ឬមមិងមមាំង ? តើយើងគួរគប្បីប្រើពាក្យសម្ដី និងសូរសំឡេងយ៉ាងណាចំពោះបុត្រធីតារបស់យើង?

ឥឡូវនេះ ចូរយើងសាកល្បងវិភាគ និងជ្រើសរើសវិធីសាស្ត្រក្នុងការនិយាយជាមួយកូន។

- សូមគិតថារាល់ការនិយាយស្ដីជាមួយកូន គឺសុទ្ធតែផ្សារភ្ជាប់អត្ថន័យអប់រំទាំងអស់ ។

- ការសើច ការញញឹម និងការនិយាយរាប់រកគ្នា តើមានន័យអប់រំមែនឬ ?

- តើអ្នកបានសង្កេតឃើញថា ពាក្យសម្ដីផ្អែមល្ហែម ដោយបង្ហាញហេតុផលច្បាស់លាស់ក្នុងការនិយាយអប់រំកូនទទួលបានលទ្ធផលយ៉ាងណាខ្លះ ? (ផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាន)។

- តើអ្នកមានដែលគំហកកំហែងកូនដែរឬទេ? ឬក៏គួរប្រើពាក្យកំហែងយ៉ាងអសុរោះ នៅពេលដែលអ្នកខឹងនឹងបុត្រធីតា? ក្រោយមកអ្នកដែលបានសង្កេតឃើញថា អ្នកបានទទួលផលយ៉ាងណាខ្លះ?(សាកល្បងគិត ឬរំលឹក) គេស្អប់ គេខឹង គេប្រមាថ មែនឬទេ ? តើអ្នកពេញចិត្ត ឬក៏ភ័យរន្ធត់? អ្វីខ្លះដែលអ្នកទទួលយកពុំបាន ជូរចត់ ងងឹតសូន្យ គួរផ្ទេរទង្វើនេះទៅកូនដែរឬទេ?

គេវាយដំអ្នកគ្មានត្រាប្រណី គេជេរប្រទេចផ្ដាសា គេគ្មានសន្តិភាពចំពោះអ្នក គេមិនបង្ហាញ មិនពន្យល់ពីហេតុផល គេចាប់បង្ខំឱ្យទទួលនូវអ្វីដែលពុំមែនជាការពិតរបស់យើង តើយើងទទួលយកនូវភាពកក់ក្ដៅដែរឬទេ?

ប្រសិនបើយើងយល់ថាទេ តើយើងគួរជៀសវាងការប្រព្រឹត្ត ឬផ្ទេរហេតុផលនេះ ទៅឱ្យកូនជាទីស្រឡាញ់បំផុតរបស់យើងដែរឬទេ?

គ្មាននរណាម្នាក់ចង់ឱ្យហេតុផលអាក្រក់ធ្លាក់ទៅលើបុត្រធីតានោះឡើយ ។ សូម្បីមេមាន់រស់តាមសភាវគតិក៏វាការពារកូនរបស់វានៅពេលមានអាសន្ន ឬសត្រូវមកបៀតបៀនដែរ ។

(នៅមានត)

**លោក ផេង កែន**




# អភិវឌ្ឍចំណេះដឹង និងបំណិន(ត)

**២. បំណិន** (skills)

ចំណេះដឹងតែមួយមុខមិនគ្រប់គ្រាន់សម្រាប់ឱ្យក្លាយជាអ្នកដឹកនាំពូកែបានទេ។ ទន្ទឹមនឹងចំណេះដឹង យើងត្រូវមានបំណិន ទាំងនោះអាចចែកជាពីរផ្នែកគឺ បំណិនវិជ្ជាជីវៈ(Professional skills) និងបំណិនទំនាក់ទំនង (Inter personal skills)។

**២.១. បំណិនវិជ្ជាជីវៈ**( Professional skills)

ដូចយើងបាននិយាយខាងដើម ដឹកនាំខុសពីគ្រប់គ្រង។ ដឹកនាំគឺមានប្រឌិតញាណ ដឹកនាំគឺលើកកម្ពស់ការប្រែប្រួលតាមបែបច្នៃប្រឌិត ដឹកនាំគឺគិតគ្រប់ជ្រុងជ្រោយ... ។ ដើម្បីសម្រេចបាននូវទិសដៅនេះ នាយកសាលាត្រូវមានបំណិនសំខាន់ៗមួយចំនួនដូចជា បំណិនដោះស្រាយបញ្ហា បំណិនបង្រៀន បំណិនបង្កើតនូវគំនិតថ្មីៗ បំណិនពង្រីកនូវគំនិតល្អៗ និងបំណិនប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ។

ក. បំណិនដោះស្រាយបញ្ហា(Problem solving skills)

បញ្ហាគឺជាឧបសគ្គដែលរារាំងយើងមិនឱ្យសម្រេចនូវទិសដៅរបស់យើងបាន។ បានន័យថា រវាងទីតាំងដែលយើងកំពុងស្ថិតនៅ និងទីដែលយើងត្រូវទៅដល់នោះមានចម្ងាយមួយដែលតាមរយៈចម្ងាយនោះវាមានឧបសគ្គដែលយើងត្រូវពុះពារ ។ ដោះស្រាយបញ្ហាបានន័យថា ដកចេញនូវឧបសគ្គទាំងនោះហើយដាក់ជំនួសវិញនូវមធ្យោបាយផ្សេងទៀតដែលមិនមែនជាឧបសគ្គ។ ធ្វើយ៉ាងនេះបានលុះត្រាតែយើងយល់ថា តើអ្វីជាឧបសគ្គនោះហើយតើអាចដកវាចេញ ឬជំនួសវាដោយរបៀបណា។ ខាងក្រោមនេះជាលំនាំមួយចំនួនដែលគួរពិចារណា ។

សូមចាប់ផ្ដើមដោយធ្វើអត្តសញ្ញាណកម្មនៃបញ្ហា ពិនិត្យឱ្យបានដិតដល់ចំពោះឧបសគ្គនានា។ វាអាចជាបញ្ហាថវិកា បញ្ហាសម្ភារៈ បញ្ហាមនុស្ស។ល។ បន្ទាប់ពីបានធ្វើអត្តសញ្ញាណកម្ម និងវិភាគឧបសគ្គទាំងនោះហើយ យើងអាចមើលឃើញថា តើឧបសគ្គណាអាចត្រូវដកចេញបាន ឧបសគ្គណាអាចត្រូវជំនួសបានដោយលទ្ធភាពផ្សេងៗ។ បន្ទាប់មកយើងអាចធ្វើផែនការនិងអនុវត្តផែនការនោះ។ សូមពិនិត្យមើលនូវបញ្ហាសត្វគោចូលសាលារៀន ហ្វូងគោទាំងនោះវាបំផ្លាញដំណាំរបស់សិស្សបន្ទោរបង់ក្នុងទីធ្លា បំផ្លាញសួនច្បាររបស់សិស្ស ។ យើងឃើញថា គោចូលសាលារៀនគឺបញ្ហាហើយទិសដៅរបស់សាលារៀន គឺបញ្ឈប់កុំឱ្យមានគោចូលសាលារៀនទៀត។ ផ្លូវដែលទៅកាន់ទិសដៅនេះមានឧបសគ្គជាច្រើនដូចជា សាលារៀនពុំមានរបង សហគមន៍សាលារៀនជាសហគមន៍ក្រីក្រពុំអាចមានលទ្ធភាពជួយរួមចំណែកធ្វើរបងបានពុំមានទំនាក់ទំនងល្អរវាងសាលារៀននិងសហគមន៍ គ្រូបង្រៀនមានប្រាក់បៀវត្សតិចតួចបង្ខំឱ្យគាត់រកមុខរបរបន្ថែមមិនអាចជួយយាមការពារសាលារៀនបាន។ ការវិភាគបញ្ហាទាំងនេះអាចនាំនាយកសាលារៀនឈានទៅដល់ការគិតឃើញ

នូវវិធីលុបបំបាត់ចោលនូវឧបសគ្គខ្លះនិងប្រើមធ្យោបាយខ្លះដើម្បីជំនួសឧបសគ្គមួយចំនួន។នាយកសាលាដែលវៃឆ្លាត អាចពិភាក្សាជាមួយគ្រូបង្រៀននិងសិស្សានុសិស្សកសាងរបងសាលាដែលមិនចំណាយប្រាក់ច្រើន។ជំនួសការធ្វើរបងថ្ម គាត់ធ្វើរបងរស់ដោយដាំដើមឈើ ។ ការរកកូនឈើមិនជាការលំបាក។ សិស្សអាចផ្តល់កូនឈើបានឬសាលារៀនអាចកសាងថ្នាលបណ្តុះកូនឈើក្នុងសាលាដែលជាឱកាសឱ្យសិស្សអាចរៀនបានថែមទៀតពីវិទ្យាសាស្ត្រ គណិតវិទ្យា ភាសា ។ល។ចំពោះឧបសគ្គស្តីពីកង្វះការចូលរួមពីសហគមន៍ នាយកសាលាអាចលុបបំបាត់ដោយការរាក់ទាក់ជិតស្និទ្ធជាមួយសមាជិកសហគមន៍ ជួបនិយាយជាមួយពួកគាត់ និងអញ្ជើញពួកគាត់ឱ្យចូលធ្វើទស្សនកិច្ចសាលារៀន។ បន្ទាប់ពីបានធ្វើអត្តសញ្ញាណកម្មឧបសគ្គទាំងនេះហើយ នាយកសាលាត្រូវធ្វើផែនការសម្រាប់ធ្វើសកម្មភាព ។ ផែនការនិងសកម្មភាពសំខាន់ណាស់ ។ មាននាយកសាលាជាច្រើនដែលរមែងមានអារម្មណ៍ធ្លាក់ទឹកចិត្ត នៅពេលដែលគាត់ឃើញបញ្ហាត្រូវដោះស្រាយ ហើយពុំដឹងធ្វើអ្វីក៏រង់ចាំការណែនាំពីថ្នាក់លើ។ ប្រការល្អបំផុតគឺនាយកសាលាមិនត្រូវខ្លាចបញ្ហា។ ត្រូវគិតថា បញ្ហារមែងកើតឡើងជាធម្មតាសម្រាប់អ្នកអនុវត្តការងារ ហើយបញ្ហាទាំងអស់សុទ្ធតែអាចដោះស្រាយបាន ពិសេស ចំពោះមនុស្សដែលស្រេកឃ្លាននូវការសាកល្បងគំនិតថ្មីៗ និងដែលមើលឃើញបញ្ហាថា ជាឱកាសសម្រាប់ពង្រីកចំណេះ ដឹងរបស់ខ្លួន ។ គប្បីមើលទៅបញ្ហាក្នុងផ្លូវវិជ្ជមាន។ បញ្ហាលំបាកប៉ុនណា ឱកាសរៀនក៏មានច្រើនប៉ុននោះ។ ត្រូវយល់ ថា ដំណោះស្រាយស្ថិតនៅចំណោមពួកយើងជាអ្នកអនុវត្តផ្ទាល់ មិនមែនពីខាងក្រៅទេ។

ធ្វើអត្តសញ្ញាណកម្មបញ្ហា ⇨ វិភាគបញ្ហា ⇨ ធ្វើផែនការ ⇨ អនុវត្ត

ខ. បំណិនបង្រៀន (Teaching skills)

គោលបំណងសំខាន់របស់សាលារៀនគឺ **សិស្សរៀន** ហើយដើម្បីជួយសិស្សឱ្យរៀនបានប្រកបដោយប្រសិទ្ធភាព នាយកសាលាមានភារកិច្ចជួយទ្រទ្រង់គ្រូបង្រៀនក្នុងលំនាំធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពបង្រៀនរបស់ខ្លួន។ ភារកិច្ចនេះទាមទារឱ្យគ្រប់នាយកសាលាទាំងអស់មានសមត្ថភាពខ្ពស់។ ទាំងខាងចំណេះដឹងនិងបំណិនលើវិធីបង្រៀន និងធ្វើបច្ចុប្បន្នភាពនូវសមត្ថភាពទាំងអស់នេះជាប្រចាំ ។ ដើម្បីបានយ៉ាងនេះពួកគាត់ត្រូវតែរៀន។ ពួកគាត់ត្រូវតែគិតថា ពីមួយថ្ងៃទៅមួយថ្ងៃ ភារកិច្ចរបស់ពួកគាត់ កាន់តែពិបាកនិងស្មុគស្មាញ ដូចនេះគាត់ត្រូវតែបង្កើនសមត្ថភាពផ្ទាល់ខ្លួនជាប្រចាំ។ កុំគប្បីយល់ថា យើងចាស់ហួសការរៀន ។ ក្នុងស្រីហិតោបទេសដែលត្រូវបកប្រែពីភាសាសំស្រ្កឹតដោយព្រះមហាវិរិយបណ្ឌិតោ ប៉ាង ខាត់ មានល្បះមួយពោលថា « ប្រសិនបើអ្នកស្វែងរកចំណេះ អ្នកត្រូវគិតថា អ្នកមិនចាស់ មិនស្លាប់ ប៉ុន្តែប្រសិនបើអ្នកស្វែងរកធម៌ អ្នកនឹងត្រូវម្រឹត្យុក្របួចកយកទៅឥឡូវហើយ »។ ជានាយកសាលាត្រូវបង្ហាញគំរូជាអ្នករៀនជានិច្ច ជាអ្នករៀនមួយជីវិត។

នាយកសាលាអាចរៀនតាមរយៈការសង្កេតគ្រូបង្រៀនសិស្ស។ការសង្កេតការបង្រៀនមិនមែនបានត្រឹមតែជាការជួយគ្រូបង្រៀនក្នុងលំនាំពង្រីកសមត្ថភាពរបស់គាត់ប៉ុននោះទេប៉ុន្តែវាជាឱកាសផងដែរសម្រាប់នាយកសាលាដកស្រង់បាននូវបទពិសោធន៍ថ្មីៗនៃការបង្រៀន និងរៀនសូត្រពីគំនិតថ្មីៗផងដែរ។ វិធីផ្លូវការនៃការរៀន គឺការទៅចូលរួមសិក្ខាសាលាដែលរៀបចំដោយថ្នាក់គ្រប់គ្រងខាងលើ ឬដោយអង្គការក្រៅរដ្ឋាភិបាលនានា ។ការបំប៉នទាំងនេះអាចផ្តល់ជូននាយកសាលានូវគំនិតថ្មីៗ ហើយជាលទ្ធផលជួយនាយកសាលាឱ្យទទួលបាននូវបច្ចេកទេសថ្មីៗថែមទៀត។ នាយកសាលាជាច្រើនមិនចូលចិត្តសិក្ខាសាលា ។ គាត់តែងគេចវេះពីសិក្ខាសាលានានា ទោះបីជាគាត់មានឱកាសនឹងទៅចូលរួមក្តី។ដោយសារពុំមានឱកាសសាកល្បងគំនិតថ្មីៗនោះ ពីមួយថ្ងៃទៅមួយថ្ងៃ ពួកគាត់ក៏ធ្លាក់ទៅក្នុងអតីតកាល ហើយមានការលំបាកក្នុងការរកគំនិតនិងធ្វើកំណែលំអ។ មិនតែប៉ុណ្ណោះគាត់ក៏បានឱ្យបុគ្គលិកនិងសិស្សរបស់គាត់មើលឃើញថាគាត់មិនឱ្យតម្លៃការសិក្សាទេ។

វិធីមួយទៀតដែលប្រកបដោយប្រសិទ្ធភាពក្នុងការរៀនគឺ ការចែករំលែកបទពិសោធន៍និងបំណិនរវាងគ្នានិងគ្នា។ នោះគឺការជជែកតតួជាមួយគ្នា ការប្រជុំ ការពិភាក្សាដោះស្រាយបញ្ហា។ នាយកសាលាជាច្រើនតែងបង្ហាញមុខនៅគ្រប់

កន្លែងនៃសាលារៀនរាល់ថ្ងៃធ្វើការ។ គាត់ជួបនិយាយជាមួយមាតាបិតាសិស្ស សិស្ស និងគ្រូបង្រៀន… គាត់ប្រជុំជាមួយបុគ្គលិករបស់គាត់ និងចូលរួមក្នុងការប្រជុំក្រុមបច្ចេកទេស។ នេះជាឱកាសជួយឱ្យគាត់អាចបង្កើនសមត្ថភាពនិងបំណិនរបស់គាត់ជាប់ជានិច្ច ហើយពីមួយថ្ងៃទៅមួយថ្ងៃ គាត់ក៏បានក្លាយជានាយកសាលាមួយរូបដែលជួយបង្កើនសមត្ថភាពបង្រៀនរបស់គ្រូបានកាន់តែប្រកបដោយប្រសិទ្ធភាព។ ប្រការដែលគួរឱ្យស្ដាយនោះគឺ កន្លងមកមាននាយកសាលាមួយចំនួនបានបាត់បង់នូវឱកាសនេះដោយគាត់ចំណាយពេលលាក់ខ្លួនតែក្នុងការិយាល័យរបស់គាត់ មិនជួបបុគ្គលិកក្រោមឱវាទ មិនចូលរួមប្រជុំជាមួយក្រុមបច្ចេកទេស ។ គាត់តែងលើកឡើងថា ការងារបង្រៀននិងរៀនជាការទទួលខុសត្រូវរបស់នាយករង ដែលគាត់ទទួលបន្ទុកបច្ចេកទេស។ គាត់យល់ខុសទាំងស្រុង!

វិធីដែលល្អបំផុតសម្រាប់បង្កើនសមត្ថភាពរបស់ខ្លួននោះ គឺការបង្រៀនអ្នកដទៃ។ ជាការពិតណាស់ថា បើយើងចង់រៀនអ្វីនោះ វិធីដែលល្អបំផុត គឺបង្រៀនអ្វីនោះដល់គេ។ ដោយបង្រៀនគេ ឬរំលែកបទពិសោធន៍ជាមួយគេនោះ ការយល់ដឹងរបស់យើងក៏កាន់តែច្បាស់ឡើង កម្រិតចំណេះដឹងរបស់យើងក៏កើនឡើង អាចបង្រៀនបានកាន់តែល្អ ហើយដោយបន្តបង្រៀនជាប់ជានិច្ចនោះ យើងក៏រៀនបានច្រើនឡើងៗរាល់ថ្ងៃ។ នេះជាលំនាំនៃនិរន្តរភាពនៃការរៀន។




គ. បង្កើតតថភាពថ្មីៗ (Creating new realities)

ជាទូទៅ នាយកសាលាច្រើនមានការញញើតញញើមក្នុងការសាកល្បងរកលទ្ធភាពថ្មីក្នុងការដោះស្រាយបញ្ហា។ ជានិច្ចជាកាលគេរង់ចាំអនុសាសន៍ពីថ្នាក់ដឹកនាំខាងលើ ឬអនុវត្តវិធីដែលគេមើលឃើញថា ជាវិធីល្អកន្លងមកឬចម្លងតាមបុគ្គលទាំងឡាយដែលធ្លាប់មានជោគជ័យ។ ប៉ុន្តែគ្រប់បញ្ហាមិនមែនសុទ្ធតែដូចគ្នានោះទេ។ មានបញ្ហាជាច្រើនដែលកើតឡើងដោយមិនបានគិតទុកជាមុន ហើយទាមទារនូវដំណោះស្រាយពិសេស ដោយឡែករបស់ខ្លួន។ បទពិសោធឬមេរៀនពីអតីតកាលមិនមែនជានិច្ចកាល ជាមេរៀនមានប្រសិទ្ធភាពសម្រាប់បច្ចុប្បន្ន ហើយលើសពីនេះមេរៀនទាំងនោះអាចមិនសមស្របទៅនឹងតថភាពនៃបញ្ហា ។ ដើម្បីបានជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព នាយកសាលាត្រូវតែហ៊ានបង្កើតនូវលទ្ធភាពថ្មីៗក្នុងការដោះស្រាយបញ្ហា។ វិធីដ៏ល្អសម្រាប់ការងារនេះ គេគប្បីសាកល្បងឆ្លើយនូវសំណួរ មានអ្វីកើតឡើងប្រសិនបើ…?

ឃ.ពង្រីកនូវគំនិតដែលមានរួចហើយ (Expanding on existing ideas)

អ្នកដឹកនាំពូកែ គឺជាអ្នកដែលពូកែលួចគំនិត។ គាត់សិក្សាមេរៀនពីប្រវត្តិសាស្ត្រ ហើយស្វែងរកគំនិតណាដែលអាចសម្របសម្រួលជាមួយនឹងស្ថានភាពបច្ចុប្បន្ន។ ធ្វើបែបនេះ ខួរក្បាលរបស់គេរមែងពោរពេញទៅដោយគំនិត និងយុទ្ធសាស្ត្រល្អៗ ហើយនៅពេលណាដែលសាលាជួបប្រទះនូវបញ្ហាអ្វីមួយគាត់អាចដោះស្រាយបញ្ហានេះបានភ្លាម ប្រកបដោយភាពឈ្លាសវៃដោយប្រើប្រាស់មេរៀនដែលគាត់បានទទួលពីអ្នកដទៃ។ « លួចគំនិត » មិនមែនជាការលំបាក។ យើងអាចរកឃើញគំនិតល្អៗគ្រប់ទីកន្លែងក្នុងសៀវភៅ ក្នុងកាសែត ក្នុងទស្សនាវដ្ដី ក្នុងការអនុវត្ត ក្នុងសាលារៀន នៅសាលាផ្សេងទៀត ក្នុងប្រទេស នៅប្រទេសដទៃទៀត។ យើងអាចរុករកគំនិតទាំងនោះដោយអាន សង្កេតឬច្នៃតាមបរិបទរបស់យើង។ នាយកសាលាមួយចំនួនមានទម្លាប់ប្រមូលគំនិតដោយកាត់យកអត្ថបទដែលគាត់មើលឃើញថាមានប្រយោជន៍យកទៅរក្សាទុកក្នុងសំណុំឯកសារមួយដែលជា « ឃ្លាំងគំនិតល្អៗ » របស់គាត់។ (នៅមានត)

**លោក អ៊ីវ សារីក់**

# វេយ្យាករណ៍

## របៀបប្រើពាក្យ(ត)

### នៅ និង នូវ

ពាក្យទាំងនេះ ផ្សេងគ្នាដោយអត្ថាធិប្បាយនិងវិធីប្រើដូចខាងក្រោមនេះ

១-នៅជាកិរិយាស័ព្ទនិងជាអាយតនិបាតស័ព្ទ។

ក- ជាកិរិយាស័ព្ទ : ខ្ញុំនៅក្នុងសង្កាត់ទឹកថ្លា។ គាត់នៅក្នុងសង្កាត់ទន្លេបាសាក់

ខ- ជាអាយតនិបាតស័ព្ទ : គេប្រើរៀងខាងដើមនាមស័ព្ទបញ្ជាក់ទីឬពេល។

ឧ- នៅក្រុងភ្នំពេញ មានអគារខ្ពស់ៗច្រើន ។

- សូមអញ្ជើញបងប្អូនញាតិមិត្ត ទៅពិសាភោជនាហារនៅគេហដ្ឋានខាងស្រីនៅថ្ងៃទី១៥មីនា នៅវេលាម៉ោង ៤ ល្ងាច ។

២- នូវ ជាអាយតនិបាតស័ព្ទ និងជាសន្ធានស័ព្ទ ។

ក- ជាអាយតនិបាតស័ព្ទ គេប្រើរៀងពីខាងដើមនាមស័ព្ទដែលជាកម្មបទរងអំពើនៃកិរិយាស័ព្ទ ។ ជួនកាលរៀងបន្ទាប់ផ្ទាល់កិរិយាស័ព្ទ ជួនកាលបន្ទាប់ឃ្លាដែលជ្រែកចូលមក ដូច ៖

ឧ- ព្រះសង្ឃទទួលនូវទេយ្យទាន ដែលជនអ្នកមានសទ្ធាប្រគេន ហើយនិមន្តទៅវត្តវិញ ។

- ព្រះបាទសម្ដេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះរាជានៃប្រទេសកម្ពុជា បានទ្រង់ព្រះរាជទានដល់ប្រជារាស្ត្រ របស់ព្រះអង្គ នូវរដ្ឋធម្មនុញ្ញ ប្រកបដោយលទ្ធិប្រជាធិបតេយ្យ នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧ ។

ខ- ជាសន្ធានស័ព្ទ គេប្រើជំនួសពាក្យថា និង។

ឧ- នាម៉ឺនសព្វមុខមន្ត្រី នូវប្រជារាស្ត្រទាំងអស់ មានសេចក្ដីសោមនស្ស សប្បាយក្នុងព្រះរាជពិធីបុណ្យអុំទូក លយប្រទីប ។

### ត្រូវ

ខាងក្រោមនេះបង្ហាញឱ្យឃើញថា តើគេប្រើពាក្យ « ត្រូវ » ក្នុងករណីយ៉ាងណាខ្លះ ?

១-ត្រូវជាគុណស័ព្ទ កាលណាបើវាបញ្ជាក់នាមស័ព្ទ ។

ឧ. ការចិញ្ចឹមជីវិតត្រូវ ជាផ្លូវដ៏ប្រសើរមួយ លោកហៅថាអរិយមគ្គ ។

២- ត្រូវគេប្រើជាកិ.វិ ។ ឧ. លោកគ្រូថាត្រូវ ។

៣- ត្រូវគេប្រើជាកិរិយានុគ្រោះរៀងពីខាងដើមកិរិយាស័ព្ទ បញ្ជាក់នូវការចាំបាច់ ឬ ការខានមិនបាន។

ឧ. គេត្រូវរៀនសរសេរឱ្យបានត្រឹមត្រូវ ។

ជួនកាលគេប្រើជាមួយពាក្យថា « តែ » ជា « ត្រូវតែ» ។

ឧ. ពលរដ្ឋម្នាក់ៗ ត្រូវតែបង់ពន្ធជូនរាជការ ។

### ដែល- មិនដែល

ពាក្យទាំងពីរនេះយើងប្រើដើម្បីបញ្ជាក់ពីការធ្លាប់ធ្វើអំពើអ្វីមួយពីមុនមក ជួនកាលគេប្រើពាក្យថា ធ្លាប់ មិនធ្លាប់ ជំនួស។

ឧ. បងដែលអញ្ជើញទៅអង្គរវត្តឬទេ ? ខ្ញុំដែលទៅដែរ!

ប្អូនស្រីខ្ញុំមិនដែលទៅអង្គរវត្តទេ ។ ខ្ញុំធ្លាប់ឮឈ្មោះគាត់ដែរ តែខ្ញុំមិនធ្លាប់រៀនជាមួយគាត់ទេ ។ គាត់មិនដែលអញ្ជើញទៅវត្តដោយដៃទទេ ទេ។

## ញឹកញយ ញយៗ រឿយៗ

ពាក្យទាំងនេះជាកិ.វិ បញ្ជាក់ពីការប្រព្រឹត្តទៅរឿយៗ នៃកិរិយាស័ព្ទ ជួនកាលប្រើពាក្យ ជា ឬ យ៉ាង រៀងពីខាងដើម ដូចជា ជាញឹកញយ ជារឿយៗ យ៉ាងរឿយៗ ....... ។ល។ ជួនកាលយើងប្រើពាក្យ ញឹក តែឯង ដូចជា ស្រឡាញ់កុំទៅញឹក បើរឭកសឹមទៅម្ដងៗ ។

### ក៏

ពាក្យ ក៏ មិនមែនជាពាក្យឥតន័យដូចពាក្យ ដ៏ ទេ ។ក្នុងភាសាខ្មែរ យើងប្រើពាក្យ ក៏ នេះជារឿយៗ ។ ក៏ជាសន្ធានស័ព្ទមានន័យច្រើនយ៉ាងដូច្នេះ ៖

១- មានន័យថា បើ ។ ឧ. បើយើងនៅ ទៅអ៊ីចឹង ទៅក៏ទៅ ។

២- មានន័យថា ហើយ រួចហើយ ពេលនោះ ។ ឧ. ព្រះពុទ្ធក៏ទ្រង់អនុញ្ញាតឱ្យភិក្ខុប្រើប្រាស់កឋិនចីវររៀងមក។

៣- មានន័យថា ទោះបី បើទុកណាជា សូម្បីតែ។ ឧ. បើទុកជាយ៉ាងណាក៏ដោយ ក៏ខ្ញុំរៀនតទៅទៀតដែរ។

៤- មានន័យថា បានច្រើនយ៉ាង គេធ្វើបានដោយមធ្យោបាយច្រើនយ៉ាង ។

ឧ. គេទៅសៀមរាបតាមឡានក៏បាន តាមយន្តហោះក៏បាន តាមកប៉ាល់ទឹកក៏បាន។

៥- ក៏......... ដែរ បញ្ជាក់នូវការដូចគ្នា នៃមនុស្សឬរបស់ ។

ឧ. ប្រពន្ធគាត់និយាយភាសាអង់គ្លេសល្អណាស់ គាត់ក៏និយាយភាសាអង់គ្លេសល្អណាស់ដែរ ។

ផ្ទះនេះក៏ល្អដែរ ។ ឡាននេះក៏លឿនដែរ ។

ក្នុងករណីនេះក៏គេរៀបខាងដើមកិរិយាស័ព្ទ គុណស័ព្ទឬកិ.វិ ហើយដែរគេរៀបបន្ទាប់ភ្លាមឬបន្ទាប់កម្មបទ

ឧ. ខ្ញុំក៏រៀនដែរ ។

- ខ្ញុំក៏រៀនវេយ្យាករណ៍ដែរ ។
- សៀវភៅនោះក៏ថ្លៃណាស់ដែរ ។
- នាឡិកានេះក៏ដើរលឿនដែរ ។

(នៅមានត)

**លោកចែម ផាន**

## អសង្ខេយ្យ

*អានថា អៈសង់ខៃ ឬា ( គុ ) ដែលច្រើនរាប់ពុំអស់ ដែលរាប់ពុំបាន ប្រមាណពុំអស់ ច្រើនជាអសង្ខេយ្យ ។ នាមឈ្មោះសំខ្យាចំនួនមួយរយសែនមហាកថាន ( មាន ១៤០សូន្យ ) ។ អសង្ខេយ្យអប្បមេយ្យ ច្រើនរាប់ពុំបាន ស្មានឬប្រៀបប្រដូចពុំកើត ... មានផលានិសង្ស ជាអសង្ខេយ្យអប្បមេយ្យ ។*

# សាលារៀនជាមជ្ឈដ្ឋានផ្សាយនូវវិជ្ជាទូទៅ(ត)

នៅក្នុងសាលារៀននីមួយៗ គ្រូទាំងអស់ត្រូវរួបរួមគ្នាជាក្រុមមួយ ដែលមានសន្តានចិត្ត ស្មារតី មានឧត្តមគតិដូចគ្នាក្នុងការបម្រើប្រយោជន៍សិស្សានុសិស្ស។ ការជួយគ្នាទៅវិញទៅមក រវាងគ្រូនិងគ្រូ ជាប្រភពមួយជួយឱ្យសិស្សរីកចម្រើនយ៉ាងងាយស្រួល។ប៉ុន្តែការណ៍នេះមិនទាន់គ្រប់គ្រាន់ទេ។ បរិយាកាសល្អដែលជួយឱ្យសិស្សរីកចម្រើនបានស្រួលនោះ អាស្រ័យដោយសាលារៀន និងគ្រួសារសិស្សមានសហប្រតិបត្តិការល្អដែរ។

គ្រូម្នាក់ៗត្រូវដឹងថា មាតាបិតាសិស្សមានការទុកចិត្ត មានការកក់ក្ដៅលើគ្រូជាទីបំផុត នៅពេលដែលគាត់យកកូនមកប្រគល់ឱ្យគ្រូ។ តែឪពុកម្ដាយសិស្សវិញក៏ត្រូវដឹងថា សាលារៀនមិនអាចជំនួសគ្រួសារសិស្សបានឡើយ។ សាលារៀនគ្រាន់តែជាជំនួយរបស់គ្រួសារប៉ុណ្ណោះ ។ ឪពុកម្ដាយសិស្សគួរតែយល់ពីការទទួលខុសត្រូវរបស់ខ្លួនក្នុងវិស័យនេះ។ ដូចនេះ គេត្រូវពន្យល់មាតាបិតាសិស្សឱ្យយល់ពីគោលបំណងនៃសាលារៀន ពោលគឺសាលារៀនមិនមែនគ្រាន់តែផ្ដល់នូវចំណេះវិជ្ជាដល់សិស្ស ដើម្បីសញ្ញាបត្រ កន្លែងធ្វើការរាជការ និង ប្រាក់កាសប៉ុណ្ណោះទេ តែជាងនេះទៅទៀត សាលារៀនមានគោលបំណងបណ្ដុះសិស្សឱ្យមានប្រាជ្ញា សតិសម្បជញ្ញៈ និងឆន្ទៈមុតមាំ ។

ដូច្នេះគ្រូត្រូវតែឱ្យព័ត៌មានផ្សេងៗដល់គ្រួសារ ដូចជាចរិយា ការប្រព្រឹត្តរបស់សិស្ស ដែលជាសញ្ញាប្លែកៗ ហើយធ្វើដូចម្ដេចកុំឱ្យមានប្រតិកម្មកើតឡើង។ ចំពោះរឿងនេះ គ្រូត្រូវបំភ្លឺព្យាយាមធ្វើឱ្យមាតាបិតាសិស្ស យល់ពីវិធីអប់រំផ្សេងៗណាដែលអាចដឹកនាំសិស្សឱ្យដើរក្នុងផ្លូវល្អបាន។ គ្រូដែលបានបំពេញនូវសកម្មភាពខាងលើនេះ ឈ្មោះថា ជាអ្នកបានបំពេញកិច្ចមួយដ៏ធំហើយសំខាន់ ផ្ដល់ទៅឱ្យសិស្សនិងមាតាបិតាសិស្ស ។

តើនៅក្នុងឱកាសណាខ្លះ អ្នកអប់រំអាចនឹងប្រស្រ័យទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងឪពុកម្ដាយសិស្ស?

ឪពុកម្ដាយសិស្ស និងគ្រូត្រូវតែស្គាល់គ្នា ។ តែការគ្រាន់តែជួបគ្នាមួយពេលៗនោះមិនទាន់គ្រប់គ្រាន់ទេ។ ដើម្បីស្គាល់ យល់នូវក្មេងម្នាក់ឱ្យបានច្បាស់លាស់ ហើយដឹកនាំវា(Comprendre un enfant et le guider)យើងតោងតែស្គាល់គ្រួសារនោះពិតប្រាកដ ស្គាល់លក្ខខណ្ឌនៃការរស់នៅធម្មតារបស់គ្រួសារនេះ ហើយត្រូវធ្វើការសិក្សាស្រាវជ្រាវរិះរកហេតុភេទសញ្ញា ដែលធ្វើឱ្យក្មេងនោះ មានវិបត្តិខាងផ្លូវកាយ និងផ្លូវចិត្ត។

ខ្ញុំសុំបើកវង់ក្រចក ហើយនិយាយអំពីសិស្សដែលគ្រូឱ្យឈ្មោះថា**ខ្ជិល**។ អ្វីដែលគេហៅថាក្មេង**ខ្ជិល** គឺក្មេងដែលមិនធ្វើការ ឬ ធ្វើការមិនគ្រប់គ្រាន់ ។ តើក្មេងឈឺរៀនមិនកើត ហើយខំប្រឹងទៅសាលារៀនជាក្មេងខ្ជិលដែរឬទេ?ក្មេងដែលមិនទាន់យល់ការពន្យល់របស់គ្រូ ធ្វើកិច្ចការមិនកើតជាក្មេងខ្ជិលដែរឬទេ? ក្មេងម្នាក់រវល់រត់ម៉ូតូឌុបនៅពេលយប់ ហើយមិនបានរៀនមេរៀន តើគ្រូអាចទុកថាក្មេងនេះជាក្មេងខ្ជិលដែរឬទេ?

ចំពោះគ្រូនៅតាមស្រុកស្រែចំការ នៅក្នុងឱកាសដើរទៅក្នុងភូមិម្ដងៗ គ្រូម្នាក់ៗនឹងអាចទាក់ទងសួរសុខទុក្ខគ្រួសាររបស់សិស្ស ហើយឆ្លៀតយកព័ត៌មានផ្សេងៗ ដែលចាត់ទុកថា មានតម្លៃចំពោះការណែនាំតម្រង់ផ្លូវមួយដ៏ប្រសើរនៃការខិតខំប្រឹងប្រែងអប់រំរបស់សិស្សយើង ។ នេះចំពោះគ្រូណាដែលយល់ថា សកម្មភាពបែបនេះមានប្រយោជន៍ដល់សិស្ស និងឪពុកម្ដាយសិស្ស។

ការជួបគ្នាប៉ុណ្ណោះ នៅតែមិនទាន់គ្រប់គ្រាន់ទៀត ។ គ្រូអាចមានមធ្យោបាយមួយទៀតគឺការធ្វើព្រឹត្តិបត្រស្រង់ពិន្ទុ ឬ សៀវភៅទំនាក់ទំនងសិស្សនេះដែរ ប៉ុន្តែមិនទាន់បានល្អនៅឡើយទេ ។

ព្រឹត្តិបត្រស្រង់ពិន្ទុ មិនមែនសំខាន់នៅត្រង់លក្ខខណ្ឌបញ្ជាក់លទ្ធផលនៃការបូកពិន្ទុទេ តែសំខាន់ក្នុងការឱ្យដំណឹងដល់មាតាបិតាសិស្ស អំពីកិច្ចការ ចរិយារបស់សិស្សហើយជាពិសេសនូវមូលវិចារប្លែកៗនៃភាពជឿនលឿន និងភាពអន់ថយរបស់សិស្ស។

ឪពុកម្តាយសិស្សត្រូវតែទៅធ្វើទស្សនកិច្ចដល់សាលារៀន ។ រីឯសាលារៀនវិញក៏ត្រូវសប្បាយចិត្ត ត្រូវតែមានការទទួលដោយរាក់ទាក់ នៅពេលឪពុកម្តាយសិស្សចូលមកដល់។ ឪពុកម្តាយសិស្សត្រូវតែយកចិត្តទុកដាក់នឹងសាលារៀន យកចិត្តទុកដាក់នឹងកិច្ចការដែលគេបានធ្វើក្នុងសាលារៀន។

ដើម្បីឱ្យឪពុកម្តាយសិស្សយល់ ស្គាល់នូវសារប្រយោជន៍នៃជីវភាពក្នុងសាលារៀន គេត្រូវបង្កើនការទាក់ទងរវាងឪពុកម្តាយសិស្សនិងសិស្ស ដោយមធ្យោបាយរៀបចំរាត្រីសមោសរ តាមបែបមនុស្សពេញវ័យដែលចាត់ចែងដោយគ្រូនិងសិស្សានុសិស្ស ។ ម្យ៉ាងទៀតដើម្បីហ្វឹកហ្វឺនបង្ហាត់បង្រៀនជនទាំងនោះគេត្រូវប្រារព្ធធ្វើសន្និសីទផ្សេងៗ ឬ ការអានអត្ថបទជាសាធារណៈ(Lectures Publiques)។

គេត្រូវគិតធ្វើយ៉ាងដូចម្តេចឱ្យមានការទាក់ទងដោយផ្ទាល់ហើយបង្កើតឱ្យមានការប្រមូលប្រជុំនៃមាតាបិតាសិស្សជជែកវែកញែកពិភាក្សាពីបញ្ហាអប់រំសំខាន់ៗ ដែលមានលក្ខណៈជាសាធារណៈ។ ទាំងអស់នេះប្រព្រឹត្តទៅបានតែក្នុងករណីគ្រូទាំងអស់រួបរួមសាមគ្គី ហើយម្នាក់ៗមានការដឹង យល់ ឬ ជឿជាក់លើភាពសំខាន់នៃបេសកម្មរបស់ខ្លួន ដូចជារកមធ្យោបាយបង្កបង្កើត និងរៀបចំសន្និសីទ ឱ្យមានលក្ខណៈស្របតាមតម្រូវការផ្ទាល់នៃជនទាំងនោះ។

ម្យ៉ាងទៀត គឺត្រូវធ្វើឱ្យសាលារៀនទៅជាចំណងយ៉ាងរស់រវើក ចងភ្ជាប់យុវជននៅពេលដែលចប់ការសិក្សានិងជាទីកន្លែងជួបជុំគ្នា និងឱកាសរំឭកនូវអនុស្សាវរីយ៍សិក្សារួមគ្នានៃយុវជនទាំងនោះ។ រីឯការអប់រំធ្វើឱ្យយុវជនមានការជាប់ជំពាក់ ស្រឡាញ់ភូមិកំណើតរបស់ខ្លួន ក៏អនុវត្តនូវវិធីរបៀបនេះដែរ ។

បើយើងធ្វើទាំងនេះបាន សាលារៀក៏ដូចជាវត្តអារាម គឺជាទីកន្លែងដែលគ្រួសារនានា អាចមកជួបជុំបានក្នុងឱកាសផ្សេងៗ ។ ដូចនេះ យើងឃើញថាសាលារៀនមានមុខងារហៀរហួសពីក្របខណ្ឌតូចចង្អៀតពីព្រោះថា ក្នុងការផ្សព្វផ្សាយចេញទៅគ្រប់ទិសទី នូវកិត្តិគុណដល់សង្គមមនុស្សទូទៅ សាលារៀនប្រែទៅជាវត្ថុជាតុមួយសម្រាប់ផ្តល់ជីវិត ។

នៅចំពោះភ្នែកអ្នកស្រុកមុខងាររបស់គ្រូជាអ្នកបង្រៀននិងជាអ្នកអប់រំ បានធ្វើឱ្យគ្រួសារមានកិត្យានុភាពមានកិត្តិនាមដ៏ខ្ពង់ខ្ពស់។ ដូចនេះគ្រូត្រូវតែចេះធ្វើឱ្យកិត្យានុភាពនេះមានតម្លៃ ដើម្បីទុកជាប្រយោជន៍ដល់អ្នកស្រុក ។ ចំពោះអ្នកស្រុក គេតែងចាត់ទុកគ្រូជាអ្នកដឹកនាំខាងបញ្ញា ខាងចរិយា និងខាងសង្គម ។ គ្រូបានទទួលការអប់រំម្តងរួចហើយ ក៏ប៉ុន្តែមុខងាររបស់គ្រូ បង្ខំគ្រូឬតម្រូវគ្រូឱ្យអប់រំខ្លួនឯងតទៅមុខទៀត ។ ការអប់រំខ្លួនឯងតទៅទៀតនេះ ធ្វើឱ្យគេឃើញថា ការប្រព្រឹត្តិរបស់គ្រូ មិនខុសគ្នាពីការទូន្មានប្រដៅរបស់ខ្លួនធ្វើឱ្យគេឃើញថា គ្រូជាគំរូប្រពៃមួយគ្រប់វិស័យទាំងអស់ ។ តាមធម្មតាអ្នកទាំងឡាយ មានកិត្តិនាមជាវរជន(L'ELITE) នៃប្រទេសជាតិ ។

នៅឱកាសខ្លះ គ្រូឆ្លៀតទៅដោះស្រាយដោយផ្ទាល់ខ្លួន នូវបញ្ហាផ្សេងៗនៃសង្គមដែលមានចោទឡើងនៅជុំវិញខ្លួនគ្រូ តែការធ្វើការដោះស្រាយមានលក្ខណៈរួម ។

ករណីយកិច្ចរបស់គ្រូ គឺត្រូវបំភ្លឺនូវសារប្រយោជន៍ដល់សហគមន៍ ដោយមិនតាំងខ្លួនជាចៅហ្វាយនាយ ហើយមិនត្រូវធ្វើការកាត់មុខអ្នកទទួលខុសត្រូវ ។

កិច្ចការចាំបាច់នៃសង្គម ដែលអ្នកអប់រំត្រូវទទួលបន្ទុក ៖

ឧទាហរណ៍ ៖ ណែនាំអ្នកស្រុកឱ្យចេះប្រើបង្គន់អនាម័យ ចេះដាំដើមឈើសម្រាប់ឱ្យម្លប់ដល់ផ្ទះ ចេះដាំដើមផ្កាជាគ្រឿងលម្អដល់ផ្ទះ ចូលចិត្តប្រតិបត្តិតាមក្បួនអនាម័យ (Les Regles d'hygene)ណែនាំអ្នកស្រុកឱ្យចេះធ្វើជីក្រោល«ជីអាចម៍គោឬជីកំប៉ុស » កុំធ្វើក្រោលគោនៅក្រោមផ្ទះ ។ ណែនាំអ្នកស្រុកឱ្យចេះជួយគ្នាទៅវិញទៅមកដូចសម័យមហានគរ ឱ្យយល់នូវប្រយោជន៍នៃការអភិវឌ្ឍ ឱ្យព័ត៌មានដល់អ្នកស្រុកអំពីបច្ចេកទេសនៃកសិកម្មនិងចិញ្ចឹមសត្វ។ ខ្ញុំសូមគូសបញ្ជាក់អំពីការចិញ្ចឹមសត្វប្រចាំគ្រួសារអ្នកស្រុកខ្លះចិញ្ចឹមមាន់ តែការពិតវិញ អ្នកស្រុកទាំងនោះមិនចិញ្ចឹមសោះ ពីព្រោះគាត់មិនឱ្យចំណី ឬ មិនថែទាំមាន់គាត់សោះ ។ ខ្ញុំបាទសង្ខេបតែប៉ុណ្ណេះ នូវការដែលសាលារៀនអាចជួយអ្នកស្រុកបាន ។

(នៅមានត)

**លោក ចែម ផាន**

# គណិតវិទ្យា

## ការស្រាវជ្រាវរកព័ត៌មានដែលខ្វះ ដើម្បីឆ្លើយនឹងសំណួរ

**វត្ថុបំណង**

- អានព័ត៌មានផ្សេងៗ
- សម្គាល់បរិបទ
- ឱ្យអត្ថន័យនៃព័ត៌មាន
- ស្រាវជ្រាវរកព័ត៌មានដែលខ្វះ

I. **គោលបំណងរបស់សលាកប័ត្រ**

បណ្ដុះសិស្សឱ្យមានចរិតចេះវិភាគឱ្យបានហ្មត់ចត់ និងកុំឱ្យមានចរិតជឿជាក់ភ្លាមចំពោះហេតុការណ៍អ្វីមួយ។

<u>**ចំណោទ**</u>

រថយន្តដឹកទំនិញធុនធំមួយជិតអស់ប្រេងសាំង ។ ក្នុងធុងប្រេងរថយន្តនោះនៅសល់ប្រេងសាំងតែ៥លីត្រ ។ មកដល់ស្ថានីយ៍ប្រេងឥន្ធនៈ អ្នកបើកបរក៏ឈប់ រួចឱ្យគេចាក់ប្រេងសាំងបំពេញធុងរថយន្តរបស់គាត់។ តើក្នុងធុងប្រេងរថយន្តនោះមានប្រេងសាំងប៉ុន្មានលីត្រ?

II. **ការរៀបចំរបស់គ្រូ**

- គ្រូត្រូវចម្លងចំណោទដាក់ក្ដារខៀនមុនម៉ោងបង្រៀន។
- គ្រូត្រូវរៀបចំជាមុននូវតារាងដើម្បីយកទៅបិទលើក្ដារខៀន នៅពេលធ្វើការបូកសរុប។

III. **លំនាំនៃការបង្រៀន**

<u>**ដំណាក់ទី១**</u> **: អំណាន និងការយល់អត្ថន័យនៃអត្ថបទ**

- ឱ្យសិស្សអានចំណោទដោយស្ងៀមស្ងាត់
- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សអាន
- ឱ្យសិស្សបកស្រាយអត្ថន័យចំណោទដោយចោទជាសំណួរ (ម្ដងមួយសំណួរៗ)

« តើក្នុងចំណោទនេះគេនិយាយអំពីអ្វីខ្លះ? »

« តើអ្នកអាចដោះស្រាយចំណោទនេះបានដែរឬទេ? ព្រោះអ្វី? »

(មិនអាចដោះស្រាយបានទេ ព្រោះគេមិនដឹងចំណុះប្រេងសាំងដែលគេបានចាក់)

- ឱ្យសិស្សឆ្លើយឱ្យបានច្រើននាក់ក្នុងសំណួរនីមួយៗ ដោយបកស្រាយពន្យល់ផង
- ឱ្យសិស្សដទៃទៀតផ្ទៀងផ្ទាត់ និងផ្ដល់ចម្លើយ
- ឱ្យសិស្សរកព័ត៌មានដែលខ្វះ។
- គ្រូពន្យល់បន្ថែមថា ៖ « គេពុំដឹងចំណុះប្រេងសាំងដែលគេបានចាក់ » គឺព័ត៌មានដែលខ្វះ ។

<u>**ដំណាក់ទី២**</u> **: ការស្រាវជ្រាវរបស់សិស្ស**

- គ្រូរៀបចំសិស្សពី ២ ទៅ ៤ នាក់។

<u>***សំណូមពរ***</u>: កូនទាំងអស់គ្នាបានដឹងហើយថា ចំណោទនេះមិនអាចដោះស្រាយបានទេ ដូច្នេះកូនត្រូវរកឱ្យឃើញព័ត៌មានដែលខ្វះ ដើម្បីបំពេញន័យចំណោទនេះ បន្ទាប់មកចូរឆ្លើយនឹងសំណួរដោយធ្វើប្រមាណវិធីផង។

- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សស្រាវជ្រាវរក
- គ្រូចល័តតាមជួរសិស្ស ដើម្បីពិនិត្យមើលការងាររបស់ពួកគេ។

✷ប្រសិនបើមានសិស្សដែលពុំទាន់យល់ច្បាស់លាស់គ្រូត្រូវយកសំណួរទាំងពីរក្នុងដំណាក់ទី១មកចោទសួរសិស្សឡើងវិញ ព្រមទាំងបញ្ជាក់ឡើងវិញឱ្យបានច្បាស់លាស់នូវសំណួរខាងលើនេះ

- ឱ្យសិស្សដែលមិនយល់ឆ្លើយឱ្យបានច្រើននាក់ ដើម្បីឱ្យគេយល់បានល្អ ឱ្យសិស្សបន្តការស្រាវជ្រាវ ។

**<u>ដំណាក់ទី៣</u> : ការបូកសរុប**

- ឱ្យសិស្សពីរនាក់ឡើងក្តារខៀនៈ ម្នាក់អានចំណោទដែលគេបានបន្ថែមព័ត៌មានដែលខ្វះ ហើយម្នាក់ទៀតជាអ្នកធ្វើប្រមាណវិធី

- ឱ្យសិស្សឯទៀតផ្ទៀងផ្ទាត់ និងផ្ទុផ្ទងចម្លើយរបស់គេនិងជួយកែលម្អ

-ឱ្យសិស្សដទៃទៀតឡើងបង្ហាញចម្លើយរបស់គេប៉ុន្តែត្រូវបង្ហាញតែចម្លើយណាដែលគេរកឃើញផ្សេងពីអ្នកមុនៗ ពុំមែនឱ្យបង្ហាញចម្លើយដដែលៗដូចគ្នានោះទេ ។ គ្រូត្រូវអនុវត្តតាមលំនាំបង្រៀនខាងដើមនេះ ។

✷គ្រូត្រូវយល់ថា ចំណោទនេះអាចមានចម្លើយច្រើន ដូច្នេះចាំបាច់ត្រូវប្រមូលចម្លើយដែលសិស្សបានរកឃើញទាំងអស់ ដោយកត់ត្រានៅលើជ្រុងម្ខាងនៃក្តារខៀន ។ បន្ទាប់មកគ្រូវពន្យល់សិស្សថា ធុងប្រេងរបស់រថយន្តដឹកទំនិញធុនធំមួយអាចមានចំណុះប្រេង ១០០ លីត្រ ជាអតិបរិមា។

- គ្រូយកតារាងដែលបានរៀបចំទុកជាមុនលើផ្ទាំងក្រដាសធំមកបិទលើក្តារខៀន រួចឱ្យសិស្សឡើងបំពេញតារាងនោះ(ការងាររួម)ពេលសិស្សម្នាក់ឡើងបំពេញត្រូវឱ្យសិស្សដទៃទៀតតាមដានពិនិត្យ និងជួយកែលម្អ ។

| អត្ថបទ ✷ | ព័ត៌មានដែលខ្វះ | បម្រាប់ជាលេខ | ដំណោះស្រាយ |
|---|---|---|---|
| រថយន្តដឹកទំនិញធុនធំមួយជិតអស់ប្រេងសាំង ។ ក្នុងធុងប្រេងរថយន្តនោះនៅសល់ប្រេងសាំងតែ៥លីត្រ។ មកដល់ស្ថានីយ៍ប្រេងឥន្ធនៈ អ្នកបើកបរក៏ឈប់ រួចឱ្យគេចាក់ប្រេងសាំងបំពេញធុងរថយន្តរបស់គាត់។<br>តើក្នុងធុងប្រេងរថយន្តនោះមានប្រេងសាំងប៉ុន្មានលីត្រ? | | | |

-គ្រូជួយកែលម្អនិងបំពេញបន្ថែម

- ឱ្យសិស្សចម្លងតារាងនេះចូលក្នុងសៀវភៅ ។

**<u>ដំណាក់ទី៤</u> : ការពង្រឹងចំណេះដឹង**

- ឱ្យសិស្សយកក្តារឆ្នួនចេញ។

**<u>សំណួមពរ</u>** : ចូរកូនតាមដានស្តាប់ដោយប្រុងប្រយ័ត្ននូវអត្ថបទចំណោទដែលគ្រូអាន ហើយកត់ត្រានៅលើក្តារឆ្នួននូវព័ត៌មានដែលខ្វះ ដើម្បីឆ្លើយនឹងសំណួរ ។

**<u>ចំណោទ</u>** : នៅហាងលក់នំប៉័ង ម្តាយខ្ញុំបានទិញនំប៉័ង ២ដើម ដែលមានតម្លៃ ៥០០៛ ក្នុងមួយដើម ។ តើអ្នកលក់នំប៉័ងបានអាប់ប្រាក់មកម្តាយខ្ញុំវិញចំនួនប៉ុន្មាន?

- គ្រូត្រូវអានចំណោទខាងលើនេះយឺតៗ ឱ្យបានពីរទៅបីដង

- ឱ្យសិស្សសរសេរព័ត៌មានដែលខ្វះនៅលើក្តារឆ្នួនជាបុគ្គល

- ដើរពិនិត្យមើលការងារសិស្ស - ឱ្យសិស្សលើកក្តារឆ្នួន

- ឱ្យសិស្សផ្ទៀងផ្ទាត់និងផ្ទុផ្ទងចម្លើយ

- គ្រូធ្វើការបូកសរុប « ប្រាក់ដែលម្តាយខ្ញុំបានឱ្យទៅអ្នកលក់ » គឺជាព័ត៌មានដែលខ្វះ ។

- អនុវត្តដូចលំនាំខាងលើនេះចំពោះចំណោទខាងក្រោម ៖

**<u>ចំណោទ</u>** : នៅផ្សារធំថ្មី ដារាបានទិញមាន់ពីរទម្ងន់៣,៤០គ.ក។ តើដារាបានចំណាយប្រាក់អស់ប៉ុន្មានរៀល?

<u>ដំណាក់ទី៥</u> : ការសន្និដ្ឋាន

- គ្រូសួរ : « ក្នុងចំណោទទាំងអស់សុទ្ធតែ ជាចំណោទដែលអាចដោះស្រាយបានមែនឬទេ ?ព្រោះអ្វី ? »
- ឱ្យសិស្សឆ្លើយឱ្យបានច្រើននាក់
- ឱ្យសិស្សផ្ទៀងផ្ទាត់ចម្លើយ និងជួយកែលម្អ
- គ្រូធ្វើការបូកសរុបដោយសរសេរអត្ថបទ « គួរចងចាំ » លើក្តារខៀន ។

**គួរចងចាំ** :

មានចំណោទខ្លះគេក៏ពុំអាចដោះស្រាយបានដែរ ពីព្រោះវាខ្វះព័ត៌មានដែលទាក់ទងទៅនឹងសំណួរ ក្នុងកាលៈទេសៈនេះ មុននឹងដោះស្រាយចំណោទ គេត្រូវរកព័ត៌មានដែលខ្វះនោះសិន ។

IV-**ចម្លើយ**

| អត្ថបទ | ព័ត៌មានដែលខ្វះ | បម្រាប់ជាលេខ | ដំណោះស្រាយ |
|---|---|---|---|
| រថយន្តដឹកទំនិញ............................ ...............មានប្រេងសាំងប៉ុន្មានលីត្រ? | ចំណុះប្រេងសាំងដែលគាត់ចាក់ | ១០០លីត្រ | ធុងប្រេងសាំងរថយន្តនោះមានចំណុះ ៩០ល+៥ល = ៩៥ល |

V- **កំណត់សម្គាល់**

ការសិក្សាសលាកប័ត្រនេះ បង្ហាញឱ្យសិស្សឃើញថា មានចំណោទខ្លះមិនអាចដោះស្រាយបានទេ ហើយចំណោទខ្លះទៀតមានចម្លើយច្រើន ។ដូច្នេះដើម្បីវាយតម្លៃទៅលើការយល់ដឹងរបស់សិស្សបាន លោកគ្រូអ្នកគ្រូត្រូវដាក់ចំណោទខាងក្រោមនេះឱ្យសិស្សធ្វើក្នុងថ្នាក់រៀន បន្ទាប់ពីការសិក្សាចំណោទគំរូមួយនេះ ។

<u>ចំណោទ</u> :

| អត្ថបទ | ព័ត៌មានដែលខ្វះ | បម្រាប់ជាលេខ | ដំណោះស្រាយ |
|---|---|---|---|
| សុខមានរូបភាពសត្វ៦៤សន្លឹក។ ដារាមានរូបភាពសត្វលើសសុខ។ តើដារានៅខ្វះរូបសត្វប៉ុន្មាន ដើម្បីយកទៅបិទក្នុងសៀវភៅកម្រងរូបភាពដែលអាចដាក់បាន២០០សន្លឹក ? | | | |
| បូណាមានប្រាក់ ៣២០០៛ ។ វាចង់ទិញសៀវភៅសរសេរ៥ក្បាលថ្លៃ៥០០៛ក្នុងមួយក្បាលៗ និងទិញប៊ិចមួយ។ តើបូណានៅសល់ប្រាក់ប៉ុន្មានរៀល? | | | |
| ពេលចេញលេង សេងលេងបាញ់ឃ្លីជាមួយមិត្តភក្តិវា។វាលេងចាញ់អស់១០គ្រាប់។ តើសេងនៅសល់គ្រាប់ឃ្លីប៉ុន្មានគ្រាប់ ? | | | |
| សុវណ្ណមានអាយុ៦ឆ្នាំច្រើនជាងប្អូនស្រីវា ។ តើប្អូនស្រីវាមានអាយុប៉ុន្មានឆ្នាំ? | | | |

ដកស្រង់ដោយលោកស្រី ប៊ុន សារ៉ន




# អ្នកបួស

(បទកាកគតិ)

១- តាំពីដូនតា ខ្មែរជឿសាសនា សមណគោតម
ព្រះអង្គនាំផ្លូវ ទៅឋានឧត្តម ប្រកាន់ក្រឹត្យក្រម
សាយសព្វទិសទី។

២- ខ្មែរឱ្យកូនបួស ជាព្រះសង្ឃព្រោះ តាមប្រពៃណី
បួសសងគុណម្តាយ ឪពុកទាំងទ្វេ ថែរក្សាកេរ្តិ៍
ព្រះពុទ្ធសាសនា ។

៣- គោរពព្រះធម៌ សាងអំពើល្អ ដោយកាយវាចា
លះបង់ឫកពាល សម្រួលឥរិយា តាមពុទ្ធដីកា
ប្រសើរក្សេមក្សាន្ត ។

៤- លះបង់មុសា អសុរោះវាចា លះបង់គ្រឿងញៀន
លះកិលេសកាម រំលោភបំពាន សម្លាប់បៀតបៀន
ចៀសផុតអន្តរាយ ។

៥- បួសសាងខ្លួនឯង បួសដោយសម្តែង សុទ្ធចិត្តនិងកាយ
មិនបួសព្រោះតែ វិបត្តិសោកស្តាយ ធម៌ជាសម្លាយ
ជីវិតថ្លៃថ្លា ។

៦- សម័យបុរាណ កូនប្រុសបួសបាន លើកឈ្មោះគ្រួសារ
ទាំងក្នុងពុទ្ធចក្រ អាណាចក្រលោកា ជាប្រទីបថ្លា
ឆ្លងផុតបាបគ្រោះ ។

៧- សម័យឥឡូវ កូនប្រុសត្រឹមត្រូវ ប្រសើរឥតមោះ
សុចរិតត្រង់ រស់ក្នុងកិត្តិយស មានបុណ្យស័ក្តិខ្ពស់
ព្រោះមានវិជ្ជា ។

៨-សូមថែរក្សា សម្រាំងឥរិយា ក្នុងផ្លូវត្រង់ជា
សម្មាជីវោ កុំឈ្នានីសគ្នា លះបង់ជួយគ្នា
សង្គមរុងរឿង ។

ទន់ សាអ៊ីម

# ពលរដ្ឋល្អ សិស្សល្អ កូនល្អ មិត្តល្អ ក្មេងល្អ

« បទពាក្យប្រាំពីរ »

១- បើយើងចង់ក្លាយពលរដ្ឋល្អ ត្រូវតែស្មោះសរគ្រប់ៗគ្នា
ពួកយើងរក្សានិងការពារ គ្រប់ពេលវេលាកុំបីខាន។
២- ចង់ក្លាយសិស្សល្អត្រូវមករៀន ស្តាប់ពាក្យទូន្មានកុំបីខាន
ស្តាប់គ្រូបង្រៀនគ្រប់ៗប្រាណ ទូន្មានប៉ុន្មានសុទ្ធតែល្អ។
៣- ពេលម្តាយឪពុកចាស់ជរា ជួយធ្វើការងារដោយស្មោះសរ
ពោលពាក្យទន់ភ្លន់និងធ្វើល្អ ទើបរូបយើងល្អគ្រប់ៗគ្នា។
៤- បើយើងចង់ក្លាយជាមិត្តល្អ ទឹកចិត្តស្មោះសរគ្រប់វេលា
ត្រូវខំសិក្សាកុំពាលា ពន្យល់ការងារដល់មិត្តភក្តិ។
៥- ពួកយើងសិក្សាដើម្បីជាតិ ខិតខំខ្មីឃ្មាតគ្រប់ៗអ្នក
ដូចទឹកអណ្តូងដែលត្រជាក់ ពួកយើងម្នាក់ៗត្រូវការពារ។
៦- បរិស្ថានយើងស្អាតជានិច្ច ប្រៀបដូចជាពេជ្រនិងសូត្រា
យើងជាកុមារណាពុំងា ពួកយើងគ្រប់គ្នាត្រូវរក្សា។
៧- ដូច្នេះពួកយើងកុំជក់ម៉ា មនុស្សទាំងឡាយណាកុំប្រាថ្នា
វាអាចសម្លាប់ដល់កុមារ ព្រោះថ្នាំនេះណាមិនល្អទេ។
៨- ពួកយើងរក្សាវប្បធម៌ខ្មែរ មិនត្រូវគេចកែយកជាតិគេ
ត្រូវស្រឡាញ់ជាតិខ្មែរកុំរេ ខ្មែរយើងបានផ្ទេរពីដូនតា។
៩- ទឹកដីខ្មែរយើងត្រូវរក្សា កេរ្តិ៍ពីដូនតាណារៀមរ៉ា
ពួកយើងគួរតែស្ថាបនា ជួយធ្វើកិច្ចការកុំអាក់ខាន។
១០- ពួកយើងគឺជាជនជាតិខ្មែរ រឹងមាំពូកែគ្រប់ៗប្រាណ
ធ្វើល្អត្រូវតែទទួលបាន ជាតិខ្មែរយើងថ្កានល្អប្រពៃ៕

និពន្ធដោយ កុមារី លី ស្រីពៅ អាយុ ១៣ ឆ្នាំ
រៀននៅ ថ្នាក់ទី ៥ « ក »សាលាបឋមសិក្សាអន្លង់វិល
ស្រុកសង្កែ ខេត្តបាត់ដំបង

✎📖✍

# សីលប្រាំខាយចាំមិនភ្លេច សីលប្រាំជានិច្ចអ្នកសាងកុសល

«បទកាកគតិ»

១- តើថ្ងៃណាទៅ ទើបបានកូនចៅ ភ្ញាក់ដឹងរូបា
កុំគិតតែដេក ផ្ទេចភ្នែកថ្នេះរ៉ា ត្រូវក្រោកហើយណា
សម្លឹងជ្រុងជ្រោយ។

២- រកផ្លូវទៅមុខ ក្រែងបានក្តីសុខ កូនកុំបណ្តោយ
ឱ្យហួសកន្លង នាំតែស្តាយក្រោយ គិតគូរឱ្យហើយ
ទើបមិនវេទនា។

៣- ផ្លូវនោះមានប្រាំ ចូរកូនចំណាំ ចាំឱ្យច្បាស់ថា
មានតែព្រះធម៌ អាចនាំអាត្មា តាមក្បួនតម្រា
ថាបានក្តីសុខ។

៤- ព្រះពុទ្ធទ្រង់ញាណ យាងចូលនិព្វាន បានបន្សល់ទុក
នូវពុទ្ធោវាទ ហាក់ក្តៅគគុក ដែលជាប្រមុខ
ឱ្យយើងចងចាំ។

៥- បញ្ចសីលា តាមខ្មែរភាសា ប្រែថាសីលប្រាំ
ជាពាក្យងាយស្រួល ក្នុងការចំណាំ តែភ្លេចបណ្តាំ
លែងខ្វីនឹកគិត។

៦- បាណាតិបាត កុំឱ្យប្រមាថ សត្វមានជីវិត
កុំប៉ុនកុំប៉ង កុំមានគំនិត ប្រល័យជីវិត
សត្វនោះឱ្យសោះ។

៧- រាល់អស់រូបា កើតមកហើយណា តែងតែចង់រស់
ទាំងយើងទាំងគេ ដូចគ្នាទាំងអស់ មិនថាទាបខ្ពស់
ធាត់ធំឬតូច។

៨- អទិន្នាទានា កុំបីបំពាន កុំប្លន់កុំលួច
កុំកេងប្រវ័ញ្ច នាំតែឱ្យខូច ទោះបីតិចតួច
ទ្រព្យអ្នកដទៃ។

៩- ទ្រព្យយើងទ្រព្យគេ រកមកហូរហៃ មិនថាយប់ថ្ងៃ
ដោយចេះគិតគូរ និងចេះលកលៃ ចេះទាំងសំចៃ
ទើបសល់ទុកបាន។

១០- បើគេមកប្លន់ លួចឆក់ទ្រព្យធន នាំឱ្យក្តៅប្រាណ
កុំចង់កាប់ចាក់ បកសងវិញថ្កាន នោះទើបខ្លួនបាន
រំងាប់កំហឹង ។

(នៅមានត)

ដកស្រង់ចេញពីសៀវភៅធម្មជីវិត (ព្រះមហា ម៉ាសុវិនវិសុទ្ធា)



# ពុទ្ធសាសនានិងសង្គមខ្មែរ

ពុទ្ធសាសនាបានផ្ដល់ប្រយោជន៍ឱ្យប្រជារាស្ត្រខ្មែរដ៏ត្រចះត្រចង់ ហើយប្រជារាស្ត្រក៏សុខចិត្តឱបពុទ្ធសាសនាយ៉ាងប្ដូរផ្ដាច់ ស៊ូស្លាប់មិនលះបង់ចោល ទោះបីជាមានអាសន្នអន្តរាយក្រដុនជាបយ៉ាងណាក៏ដោយ ។ ពុទ្ធសាសនាថេរវាទបានជ្រួតជ្រាបដល់ចិត្តថ្លើមប្រជាជនខ្មែរគ្រប់ជាន់គ្រប់ថ្នាក់ ទាំងស្ដេច នាម៉ឺនសព្វមុខមន្ត្រីទាំងរាស្ត្រក្រីក្រ កម្មករ អ្នកមានអ្នកក្រ ។ ខ្មែរមានច្បាប់ទម្លាប់ អក្សរសាស្ត្រ សិល្បៈ សីលធម៌ ដែលបានមកពីពាក្យប្រៀនប្រដៅនៃព្រះសម្មា-សម្ពុទ្ធ ដូចជាប្រជាជាតិភូមា សៀម ជប៉ុន ស្រីលង្កា កូរ៉េ ទីបេត៍ ។ ល ។ ដែរ ។ តាំងពីអតីតកាលមករហូតតឡូវ ប្រជារាស្ត្រខ្មែរតែងអប់រំកូនចៅតាមគន្លងពុទ្ធសាសនា ដូចជាឱ្យកូនចៅទៅរៀនឯវត្តជាដើម ។ កូនខ្មែរទោះជាព្រះរាជបុត្រក្ដី កូននាម៉ឺនមន្ត្រីក្ដីកូនអ្នកមានអ្នកក្រក្ដី តែងតែទទួលការសិក្សាអប់រំនៅក្នុងវត្ត ប៉ុន្តែសព្វថ្ងៃ កូនប្រុសមិនសូវបានបួសជាភិក្ខុសាមណេរដូចពីដើមទេ ព្រោះមានសាលាកើតនៅក្រៅវត្តច្រើនហើយ ។ ទោះបីយ៉ាងណាក៏នៅតែមានសិស្សច្រើនគ្នាណាស់ដែលត្រូវពឹងអាស្រ័យនៅក្នុងវត្តអារាម ។ សូម្បីយុវជនដែលអាស្រ័យនៅផ្ទះ ក៏តែងនាំគ្នាចូលវត្តដើម្បីប្រាស្រ័យទាក់ទងនឹងព្រះសង្ឃក្នុងការភ្ជាប់និស្ស័យខ្លួនទៅនឹងពុទ្ធសាសនា ។ វត្តអារាមជាមជ្ឈដ្ឋានអប់រំផ្លូវចិត្តផង ជាកន្លែងសម្រាប់ជួបជុំកិច្ចការសង្គមផង។ ប្រជារាស្ត្រខ្មែរតែងបបួលគ្នាជួបជុំនៅវត្ត ដើម្បីធ្វើបុណ្យទានខាងសាសនា ឬធ្វើបុណ្យប្រពៃណីជាតិជាដើម។ ការជួបជុំគ្នានៅវត្តនេះ ជាឱកាសល្អណាស់ សម្រាប់ឱ្យស្គាល់គ្នា ឱ្យចេះរួបរួមយោគយល់គ្នា ពិភាក្សាពិគ្រោះសន្ទនាគ្នា ដើម្បីដោះស្រាយកិច្ចការផ្សេងៗ មានសង្គមកិច្ច សេដ្ឋកិច្ច រដ្ឋាភិបាល ឬកិច្ចការគ្រួសារជាដើម ។

បុព្វបុរសខ្មែរបានបង្កើតទំនៀមទម្លាប់បុណ្យទានច្រើនយ៉ាងសម្រាប់អប់រំសង្គមជាតិខ្មែរឱ្យជាប់ជាមួយពុទ្ធសាស-នា ដូចបុណ្យកាន់បិណ្ឌ បុណ្យកឋិន បុណ្យផ្កា បុណ្យបំបួសនាគ បុណ្យស្រង់ព្រះ បុណ្យស្រោចស្រពមាតាបិតាចាស់ទុំជាដើម ។ សូម្បីបុណ្យខ្មោច ពិធីរៀបចំការកូនប្រុសកូនស្រី បុណ្យចូលឆ្នាំជាដើម ក៏ចាស់ទុំខ្មែរបញ្ចូលលទ្ធិពុទ្ធសាសនាទាំងអស់ ។

ព្រះពោធិវង្ស សូរ-ហាយ បានអធិប្បាយប្រយោជន៍ពុទ្ធសាសនាថា «គ្រប់ប្រទេសទាំងអស់ច្រើនតែទទួលថា សេចក្ដីចម្រើនក្នុងសិល្បៈវិទ្យាបានទទួលកំណើតពីសាសនា ។ អ្នកប្រាជ្ញប្រវត្តិសាស្ត្រប្រទេសជប៉ុន បានសរសេរទុកក្នុងប្រវត្តិសាស្ត្រថា ព្រះពុទ្ធសាសនា ជាសាសនានាំសេចក្ដីចំរើនមកឱ្យប្រទេសជប៉ុន ។ ពុទ្ធសាសនាបានបើកទ្វារប្រ-ទេសជប៉ុនដោយទ្រឹស្ដីមុនដំបូងបង្អស់ឱ្យប្រទេសជប៉ុនឈមមុខទៅរកសេចក្ដីចំរើនថ្កុំថ្កាន » ។

ពុទ្ធសាសនាទុកដូចជាគ្រឹះស្ថានឬជាមហាមន្ទីរនៃសិល្បៈ ទស្សនវិជ្ជា វិទ្យាសាស្ត្រនិងសីលធម៌ ។ មានអត្ថបទល្អៗច្រើនណាស់សម្រាប់យកទៅប្រតិបត្តិដើម្បីរំលត់ទុក្ខ នាំមកនូវសេចក្ដីសុខ ។ វត្តអារាមមិនមែនគ្រាន់តែជាទីប្រជុំធ្វើបុណ្យទានប៉ុណ្ណោះទេ គឺថែមទាំងជាមជ្ឈមណ្ឌលរៀនហត្ថកម្មក្នុងផ្លូវសិល្បៈ វប្បធម៌ ដូចជារៀនជាងសំណង់សង់វិហារ សាលា កុដិ ផ្ទះអ្នកស្រុកជាដើម ។ កាលប្រទេសកម្ពុជាពុំទាន់មានសាលារៀនជាផ្លូវរដ្ឋនៅឡើយ មានតែវត្តហ្នឹងឯង ជាសាលារៀន ។ កាលពីបុរាណ ប្រជារាស្ត្រខ្មែរនាំគ្នាហាត់វិជ្ជាការពារខ្លួននៅក្នុងវត្ត ជួនកាលព្រះសង្ឃជាគ្រូបង្ហាត់គុន

ដំបង គុនដាវ គុនខែល ឬសិល្បៈចំបាប់ ។ល។ កាលមិនទាន់មានមន្ទីរពេទ្យនៅឡើយ វត្តអារាមជាមន្ទីរពេទ្យមើលជំងឺប្រជារាស្ត្រ មើលទាំងជំងឺកាយទាំងជំងឺចិត្ត។ ដូច្នេះ វត្តជួយរដ្ឋាភិបាលបានយ៉ាងច្រើន ក្នុងការជួយថវិកាជាតិ ដែលត្រូវចំណាយទៅលើក្រសួងសុខាភិបាលជាតិ និងក្រសួងអប់រំជាតិ ។

ក្រុងភ្នំពេញជារាជធានីនៃប្រទេសកម្ពុជា មានវត្តអារាមធំៗ គឺវត្តឧណ្ណាលោម វត្តលង្កា វត្តសារាវ័ន្ត វត្តបទុមវតីជាដើម ជាទីទទួលបន្ទុកនៃពួកភិក្ខុសាមណេរ និងកុមារតូចធំបានច្រើនណាស់ ។ វត្តនីមួយៗ មានភិក្ខុសាមណេរសិស្ស និស្សិត ដែលចេញមកពីស្រុកខេត្តនានា មកនៅបញ្ចុះជ្រំជាមួយគ្នា ដើម្បីសិក្សារៀនសូត្រយកចំណេះវិជ្ជាទៅប្រកបវិជ្ជាជីវៈចិញ្ចឹមគ្រួសារ ។ មិនថាតែវត្តធំៗនៅក្រុងភ្នំពេញទេ សូម្បីវត្តនៅទីប្រជុំខេត្តនានាក៏ទទួលបន្ទុកជួយយុវជនដូចគ្នា ។ ពួកភិក្ខុដែលមកនៅក្នុងវត្តទាំងនោះ លុះយូរបន្តិចទៅ ក៏មានសមត្ថភាពគ្រាន់បើបានធ្វើជាមេកុដិ អាចទទួលចិញ្ចឹមភិក្ខុ សាមណេរនិងយុវជនឱ្យនៅរៀនសូត្រទាល់តែសម្រេចការសិក្សា ។ ពួកសិស្សនិស្សិតដែលមកនៅអាស្រ័យជ្រកកោនក្នុងវត្តអារាមនោះ ភាគច្រើនជាកូនអ្នកស្រែចំការ ដែលទាល់ក្រទ្រព្យធន។ គួរឱ្យអាណិតអាសូរពួកយុវជនដ៏កំសត់ទាំងនេះពន់ពេក បើកុំតែមានវត្តព្រះពុទ្ធសាសនាជាទីជ្រកកោន ប្រហែលជាមិនបានទទួលស្មើការសិក្សាដូចកូនអ្នកមានទ្រព្យទេ ប្រែសេចក្តីថា « កូនអ្នកក្រជនជានរស់រានដោយសារបាយវត្ត » ខំទ្រាំទាំងវេទនាបំពេញការសិក្សារហូតសម្រេចផល ខ្លះបាន ទទួលបុណ្យសក្តិជាមន្ត្រីសេនាបតី ខ្លះទៅជាអ្នកមានជីវភាពខ្ពង់ខ្ពស់តាមសមគួរដល់សមត្ថភាពរបស់ខ្លួន។

កូនចៅអ្នកក្រីក្របានទទួលសេចក្តីសង្គ្រោះអំពីបព្វជិតពុទ្ធសាសនិកក្នុងឆ្នាំនីមួយៗមានចំនួនច្រើននាក់ណាស់ ដូចយ៉ាងវត្តធំៗមានកុមារចំនួន ៣០០ឬ៤០០នាក់។ ចំនួនពួកកុមារទាំងនោះ បើទោះជារដ្ឋាភិបាលទទួលយកទៅចិញ្ចឹមវិញអស់ប្រាក់ថវិកាជាតិមិនតិចទេ ។ ដូច្នេះ វត្តពុទ្ធសាសនាឈ្មោះថាបានជួយសម្រាលភារៈរដ្ឋាភិបាលឱ្យធូរស្រាលបានច្រើនដែរ ព្រមទាំងជួយសង្គ្រោះកូនចៅអ្នកក្រីក្រដែលឥតលំនៅជ្រកកោន និងអាហារបរិភោគនោះបានច្រើនណាស់ ។ ម្លឹងហើយនៅតែមានពាក្យរិះគន់រករឿងដោយស្អប់ថា វត្តជាកន្លែងចិញ្ចឹមឈ្លើង ព្រះសង្ឃជាឈ្លើងជាពួនជញ្ជក់ឈាមរាស្ត្រ ។

បព្វជិតពុទ្ធសាសនាមានចៅអធិការ គ្រូសូត្រជាដើម ជាអ្នកសង្វាតខ្នះខ្នែងក្នុងការដឹកនាំអ្នកជើងវត្ត ឱ្យកសាងសាលារៀន និងមន្ទីរពេទ្យនៅគ្រប់ស្រុកខេត្តខណ្ឌ រួចហើយប្រគល់ជូនស្ថាប័នទាំងនោះទៅរដ្ឋាភិបាល សុំឱ្យចាត់ការរកគ្រូបង្រៀនតាមផ្លូវការ ។ សាលារៀននៅប្រទេសខ្មែរ ភាគច្រើនកើតឡើងដោយការប្រឹងប្រែងរបស់ព្រះសង្ឃ ។

វត្តអារាម ឈ្មោះថាជាកន្លែងសម្រាប់ថែរក្សាអក្សរសាស្ត្រ សិល្បៈ វប្បធម៌ សាមគ្គីធម៌របស់ប្រទេសជាតិ។ គេសង្កេតឃើញថា គម្ពីរតម្រាក្បួនច្បាប់ផ្លូវលោកក្តីផ្លូវធម៌ក្តី ដែលប្រទេសខ្មែរយើងមានតាំងពីបុរាណរហូតឥឡូវ ច្រើនតែចេញមកពីទ្រឹស្តីព្រះពុទ្ធសាសនា ដែលមានបព្វជិតឬគ្រហស្ថដែលជិតដិតនឹងវត្ត ជាអ្នកសរសេរចងក្រងឡើង សម្រាប់ជាវត្តប្រតិបត្តិនៃពុទ្ធសាសនិកជន ។

(នៅមានត)

រៀបរៀងដោយ សោម ងន
ដកស្រង់ពីសៀវភៅពន្លឺពុទ្ធសាសនា

« *របស់ឬានទទេ គឺចាស់ជរា*
*របស់ប្រឹងរកគ្រប់គ្នា គឺគុណតម្លៃនៃជីវិត ។* »

*សៀវភៅ៤៨ធម្មទស្សន៍*

# ឋានានុក្រមបព្វជិតពុទ្ធសាសនាខ្មែរ

ព្រះរាជា ជាប្រមុខមួយអង្គគត់នៃព្រះសង្ឃខ្មែរទាំងមូល ។

និកាយនីមួយៗ ក្នុងបណ្ដានិកាយទាំងពីរ មាននាយកផ្ទាល់របស់ខ្លួន ដែលហៅថាសង្ឃនាយក ។ នាយកនៃនិកាយទាំងពីរ មិនចំណុះគ្នាទៅវិញទៅមកទេ នាយកនីមួយៗយកព្រះទ័យទុកដាក់តែចំពោះព្រះសង្ឃ និងវត្តនៃគណៈរបស់ខ្លួន ។

នាយកនៃនិកាយទាំងពីរ ត្រូវបានតែងតាំងឡើងដោយព្រះរាជា ។ព្រះអង្គបានជ្រើសរើសនាយកទាំងពីរក្នុងបណ្ដាមន្ត្រីសង្ឃជាន់ខ្ពស់ថ្នាក់ទាំងពីរ ។

មន្ត្រីសង្ឃត្រូវបានចាត់ថ្នាក់ជាបួនក្រុម ហៅថា រាជាគណៈ ។ ការដំឡើងស័ក្តិយសដល់ឋានៈរាជាគណៈ ត្រូវរក្សាទុកថ្វាយព្រះមហាក្សត្រជាអ្នកសម្រេច យោងតាមសេចក្ដីស្នើសុំរបស់ព្រះសង្ឃនាយកនៃនិកាយទាំងពីរ និងពីយោបល់របស់មន្ត្រីក្រសួងធម្មការ ។

ថ្នាក់រាជាគណៈនីមួយៗ ត្រូវបានជ្រើសរើសក្នុងក្រុមបន្ទាប់ខាងក្រោម ។

ដើម្បីអាចតែងតាំងភិក្ខុអង្គណាមួយឱ្យមានមុខងារ ជារាជាគណៈថ្នាក់ចត្វាបាន ភិក្ខុអង្គនោះ ត្រូវមានអាយុផ្នួសយ៉ាងតិច ២០វស្សា(ឆ្នាំបួស) (វស្សា មកពីពាក្យបាលីថាវស្សៈ ភ្លៀង អាយុផ្នួសត្រូវគេគិតតាមរដូវភ្លៀង) ។

ការដំឡើងកិត្តិយសទីឋានានុក្រម ត្រូវរក្សាទុកថ្វាយព្រះសង្ឃនាយកនៃនិកាយសាមីជាអ្នកសម្រេច ដោយមានសេចក្ដីយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា។

## ងារនៃមន្ត្រីសង្ឃ

នៅក្នុងនិកាយនីមួយៗក្រុមនីមួយៗនៃរាជាគណៈមានចំនួនមន្ត្រីសង្ឃជាអ្នកកំណត់ ហើយមានមុខងារផ្សេងៗគ្នា ប៉ុន្តែមានឋានៈស្មើគ្នាទៅវិញទៅមក។

ក្រុមដែលខ្ពស់ជាងគេ ពោលគឺក្រុមទីមួយ(ហៅថា ថ្នាក់ឯក) មានសមាជិកបីរូប សម្រាប់គណៈមហានិកាយនិងមានតែសមាជិក២រូបសម្រាប់គណៈធម្មយុត្តិ ។

## ងាររបស់គណៈទាំងពីររៀងៗខ្លួនមានដូចតទៅ

| មហានិកាយ | ធម្មយុត្តិ |
|---|---|
| ១. ព្រះធម្មលិខិត | ១. ព្រះមង្គលទេពាចារ្យ |
| ២. ព្រះពោធិវង្ស | ២. ព្រះពុទ្ធាចារ្យ |
| ៣. ព្រះវនរ័ត្ន | |

រាជានៃក្រុមទីពីរ(ហៅថា ថ្នាក់ទោ)មានចំនួនសមាជិកចំនួនប្រាំមួយរូបសម្រាប់គណៈមហានិកាយ និងសមា ជិកបីរូបសម្រាប់គណៈធម្មយុត្តិ ៖

| មហានិកាយ | ធម្មយុត្តិ |
|---|---|
| ១. ព្រះមហាវិមលធម្ម | ១. ព្រះមហាព្រហ្មមុនី |
| ២. ព្រះពុទ្ធឃោសាចារ្យ | ២. ព្រះធម្មឧត្តម |
| ៣. ព្រះធម្មឃោសាចារ្យ | ៣. ព្រះអរិយកស្សប |
| ៤. ព្រះឃោសធម្ម | |
| ៥. ព្រះសាសនមុនី | |
| ៦. ព្រះមុនីកុសល | |

រាជាគណៈក្រុមទីបី (ហៅថា ថ្នាក់ត្រី) មានចំនួនសមាជិកប្រាំមួយរូប សម្រាប់មហានិកាយ និងមានសមាជិកបួនរូបសម្រាប់ធម្មយុត្តិ ៖

| មហានិកាយ | ធម្មយុត្តិ |
|---|---|
| ១. ព្រះសិរីសម្មតិវង្ស | ១. ព្រះអរិយវង្ស |
| ២. ព្រះពុទ្ធវង្ស | ២. ព្រះញាណវង្ស |
| ៣. ព្រះសាក្យវង្ស | ៣. ព្រះធម្មកវីវង្ស |
| ៤. ព្រះឧបាលិវង្ស | ៤. ព្រះមហាវីរវង្សាចារ្យ |
| ៥. ព្រះញាណវង្ស(ថ្មី) | |
| ៦. ព្រះសុមេធវង្ស (ថ្មី) | |

រាជាគណៈនៃក្រុមទីបួន (ហៅថា ថ្នាក់ចត្វា) មានចំនួនសមាជិកម្ភៃរូបសម្រាប់គណៈមហានិកាយ និងមានសមាជិកចំនួនដប់ពីររូបសម្រាប់គណៈធម្មយុត្តិ ៖

| មហានិកាយ | | ធម្មយុត្តិ |
|---|---|---|
| ១. ព្រះធម្មវិបស្សនា | ១១.ព្រះវិន័យមុនី | ១. ព្រះបទុមវង្ស |
| ២. ព្រះសម្មាធិធម្ម | ១២.ព្រះទេពសត្ថា | ២. ព្រះធម្មមុនី |
| ៣. ព្រះញាណកោសល | ១៣.ព្រះសីលសំវរៈ | ៣. ព្រះជីវមេធា |
| ៤. ព្រះសិរីសង្គាមមុនី | ១៤.ព្រះគម្ពីរត្ថេរ | ៤.ព្រះអរិយមុនី |
| ៥. ព្រះសិរីសុទ្ធី | ១៥.ព្រះអរិយមគ្គញាណ | ៥. ព្រះទេពមោលី |
| ៦. ព្រះធម្មវង្សា | ១៦. ព្រះវិកទ្ធញាណ | ៦. ព្រះធម្មត្ថេរ |
| ៧. ព្រះញាណសំវរៈ | ១៧.ព្រះបវរសត្ថា | ៧. ព្រះអមរាភិរក្ខិត |
| ៨. ព្រះធម្មសំវរៈ | ១៨. ព្រះញាណវិសុទ្ធិវង្ស | ៨. ព្រះមហារាជធម្ម |
| ៩.ព្រះឥន្ទមុនី | ១៩.ព្រះធម្មវិសុទ្ធិវង្ស | ៩. ព្រះរតនៈមុនី |
| ១០.ព្រះទេពមុនី | ២០.ព្រះបិដកធម្ម | ១០.ព្រះធម្មត្រ័យលោកាចារ្យ |
| | | ១១.ព្រះធម្មវរោត្តម |
| | | ១២.ព្រះញាណវិរិយៈ |

ឋានានុក្រម ក៏ជាឋានៈក្រោមបន្ទាប់នៃឋានៈរបស់ក្រុមក្រោមគេ (ហៅថា ថ្នាក់ចត្វា) នៃរាជាគណៈ មានងារហៅថាព្រះគ្រូ, បាឡាត់ , វិន័យធម្ម , វិន័យធរ , សមុហ៍ , បៃដិការ(ងារសៀម) និងលេខាធិការ ។ ពួកនេះត្រូវបានសម្ដេចសង្ឃនាយកតែងតាំង ដោយសេចក្ដីយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការ ។ (នៅមានត)

**លោក គួយ សុគាន**

*បណ្ឌិតរមែងជាអ្នកស្គាល់កាល ។*

*ពុទ្ធសុភាសិត*

ទំព័រស្ត្រី

# គោលនយោបាយស្ដីពីមេរោគអេដស៍ និងជំងឺអេដស៍នៅកន្លែងធ្វើការ (តចប់)

**៤.អត្ថប្រយោជន៍ជាកាតព្វកិច្ច**

ក. បុគ្គលិកដែលមានផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍គួរទទួលបានការការពារពីសង្គម រួមមានអត្ថប្រយោជន៍សុវត្ថិភាពសង្គម ស្របតាមច្បាប់ជាតិ បទបញ្ញត្តិសេវាអប់រំ ឬច្បាប់របស់ស្ថាប័នអប់រំ ដូចជាបុគ្គលិកដែលមានជំងឺរ៉ាំរ៉ៃឬជំងឺធ្ងន់ធ្ងរផ្សេងៗដែរ។

ខ. ក្រសួងនឹងរក្សាការបើកប្រាក់បៀវត្សរ៍ពេញលេញជូនបុគ្គលិកទាំងអស់ដែលមានផ្ទុកមេរោគអេដស៍ ដរាបណាមានការបញ្ជាក់ពីគ្រូពេទ្យជំនាញថា បុគ្គលនោះមានសុខភាពគ្រប់គ្រាន់សម្រាប់ធ្វើការងារ ។ តាមរយៈការពិភាក្សាជាមួយបុគ្គលិក និងតំណាងរបស់បុគ្គលិក ថ្នាក់ដឹកនាំនឹងសម្រួល និងកាត់បន្ថយបន្ទុកការងាររបស់បុគ្គលិក ដែលចាំបាច់ ក៏ដូចជាជំងឺ ឬពិការភាពផ្សេងៗ ឱ្យនៅត្រឹមកម្រិតណាមួយដែលបុគ្គលនោះធ្វើទៅបានសម្រាប់ក្រសួង ឬកន្លែងធ្វើការងារផ្សេងទៀត ដោយរក្សាការសម្ងាត់ប្រកបដោយប្រសិទ្ធភាពខ្ពស់។

គ. ក្រសួងនឹងបង្កើតគោលការណ៍ណែនាំជាក់លាក់មួយ ស្ដីពីការបញ្ឈប់បុគ្គលិកដែលមិនអាចធ្វើការបាន បន្ទាប់ពីពេលនៃការអនុញ្ញាត ឱ្យឈប់សម្រាកដោយសារជំងឺ។

ឃ. ក្រសួងនឹងធានាថា បុគ្គលិកដែលមានការទទួលខុសត្រូវក្នុងការថែទាំគ្រួសារមានផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ជាពិសេសបុគ្គលិកស្ត្រី ត្រូវទទួលបានការគាំទ្រ និងផ្ដល់ការងារសមស្រប ដែលអាចឱ្យបុគ្គលិកស្ត្រីមានលទ្ធភាពមើលថែទាំក្រុមគ្រួសាររបស់ខ្លួន។

ង. ក្រសួងនឹងគាំទ្របុគ្គលិកឱ្យមានលទ្ធភាពធ្វើតេសឈាមរកមេរោគអេដស៍ ការព្យាបាលដោយថ្នាំពន្យារជីវិតក្នុងការព្យាបាល និងការព្យាបាលឥតគិតថ្លៃ តាមរយៈទំនាក់ទំនងរវាងអ្នកផ្ដល់សេវាថែទាំ និងសុខភាពរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល នៅថ្នាក់មូលដ្ឋាន នៅពេលអាចធ្វើការបាន ។ ក្រសួងផ្ដល់ជំនួយផ្សេងៗ ដូចជា ពេលវេលាឈប់សម្រាកលិខិតបទដ្ឋាននានា និងឧបត្ថម្ភផ្សេងៗតាមគោលការណ៍កំណត់ ។

២.៩. ភាពខុសគ្នានិងសមភាពយេនឌ័រ

ដោយមានការទទួលស្គាល់ថា បុរស និងស្ត្រីមានជីវសាស្ត្រខុសគ្នា ហើយស្ត្រីងាយរងគ្រោះក្នុងការឆ្លងមេរោគអេដស៍ជាងបុរស ស្ត្រីអាចត្រូវការចាំបាច់នូវការគាំទ្រក្នុងការទាមទារសិទ្ធិក្នុងការរួមភេទប្រកបដោយសុវត្ថិភាព ហើយជារឿយៗស្ត្រីជួបឧបសគ្គដ៏ធំធេងពីការមាក់ងាយ ការបាត់បង់កិត្តិយស និងការទទួលខុសត្រូវក្នុងគ្រួសារច្រើនជាងបុរសនោះ ក្រសួងនឹង ៖

**១. ធានាថា**ការបណ្ដុះបណ្ដាលបុគ្គលិកមានបញ្ចូលការយល់ដឹងអំពីយេនឌ័រ ការលើកកម្ពស់ និងការគាំទ្រសិទ្ធិស្មើគ្នា សម្រាប់ស្ត្រីនិងការបង្កើតនីតិវិធីសម្រាប់ដោះស្រាយការបៀតបៀនផ្លូវភេទ នៅក្នុងនិងក្រៅកន្លែងធ្វើការ ។

**២. ធានាថា** អ្នកគ្រូនិងបុគ្គលិកផ្សេងទៀតទទួលបានការបណ្ដុះបណ្ដាលអំពីសុខភាពបន្តពូជ និងមានការរៀបចំផ្ដល់ការអប់រំអំពីផ្លូវភេទ និងសុខភាពបន្តពូជដល់យុវតីក្នុងនិងក្រៅសាលារៀន ក្នុងស្ថានភាពមួយដែលយុវតីពេញចិត្តទទួលការរៀនសូត្រពីបុគ្គលិកនារី។

២.១០. ការទទួលខុសត្រូវរបស់បុគ្គលិកសិក្សា និងក្រសួងចំពោះកុមារកំព្រា និងងាយរងគ្រោះព្រមទាំងក្រុមគ្រួសារ

ដោយមានការទទួលស្គាល់ថា កុមារកំព្រានិងងាយរងគ្រោះ ជារឿយៗមិនបានសិក្សា ដោយសារបន្ទុករកប្រាក់ចំណូលសម្រាប់តម្រូវការជីវភាពរស់នៅប្រចាំថ្ងៃ ក្រសួង ៖

១. ធានាថា កុមារទាំងអស់មានសិទ្ធិទទួលបានការអប់រំដោយមិនគិតថ្លៃក្រោមច្បាប់កម្ពុជា។

២. ធានាថា ឱ្យបុគ្គលិកជ្រើសរើសកុមារកំព្រានិងងាយរងគ្រោះដើម្បីផ្ដល់អាហាររូបករណ៍ ដូចគ្នានឹងសិស្សានុសិស្សទាំងអស់ដែលត្រូវការជំនួយ ដើម្បីបន្តការសិក្សារហូតដល់កម្រិតមួយខ្ពស់បំផុតទៅតាមលទ្ធភាពរបស់គេ រួមទាំងការសិក្សានៅសាកលវិទ្យាល័យ។

៣. ស្នើឱ្យបុគ្គលិកជួយកុមារកំព្រា និងងាយរងគ្រោះ ដើម្បីទទួលបានការគាំទ្រពីអ្នកផ្ដល់ជំនួយជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសេវាចិញ្ចឹមនានា។

៤. ចាត់វិធានការដែលអាចធ្វើទៅបានទាំងអស់ ដើម្បីបញ្ចៀសការបោះបង់ចោលសាលារៀនរបស់កុមារ តាមរយៈគោលការណ៍គាំទ្រសមស្រប។

២.១១. ការរើសអើង និងការមាក់ងាយ

ដោយមានការទទួលស្គាល់ថា ក្រៅពីការខិតខំប្រឹងប្រែងយ៉ាងខ្លាំងពីកម្មវិធីរបស់រាជរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ និង អង្គការមិនមែនរដ្ឋាភិបាល ក្នុងការកាត់បន្ថយការមាក់ងាយ និងការរើសអើង អ្នកផ្ទុកមេរោគអេដស៍ ក្នុងចំណោមប្រជាជនភាគច្រើន ក្រសួងនឹង ៖

១. មិនអត់ឱនឱ្យបុគ្គលិក ដែលមានការរើសអើងចំពោះសហការី យុវជន ឬគ្រួសាររបស់គេ ហើយផ្ដល់ការប្រើប្រាស់ជាប់លាប់ដល់បុគ្គលិកនោះឱ្យមានការផ្លាស់ប្ដូរឥរិយាបថនិងការប្រព្រឹត្តរបស់ខ្លួន។ ក្នុងករណីនៅតែមានការរើសអើង មិនព្រមឈប់ ក្រសួងនឹងដាក់ពិន័យរដ្ឋបាលតាមគោលការណ៍កំណត់។

២.បញ្ចូលក្នុងវគ្គបណ្ដុះបណ្ដាល និងវគ្គបំប៉ននូវការមាក់ងាយ និងការរើសអើងសម្រាប់បុគ្គលិកអប់រំ ។

« ហាមដាច់ខាតដល់ជនណាម្នាក់តាមបែបណាមួយគិតពីមុន និងក្រោយពេលឱ្យចូលបំរើការងាររួមទាំងការជួល ការដំឡើងឋានន្តរសក្តិ ការចាត់ឱ្យបំពេញការងារ ការរួមរស់ក្នុងសង្គម ដោយផ្អែកលើការដឹងឬសង្ស័យថា ជននោះឬក្រុមគ្រួសាររបស់ជននោះមានមេរោគអេដស៍/ជម្ងឺអេដស៍ (HIV/AIDS) ។ ត្រូវចាត់ទុកថាខុសច្បាប់ រាល់ការបញ្ឈប់ពីការងារចំពោះជនណាម្នាក់ដោយផ្អែកលើការដឹងឬសង្ស័យថាជននោះឬក្រុមគ្រួសារនោះមានផ្ទុកមេរោគ អេដស៍/ជំងឺអេដស៍ (HIV/AIDS) » ។ (ច្បាប់ស្ដីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍និងជម្ងឺអេដស៍ជំពូកទី៨ មាត្រា៣៦) ។

២.១២.ការសហការ និងការត្រួតពិនិត្យ

ដោយមានការទទួលស្គាល់ថា មេរោគអេដស៍និងជម្ងឺអេដស៍ ជាបញ្ហារួមរបស់ក្រសួង[3]ប៉ុន្តែដោយយថាហេតុធនធាននៅមានកម្រិតសម្រាប់ការគាំទ្រឱ្យបានទូលំទូលាយដល់ការដោះស្រាយបញ្ហារួមទាំងនេះ ការអនុវត្តគោលនយោបាយស្ដីពីមេរោគអេដស៍នៅកន្លែងធ្វើការនឹងផ្អែកលើសកម្មភាពដូចខាងក្រោម ៖

ក. សហការក្នុងការបង្កើតផែនការសកម្មភាពទាំងអស់សម្រាប់ការអនុវត្តគោលនយោបាយស្ដីពីមេរោគអេដស៍ជាមួយអ្នកផ្ទុកមេរោគអេដស៍អ្នកជំងឺអេដស៍ បុគ្គលិកក្នុងវិស័យអប់រំ និងតំណាងរបស់គេ ។

ខ. គ្រប់ស្ថាប័ន និងនាយកដ្ឋាន មន្ទីរអប់រំទាំងអស់របស់ក្រសួងត្រូវចាត់តាំងបុគ្គលិកទំនាក់ទំនងម្នាក់(ឬគណៈកម្មការសម្រាប់ក្រុមធំ)ដើម្បីសម្របសម្រួលដល់ការបង្កើតផែនការសកម្មភាពនាយកដ្ឋានដើម្បីអនុវត្តគោលនយោបាយ។

គ. នាយកដ្ឋានបុគ្គលិកត្រូវទទួលបន្ទុកមើលការខុសត្រូវក្នុងការអនុវត្តនយោបាយនិងតាមដានត្រួតពិនិត្យ ដោយផ្អែកតាមគោលដៅ និងអាំងឌីកាទ័រ។ គោលដៅនិងអាំងឌីកាទ័រទាំងនេះនឹងត្រូវបង្កើត ពិគ្រោះ ពិភាក្សា និងមានការឯកភាពយល់ព្រមពីនាយកដ្ឋាននានា តាមរយៈគណៈកម្មាធិការអន្តរនាយកដ្ឋានប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលមានតួនាទីជាអ្នកសម្របសម្រួល។

---

[3]ផែនការយុទ្ធសាស្ត្រអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ( ឆ្នាំ ២០០៦- ២០១០)

**ឃ.** នាយកដ្ឋានសុខភាពសិក្សាត្រូវសហការជាមួយនាយកដ្ឋានពាក់ព័ន្ធផ្សេងៗ ដើម្បីបង្កើត និង ផ្ដល់វគ្គបណ្ដុះបណ្ដាលស្ដីពីមេរោគអេដស៍ និងជំងឺអេដស៍ដល់មន្ត្រី បុគ្គលិក នៅពេលដែលវគ្គបណ្ដុះបណ្ដាលទាំងនោះត្រូវបន្ថែមទៅក្នុងកម្មវិធីសិក្សាដែលមានស្រាប់ សម្រាប់គ្រូបង្រៀន។

**ង.** ផលប្រយោជន៍នានានឹងផ្ដល់ជូនបុគ្គលិក បន្ទាប់ពីមានការបញ្ជាក់ពីតាមរយៈលិខិតបញ្ជាក់វេជ្ជសាស្ត្រ ដែលនៅមានសុពលភាព និងមិនឱ្យមានការពន្យារពេល ដែលបណ្ដាលឱ្យជំងឺកាន់តែមានភាពលំបាកថែមទៀត។

« រដ្ឋត្រូវបង្កើតកម្មវិធីតាមដានត្រួតពិនិត្យមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ទូលំទូលាយមួយដើម្បីកំណត់ទំហំ ភាពងាយប្រឈមនឹងគ្រោះថ្នាក់របស់ប្រជាពលរដ្ឋ ការប្រព្រឹត្តរួមភេទនិងការរាលដាលមេរោគ អេដស៍ / ជំងឺអេដស៍ (HIV/ AIDS ) ។

កម្មវិធីនេះមានគោលបំណងផ្ទៀងផ្ទាត់ វាយតម្លៃពីភាពគ្រប់គ្រាន់ ប្រសិទ្ធភាព និង និរន្តភាពនៃវិធានការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS)នៅក្នុងប្រទេស »។ (ច្បាប់ស្ដីពីការ បង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និង ជម្ងឺអេដស៍ ជំពូកទី៦ មាត្រា៣០) ។

**ដកស្រង់ដោយលោក វ៉ែន គុណ**

## អក្ខរាវិរុទ្ធនិងអំណាន

គណៈកម្មការអក្ខរាវិរុទ្ធនិងអំណាននៃ ក.ជ.ភ.ខ. បានស្នើមក ក.ជ.ភ.ខ.ឱ្យកំណត់សូរអាននៃពាក្យ «កម្ពុជា» «នាយកដ្ឋាន» «ប្រពៃណី» និងពាក្យដែលមាន «ទស្ស / - ទស្សន៍ » ទាំងអស់ ។

ក្រោយពីបានជជែក ពិភាក្សា ផ្ដល់យោបល់គ្នាទៅវិញទៅមកយ៉ាងល្អិតល្អន់ទៅលើសំណើរបស់គណៈកម្មការនេះ រួចមក អង្គប្រជុំរបស់ក.ជ.ភ.ខ.បានអនុម័តដូចតទៅ ៖

១. ពាក្យ «កម្ពុជា» យើងអានថា [ កាំពុ ជា ]

២. ពាក្យ «នាយកដ្ឋាន » យើងអានថា [ នា យក់ ក្ឋាន ]

៣. ពាក្យ «ប្រពៃណី» យើងអានថា [ ប្រ ពៃ នី ]

៤. ពាក្យដែលមាន «ទស្ស / ទស្សន៍ » ទាំងអស់យើងអានថា [ -ទស់ / -ទស់ ]

ឧទាហរណ៍ ៖

ពាក្យ «ទស្សនៈ» យើងអានថា [ ទស់ សៈ ន់ៈ ]

«ទស្សន៍ទាយ» យើងអានថា [ ទស់ ទាយ ]

«ទស្សនីយភាព» យើងអានថា [ ទស់ សៈ នី យៈ ភាព ]

ពាក្យ «ទូរទស្សន៍» យើងអានថា [ ទូ រៈ ទស់ ]

«សោតទស្សន៍» យើងអានថា [ សោ តៈ ទស់ ] ... ។

ព្រឹត្តិប័ត្រ ក្រុមប្រឹក្សាជាតិភាសាខ្មែរ លេខ៥ ឆ្នាំ ២០១៣

# អំពីសករាជ

តាមវចនានុក្រមសម្តេច ជួន ណាត ពាក្យសករាជមានន័យថា ការរាប់ថ្ងៃ ខែ ឆ្នាំ ឬការរាប់ត្រឹមឆ្នាំតាមកាលកំណត់ដែលតាំងទុកពីមួយរៀងមក ដោយមានបុគ្គលអស្ចារ្យ ឬដោយមានហេតុអស្ចារ្យណាមួយដែលពួកជនានុជនអ្នកគោរពត្រូវកត់ត្រាទុកមិនឱ្យបាត់ ត្រូវប្រើក្នុងសំបុត្រចុតហ្មាយជាដើម បង្កើនមួយលេខរៀងរាល់ឆ្នាំ។

សករាជដែលខ្មែរយើងធ្លាប់ប្រើប្រាស់មាន ៥ ៖

១-បុរាណសករាជ (ប.ស.) ២-ពុទ្ធសករាជ (ព.ស.) ៣-គ្រិស្តសករាជ (គ.ស.)

៤-មហាសករាជ (ម.ស.) ៥-ចុល្លសករាជ (ច.ស.)

១. បុរាណសករាជ ៖ ជាសករាជយូរលង់ជាងគេ ហើយហៅយ៉ាងនេះ ព្រោះពុំមានឈ្មោះពិតប្រាកដណាមួយសម្រាប់ហៅ។ ព្រះពុទ្ធទ្រង់ប្រសូតនៅប.ស.១២ ហើយទ្រង់បរិនិព្វាននៅប.ស. ៩១។ បុរាណសករាជតាំងពីមុនគ្រិស្តសករាជ ៦៣៤ឆ្នាំ។

២. ពុទ្ធសករាជ ៖ ព្រះពុទ្ធទ្រង់បរិនិព្វាននៅប.ស.៩១ ថ្ងៃអង្គារ ១៥កើត ខែពិសាខ ឆ្នាំម្សាញ់នព្វស័ក។ ពុទ្ធសករាជរាប់ចាប់ពីថ្ងៃ ១រោច ខែពិសាខ ឆ្នាំ ម្សាញ់នព្វស័ក ប.ស.៩១ នោះរហូតមក។ ពុទ្ធសករាជតាំងពីមុនគ្រិស្តសករាជ ៥៤៤ឆ្នាំ។

៣. គ្រិស្តសករាជ ៖ ព្រះយេស៊ូ (ហេស៊ូហ្ស៊ុយគ្រិស្ត) នាមសាស្តាអ្នកបង្កើតលទ្ធិ ឬសាសនាក្រេដែន ឬគ្រិស្ត កើតក្នុងរវាងព.ស.៥៤៥ ឆ្នាំរកា ត្រីស័ក និងទទួលមរណភាពក្នុងកាលព.ស.៥៧៤ ឆ្នាំខាល ទោស័ក ក្នុងអាយុគម្រប់៣០ឆ្នាំ។ គ្រិស្តសករាជ រាប់ចាប់ពីឆ្នាំកំណើតព្រះយេស៊ូតមក។

៤.មហាសករាជ ៖ មហាសករាជតាំងនៅប.ស.៧១៣ ត្រូវនឹងព.ស.៦២៣ ថ្ងៃឡើងស័ក ថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំថោះឯកស័ក។ មហាសករាជតាំងក្រោយគ្រិស្តសករាជ ៧៨ឆ្នាំ។

៥. ចុល្លសករាជ ៖ ចុល្លសករាជតាំងនៅប.ស.១២៧៣ ត្រូវនឹងព.ស.១១៨៣ គ.ស.៦៣៩ និងម.ស.៥៦១។ ក្នុងព្រះរាជពង្សាវតារខ្មែរ ចៅព្រះបាទសម្តេចព្រះអរិជ្ជពលពាហនោ (ព្រះកេតុមាលា) បានតាំងមហាសករាជ១ ក្នុងកាលពុទ្ធសករាជ៦២៣ ហើយព្រះបាទសម្តេចព្រះបុទុមសុរិយវង្ស បានតាំងចុល្លសករាជ១ ក្នុងកាលពុទ្ធសករាជ ១១៨

## តារាងប្រៀបធៀបកាលតាំងសករាជនីមួយៗ

| | ព.ស. | គ.ស. | ម.ស. | ច.ស. | ឆ្នាំបច្ចុប្បន្ន |
|---|---|---|---|---|---|
| បុរាណសករាជ | ៩១ | ៦៣៦ | ៧១៣ | ១២៧៣ | ២៦៤៩ |
| ពុទ្ធសករាជ | ១ | ៥៤៥ | ៦២៣ | ១១៨៣ | ២៥៥៨ |
| គ្រិស្តសករាជ | | ១ | ៧៨ | ៦៣៩ | ២០១៤ |
| មហាសករាជ | | | ១ | ៥៦១ | ១៩៣៦ |
| ចុល្លសករាជ | | | | ១ | ១៣៧៦ |

លោក យស់ អ៊ាង

# ក្រុង ស្រុក ខណ្ឌ-ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២(ត)

V-**បញ្ជីឈ្មោះឃុំតាមស្រុក**(ចុងឆ្នាំ២០១១)

| ល.រ | ខេត្ត ស្រុក ក្រុង ឃុំ | ល.រ | ខេត្ត ស្រុក ក្រុង ឃុំ | ល.រ | ខេត្ត ស្រុក ក្រុង ឃុំ |
|---|---|---|---|---|---|
| **០១** | **ខេត្តបន្ទាយមានជ័យ** | | ៧. ទានកាំ | | ១. បឹងបេង |
| ១ | ស្រុកមង្គលបូរី មាន១៣ឃុំ | | ៨. ទឹកជោរ | | ២. ម៉ាឡៃ |
| | ១. បន្ទាយនាង | | ៩. បុស្បូវ | | ៣. អូរសំព័រ |
| | ២. បត់ត្រង់ | ៤ | ស្រុកអូរជ្រៅ មាន៧ឃុំ | | ៤. អូរស្រឡៅ |
| | ៣. ចំណោម | | ១. ចង្ហា | | ៥. ទួលពង្រ |
| | ៤. គោកបល្ល័ង្គ | | ២. កូប | | ៦. តាគង់ |
| | ៥. គយម៉ែង | | ៣. គុត្តសត | ៩ | ក្រុងប៉ោយប៉ែត មាន ៣ សង្កាត់ |
| | ៦. អូរប្រាសាទ | | ៤. សំរោង | **០២** | **ខេត្តបាត់ដំបង** |
| | ៧. ភ្នំតូច | | ៥. សូភី | ១ | ស្រុកបាណន់ មាន ៨ ឃុំ |
| | ៨. រហាត់ទឹក | | ៦. សឹង្ហ | | ១. កន្ទឺ ១ |
| | ៩. ឫស្សីក្រោក | | ៧. អូរបីជាន់ | | ២. កន្ទឺ ២ |
| | ១០.សំបួរ | ៥ | ក្រុងសិរីសោភ័ណ មាន ៧សង្កាត់ | | ៣. បាយដំរាំ |
| | ១១. សឿ | ៦ | ស្រុកថ្មពួក មាន ៦ ឃុំ | | ៤. ឈើទាល |
| | ១២. ស្រះរាំង | | ១. បន្ទាយឆ្មារ | | ៥. ចែងមានជ័យ |
| | ១៣. តាឡំ | | ២. គោករមៀត | | ៦. ភ្នំសំពៅ |
| ២ | ស្រុកភ្នំស្រុក មាន៦ឃុំ | | ៣. ភូមិថ្មី | | ៧. ស្នឹង |
| | ១. ណាំតៅ | | ៤. ថ្មពួក | | ៨. តាក្រាម |
| | ២. ប៉ោយចារ | | ៥. គោកកបិន | ២ | ស្រុកថ្មគោល មាន ១០ឃុំ |
| | ៣. ពន្លៃ | | ៦. គំរូ | | ១. តាពូង |
| | ៤. ស្ពានស្រែង | ៧ | ស្រុកស្វាយចេក មាន ៨ឃុំ | | ២. តាម៉ឺន |
| | ៥. ស្រះជីក | | ១. ផ្គាំ | | ៣. អូរតាគី |
| | ៦. ភ្នំដី | | ២. សារង្គ | | ៤. ជ្រៃ |
| ៣ | ស្រុកព្រះនេត្រព្រះ មាន ៩ ឃុំ | | ៣. ស្លក្រាម | | ៥. អន្លង់រុន |
| | ១. ឈ្នួរមានជ័យ | | ៤. ស្វាយចេក | | ៦. ជ្រោយស្ដៅ |
| | ២. ជប់វារី | | ៥. តាបែន | | ៧. បឹងព្រីង |
| | ៣. ភ្នំលៀប | | ៦. តាផូ | | ៨. គោកឃ្មុំ |
| | ៤. ប្រាសាទ | | ៧. ទ្រាស | | ៩.បន្សាយត្រែង |
| | ៥. ព្រះនេត្រព្រះ | | ៨. រលួស | | ១០. រូងជ្រៃ |
| | ៦. រហាល | ៨ | ស្រុកម៉ាឡៃ មាន៦ឃុំ | ៣ | ក្រុងបាត់ដំបង មាន១០សង្កាត់ |

| ល.រ | ខេត្ត ស្រុក ក្រុង ឃុំ | ល.រ | ខេត្ត ស្រុក ក្រុង ឃុំ | ល.រ | ខេត្ត ស្រុក ក្រុង ឃុំ |
|---|---|---|---|---|---|
| ៤ | ស្រុកបវេល មាន ៨ឃុំ | | ២. នរា | | ៥. តាសែន |
| | ១. បវេល | | ៣. តាប៉ុន | | ៦. តាក្រី |
| | ២. ខ្នាចរមាស | | ៤. រកា | ១៣ | ស្រុកគាស់ក្រឡ មាន៦ឃុំ |
| | ៣. លា | | ៥. កំពង់ព្រះ | | ១. ធិបតី |
| | ៤. ព្រៃខ្ពស់ | | ៦. កំពង់ព្រៀង | | ២. គាស់ក្រឡ |
| | ៥. អំពិលប្រាំដើម | | ៧. រាំងកេសី | | ៣. ហប់ |
| | ៦. ក្តុលតាហែន | | ៨. អូរដំបង ១ | | ៤. ព្រះផុស |
| | ៧. ឃ្លាំងមាស | | ៩. អូរដំបង ២ | | ៥. ដូនបា |
| | ៨. បឹងប្រាំ | | ១០. វត្តតាមឹម | | ៦. ឆ្នាល់មាន់ |
| ៥ | ស្រុកឯកភ្នំ មាន ៧ឃុំ | ៩ | ស្រុកសំឡូត មាន ៧ឃុំ | ១៤ | ស្រុករុក្ខគិរី មាន ៥ ឃុំ |
| | ១. ព្រែកនរិន្ទ | | ១. តាគោក | | ១. ព្រែកជីក |
| | ២. សំរោងក្នុង | | ២. កំពង់ល្ពៅ | | ២. ព្រៃត្រឡាច |
| | ៣. ព្រែកខ្ពប | | ៣. អូរសំរិល | | ៣. បាសាក់ |
| | ៤. ព្រែកហ្លួង | | ៤. ស៊ុង | | ៤. មុខរាហ៍ |
| | ៥. ពាមឯក | | ៥. សំឡូត | | ៥. ស្តុកប្រវឹក |
| | ៦. ព្រៃចាស់ | | ៦. មានជ័យ | **០៣** | **ខេត្តកំពង់ចាម** |
| | ៧. កោះជីវាំង | | ៧. តាសាញ់ | ១ | ស្រុកបាធាយមាន ១២ឃុំ |
| ៦ | ស្រុកមោងឫស្សី មាន ៩ឃុំ | ១០ | ស្រុកសំពៅលូន មាន ៦ឃុំ | | ១. បាធាយ |
| | ១. មោង | | ១. សំពៅលូន | | ២. ច្បារអំពៅ |
| | ២. គារ | | ២. អង្គរបាន | | ៣. ជាលា |
| | ៣. ព្រៃស្វាយ | | ៣. តាស្ដា | | ៤. ជើងព្រៃ |
| | ៤. ឫស្សីក្រាំង | | ៤. សន្តិភាព | | ៥. មេព្រីង |
| | ៥. ជ្រៃ | | ៥. សេរីមានជ័យ | | ៦. ផ្អាវ |
| | ៦. តាលាស់ | | ៦. ជ្រៃសីមា | | ៧. សំបូរ |
| | ៧. កកោះ | ១១ | ស្រុកភ្នំព្រឹក មាន ៥ឃុំ | | ៨. សណ្ដែក |
| | ៨. ព្រៃតូច | | ១. ភ្នំព្រឹក | | ៩. តាំងក្រាំង |
| | ៩. របស់មង្គល | | ២. ពេជ្រចិន្ដា | | ១០. តាំងក្រសាំង |
| ៧ | ស្រុករតនមណ្ឌល មាន ៥ឃុំ | | ៣. ចក្រី | | ១១. ត្រប់ |
| | ១. ស្ដៅ | | ៤. បារាំងធ្លាក់ | | ១២. ទំនប់ |
| | ២. អណ្ដើកហែប | | ៥. អូររំដួល | ២ | ស្រុកចំការលើ មាន ៨ឃុំ |
| | ៣. ផ្លូវមាស | ១២ | ស្រុកកំរៀង មាន៦ឃុំ | | ១. បុសខ្នុរ |
| | ៤. ត្រែង | | ១. កំរៀង | | ២. ចំការអណ្ដូង |
| | ៥. រស្មីសង្ហា | | ២. បឹងរាំង | | ៣. ជយោ |
| ៨ | ស្រុកសង្កែ មាន ១០ឃុំ | | ៣.អូរដា | | ៤. ល្វាលើ |
| | ១. អន្លង់វិល | | ៤. ត្រាង | | ៥. ស្ពឺ |

| ល.រ | ខេត្ត ស្រុក ក្រុង ឃុំ | ល.រ | ខេត្ត ស្រុក ក្រុង ឃុំ | ល.រ | ខេត្ត ស្រុក ក្រុង ឃុំ |
|---|---|---|---|---|---|
| | ៦. ស្វាយទាប | | ១២. រំចេក | | ១១. ទ្រា |
| | ៧. តាអុង | | ១៣. ស្រក | | ១២. ទួលស្នួល |
| | ៨. តាប្រុក | | ១៤. ទ្រាន | ១០ | ស្រុកមេមត់ មាន១៤ឃុំ(ខេត្តត្បូងឃ្មុំ) |
| ៣ | ស្រុកជើងព្រៃ មាន ១០ឃុំ | | ១៥. វិហារធំ | | ១. ចាន់មូល |
| | ១. ខ្នុរដំបង | ៧ | ស្រុកកងមាស មាន១១ ឃុំ | | ២. ជាំ |
| | ២. គោករវៀង | | ១. អង្គរបាន | | ៣. ជាំក្រវៀន |
| | ៣. ផ្ដៅជុំ | | ២. កងតាណឹង | | ៤. ជាំតាម៉ៅ |
| | ៤. ព្រៃចារ | | ៣. ខ្ចៅ | | ៥. ដារ |
| | ៥. ព្រីងជ្រុំ | | ៤. ពាមជីកង | | ៦. កំពាន់ |
| | ៦. សំពងជ័យ | | ៥. ព្រែកកុយ | | ៧. មេមង |
| | ៧. ស្ដើងជ័យ | | ៦. ព្រែកក្របៅ | | ៨. មេមត់ |
| | ៨. សូទិប | | ៧. រាយប៉ាយ | | ៩. រូង |
| | ៩. ស្រម៉រ | | ៨. រកាអារ | | ១០. រំចេក |
| | ១០. ត្រពាំងគរ | | ៩. រកាគយ | | ១១. ត្រមូង |
| ៤ | ស្រុកតំបែរ មាន ៧ឃុំ(ខេត្តត្បូងឃ្មុំ) | | ១០. ស្ដៅ | | ១២. ទន្លូង |
| | ១. ចុងជាច | | ១១. សូរគង | | ១៣. ទ្រៀក |
| | ២. តំបែរ | ៨ | ស្រុកកោះសូទិន មាន៨ ឃុំ | | ១៤. គគីរ |
| | ៣. គោកស្រុក | | ១. កំពង់រាប | ១១ | ស្រុកអូររាំងឪមាន៧ឃុំ(ខេត្តត្បូងឃ្មុំ) |
| | ៤. នាងទើត | | ២. កោះសូទិន | | ១. អំពិលតាពក |
| | ៥. សេដា | | ៣. ល្វេ | | ២. ចក |
| | ៦. ទឹកជ្រៅ | | ៤. មហាលាភ | | ៣. ដំរិល |
| | ៧. ត្រពាំងព្រីង | | ៥. មហាខ្ញូង | | ៤. គងជ័យ |
| ៥ | ក្រុងកំពង់ចាម មាន៤ សង្កាត់ | | ៦. ពាមប្រធ្នោះ | | ៥. មៀន |
| ៦ | ស្រុកកំពង់សៀម មាន ១៥ ឃុំ | | ៧. ពង្រ | | ៦. ព្រះធាតុ |
| | ១. អំពិល | | ៨. ព្រែកតានង់ | | ៧. ទួលសូភី |
| | ២. ហាន់ជ័យ | ៩ | ស្រុកក្រូចឆ្មារមាន១២ឃុំ(ខេត្តត្បូងឃ្មុំ) | ១២ | ស្រុកពញាក្រែកមាន៨ឃុំ(ខេត្តត្បូងឃ្មុំ) |
| | ៣. កៀនជ្រៃ | | ១. ឈូក | | ១. ដូនតី |
| | ៤. គគរ | | ២. ជំនីក | | ២. កក់ |
| | ៥. កោះមិត្ត | | ៣. កំពង់ទ្រាស | | ៣. កណ្ដោលជ្រុំ |
| | ៦. កោះរកា | | ៤. កោះពីរ | | ៤. កោងកាង |
| | ៧. កោះសំរោង | | ៥. ក្រូចឆ្មារ | | ៥. ក្រែក |
| | ៨. កោះទន្ទឹម | | ៦. ប៉ឺស ១ | | ៦. ពពេល |
| | ៩. ក្រឡា | | ៧. ប៉ឺស ២ | | ៧. ត្រពាំងផ្លុង |
| | ១០. អូរស្វាយ | | ៨. ព្រែកអាជី | | ៨. វាលម្លូ |
| | ១១. រអាង | | ៩. រកាខ្នុរ | ១៣ | ស្រុកព្រៃឈរ មាន១៥ឃុំ |
| | | | ១០. ស្វាយឃ្លាំង | | |

១. បារាយណ៍
២. បឹងណាយ
៣. ជ្រៃវៀន
៤. ខ្វិតធំ
៥. គរ
៦. ក្រូច
៧. ល្វា
៨. មៀន
៩. ព្រៃឈរ
១០. ស្វាយសែន
១១. សំរោង
១២. ស្រង៉ែ
១៣. ថ្មពូន
១៤. តុងរ៉ុង
១៥. ត្រពាំងព្រះ

១៤ ស្រុកស្រីសន្ធរ មា១៤ឃុំ
១. បារាយណ៍
២. ជីបាល
៣. ខ្នារស
៤. កោះអណ្តែត
៥. មានជ័យ
៦. ផ្ទះកណ្តាល
៧. ប្រាំយ៉ាម
៨. ព្រែកដំបូក
៩. ព្រែកពោធិ
១០. ព្រែករំដេង
១១. ឫស្សីស្រុក
១២. ស្វាយពោធិ
១៣. ស្វាយខ្សាច់ភ្នំ
១៤. ទងត្រឡាច

១៥ ស្រុកស្ទឹងត្រង់ មាន ១២ឃុំ
១. អារក្សត្នោត
២. ដងក្តារ
៣. ខ្ពបតាងួន
៤. មេសរជ្រៃ
៥. អូរម្លូ
៦. ពាមកោះស្នា
៧. ព្រះអណ្តូង
៨. ព្រែកបាក់
៩. ព្រែកកក់
១០. សូភាស
១១. ទួលព្រះឃ្លាំង
១២. ទួលសំបួរ

១៦ ស្រុកត្បូងឃ្មុំ មាន១៤ឃុំ(ខេត្តត្បូងឃ្មុំ)
១. អញ្ចើម
២. បឹងព្រួល
៣. ជីគរ
៤. ជីរោទ៍ទី ១
៥. ជីរោទ៍ទី ២
៦. ជប់
៧. គរ
៨. ល្ងៀង
៩. មង់រៀវ
១០. ពាមជីលាំង
១១. រកាពប្រាំ
១២. ស្រឡប់
១៣. ថ្មពេជ្រ
១៤. ទន្លេបិទ

១៧ ក្រុងសួង មាន២សង្កាត់(ខេត្តត្បូងឃ្មុំ)

**០៤ ខេត្តកំពង់ឆ្នាំង**

១ ស្រុកបរិបូណ៌ មាន១១ ឃុំ
១. អញ្ចាញរូង
២. ឆ្នុកទ្រូ
៣. ចក
៤. ខុនរ៉ង
៥. កំពង់ព្រះគគីរ
៦. មេលំ
៧. ផ្សារ
៨. ពេជ្រចង្វារ
៩. ពពេល
១០. ពន្លៃ
១១. ត្រពាំងចាន់

២ ស្រុកជលគីរី មាន ៨ឃុំ
១. ជលសារ
២. កោះថ្កូវ
៣. កំពង់អុស
៤. ពាមឆ្កោក
៥. ព្រៃគ្រី

៣ ក្រុងកំពង់ឆ្នាំង មាន ៤សង្កាត់

៤ ស្រុកកំពង់លែង មាន ៩ ឃុំ
១. ច្រណូក
២. ដារ
៣. កំពង់ហៅ
៤. ផ្លូវទូក
៥. ពោធិ៍
៦. ប្រឡាយមាស
៧. សំរោងសែន
៨. ស្វាយរំពារ
៩. ត្រងិល

៥ ស្រុកកំពង់ត្រឡាច មាន ១០ឃុំ
១. អំពិលទឹក
២.ឈូកស
៣. ច្រេស
៤. កំពង់ត្រឡាច
៥. លង្វែក
៦. អូរឫស្សី
៧. ពានី
៨. សេប
៩. តាជេស
១០. ថ្មឥដ្ឋ

៦ ស្រុករលាប្អៀរ មាន ១៣ឃុំ
១. អណ្តូងស្នាយ
២. បន្ទាយព្រាល
៣. ជើងគ្រាវ
៤. ជ្រៃបាក់
៥. គោកបន្ទាយ
៦. ក្រាំងលាវ
៧. ពង្រ
៨. ប្រស្នឹម

| ល.រ | ខេត្ត ស្រុក ក្រុង ឃុំ | ល.រ | ខេត្ត ស្រុក ក្រុង ឃុំ | ល.រ | ខេត្ត ស្រុក ក្រុង ឃុំ |
|---|---|---|---|---|---|
| | ៩. ព្រៃមូល | | ៤. ពាម | | ២. ជៀប |
| | ១០. រលាំង្កៀរ | | ៥. សេដ្ឋី | | ៣. ចោងម៉ោង |
| | ១១. ស្រែថ្មី | | ៦. ស្វាយ | | ៤.ក្បាលទឹក |
| | ១២. ស្វាយជ្រុំ | | ៧. ស្វាយជុក | | ៥. ខ្លូងពពក |
| | ១៣. ទឹកហូត | | ៨. ត្បែងខ្ពស់ | | ៦. ក្រាំងស្គារ |
| ៧ | ស្រុកសាមគ្គីមានជ័យ មាន ៩ឃុំ | | ៩. ធ្លកវៀន | | ៧. តាំងក្រសាំង |
| | ១. ឈានឡើង | ៨ | ស្រុកទឹកផុស មាន៨ឃុំ | | ៨.ទួលខ្ពស់ |
| | ២. ខ្នាឆ្មារ | | ១. អភិវឌ្ឍន៍ | | |
| | ៣. ក្រាំងល្វា | | | | |

(នៅមានត) លោកស្រីគុយ ផល្លា

## ព្រះពុទ្ធសករាជ(ព.ស.)

*ជាអ្នកកាន់ព្រះពុទ្ធសាសនា ត្រូវដឹងអំពីការរាប់ព្រះពុទ្ធសករាជ (ព.ស.) ។ ពុទ្ធសករាជចាស់ ២៥៥៧ នឹងត្រូវបានគេរាប់ជា ព.ស.ថ្មី ២៥៥៨ ចាប់ពីថ្ងៃ ១រោច ខែវិសាខតទៅ ។ ការរាប់ព.ស.នេះគឺរាប់ក្រោយព្រះអង្គយាងចូលបរិនិព្វានរបស់ព្រះជាម្ចាស់មួយថ្ងៃ គឺ ព្រះអង្គយាងចូលបរិនិព្វាននៅថ្ងៃ១៥កើត ខែវិសាខ ។ ឯព.ស.ទី១ គឺរាប់ចាប់ពីថ្ងៃ១រោចខែវិសាខតទៅ ។*

*ជាទូទៅយើងច្រើនយល់ច្រឡំថា ព្រះពុទ្ធសករាជថ្មីប្តូរនៅឱកាសពេលចូលឆ្នាំថ្មី ។*

**សមាគមបុគ្គលិកសិក្សាខ្មែរ** **ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការកណ្តាល** **សេចក្តីជូនដំណឹងមរណភាពប្រចាំខែ ឧសភា ឆ្នាំ២០១៣**

**លេខ : ០៤/១៣ គ.ក** តាងនាមសមាគមបុគ្គលិកសិក្សាទាំងមូលគណៈកម្មាធិការកណ្តាលនៃ ស.ប.ស.ខ.

សូមសំដែងសេចក្តីសោកស្តាយជាទីបំផុត ចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ

ហើយសូមចូលរួមកាន់ទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម_នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបំរើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| **ក.មរណៈភាពសមាជិក** | | | | | | | | | **សពធី** |
| ១ | ម៉ែន យន | ៦៨ | ប | គ្រូ. | និវត្តជន ស្រុកអង្គរបូរី ខេត្តតាកែវ | ២៣.០៣.១៣ | រោគាពាធ | ៣៨៨០ ត.ក | ៨៨៥៨ |
| ២ | នួច រៀម | ៦៦ | ប | គ្រូ. | និវត្តជន ស្រុកត្រាំកក់ ខេត្តតាកែវ | ០៧.០៣.១៣ | រោគាពាធ | ៥៥៨៣ ត.ក | ៨៨៥៩ |
| ៣ | អ៊ុក សាអឿន | ៧៣ | ប | គ្រូ. | និវត្តជន ស្រុកព្រៃកប្បាស ខេត្តតាកែវ | ២៥.០៣.១៣ | រោគាពាធ | ៥០៦២ ត.ក | ៨៨៦០ |
| ៤ | នួ រឿន | ៧៣ | ប | គ្រូ. | និវត្តជន ស្រុកនិវត្តជន ស្រុកបាទី ខេត្តតាកែវ | ០៣.០៤.១៣ | រោគាពាធ | ១៤៦១ ត.ក | ៨៨៦១ |
| ៥ | សុខ ស៊ីថា | ៥៩ | ស | ម.ប.ភ | អនុវិទ្យាល័យអង្គមេត្រី ក្រុងដូនកែវ ខេត្តតាកែវ | ២៤.០៤.១៣ | រោគាពាធ | ៣២០២ ត.ក | ៨៨៦២ |
| ៦ | ឈុំ ប៉ឿត | ៤១ | ប | មូលដ្ឋាន | ការិ.អយក. ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ | ២៥.០៦.១១ | រោគាពាធ | ១៨២ ឧ.ជ | ៨៨៦៣ |
| ៧ | ប៉ាន់ លើម | ៤៥ | ប | បឋម | បឋមឈើស្លាប់ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ | ៣០.០៩.១១ | រោគាពាធ | ១៩៩ ឧ.ជ | ៨៨៦៤ |
| ៨ | ឈាវ សារុធ | ៥៦ | ប | បឋម | ការិ.អយក ក្រុងសំរោង ខេត្តឧត្តរមានជ័យ | ០៦.០១.១២ | រោគាពាធ | ១៧៣ ឧ.ជ | ៨៨៦៥ |
| ៩ | ស្វាយ វឌ្ឍនី | ៤៤ | ប | បឋម | បឋមសិក្សា អំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ | ២៥.០៣.១២ | រោគាពាធ | ៣០៦ ឧ.ជ | ៨៨៦៦ |
| ១០ | យន រឿន | ៤២ | ប | បឋម | បឋមសិក្សា អូរឫស្សី ក្រុងសំរោង ខេត្តឧត្តរមានជ័យ | ២៤.០១.១៣ | រោគាពាធ | ៥៦ ឧ.ជ | ៨៨៦៧ |
| ១១ | សេក ធនរ៉ាត់ | ៤៥ | ស | បឋម | បឋមក្តុល ស្រុកដូនទាវ ខេត្តបាត់ដំបង | ២៤.០២.១៣ | រោគាពាធ | ៤៣៩ ប.ប | ៨៨៦៨ |
| ១២ | ម៉ក់ ចាន់ថា | ៤៦ | ប | បឋម | បឋមឯកភ្នំ ស្រុកឯកភ្នំ ខេត្តបាត់ដំបង | ២៤.០៣.១៣ | រោគាពាធ | ៤៧៨៩ ប.ប | ៨៨៦៩ |
| ១៣ | ថោង ប៊ុនសុង | ៣៤ | ប | បឋម | បឋម ពាក់ស្បែក ស្រុកបាណន់ ខេត្តបាត់ដំបង | ១៥.០៤.១៣ | គ្រោះថ្នាក់ចរាចរ | ១១០៨៤ ប.ប | ៨៨៧០ |
| ១៤ | ហួន សុខ | ២៣ | ប | ម.ប.ភ | មន្ទីរអប់រំយុវជន និងកីឡា ខេត្តបាត់ដំបង | ១២.០៤.១៣ | គាំងបេះដូង | ១១១៤៨ ប.ប | ៨៨៧១ |
| ១៥ | អ៊ិន វ៉ាន់ធួន | ៦៣ | ប | បឋម | និវត្តជន ការិ.ផែនការនៃមន្ទីរអយក ខេត្តព្រៃវែង | ០៤.០៣.១៣ | រោគាពាធ | ៨៤ ព.វ | ៨៨៧២ |
| ១៦ | រស់ ហន | ៦០ | ប | បឋម | និវត្តជន បឋម បាក់ដោក ស្រុកពោធិ៍រៀង ខេត្តព្រៃវែង | ២៦.០៣.១៣ | រោគាពាធ | ២០២២ ព.វ | ៨៨៧៣ |
| ១៧ | គន់ ចាន់ធឿន | ៥៥ | ស | បឋម | បឋម ព្រុំ សុន ក្តីកណ្តាល ក្រុងព្រៃវែង ខេត្តព្រៃវែង | ១៥.០៣.១៣ | រោគាពាធ | ២៣២១ ព.វ | ៨៨៧៤ |
| ១៨ | អ៊ុង សារ៉ាត់ | ៤៦ | ស | បឋម | បឋម គ្រោក ស្រុកបាភ្នំ ខេត្តព្រៃវែង | ០៩.០២.១៣ | ជំងឺបេះដូង | ៤២៨៦ ព.វ | ៨៨៧៥ |
| ១៩ | ផុន ថាវី | ៥៣ | ប | បឋម | បឋម ចាក់ខ្លាញ់ ស្រុកពាមរក៍ ខេត្តព្រៃវែង | ០៩.០២.១៣ | ខ្យល់គរ | ៤៩៤៨ ព.វ | ៨៨៧៦ |
| ២០ | តោ មួយលាង | ៦៤ | ស | បឋម | និវត្តជន បឋមត្រាល ស្រុកពារាំង ខេត្តព្រៃវែង | ៣ ០.០៣.១៣ | រោគាពាធ | ៥៩៧១ ព.វ | ៨៨៧៧ |
| ២១ | ចិន សារឿន | ៤០ | ប | បឋម | បឋមតាម៉ៅ ស្រុកបាភ្នំ ខេត្តព្រៃវែង | ២៥.០៣.១៣ | គ្រោះថ្នាក់ចរាចរ | ៧៣៦០ ព.វ | ៨៨៧៨ |
| ២២ | លក ឃិន | ៨២ | ប | បឋម | និវត្តជន មន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពង់ធំ | ២៦.០១.១៣ | រោគាពាធ | ១៤៣៤ ក.ធ | ៨៨៧៩ |
| ២៣ | ជឹម ស៊ី | ៦៩ | ប | បឋម | និវត្តជន ការិយាល័យ មន្ទីរអប់រំយុវជន និងកីឡាសស្ទោង ខេត្តកំពង់ធំ | ១៥.០២.១៣ | រោគាពាធ | ២០៣៥ ក.ធ | ៨៨៨០ |
| ២៤ | សាត់ ឡូត | ២៩ | ប | បឋម | សាលាបឋមសិក្សា ចុងព្រៃ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ | ១៨.០២.១៣ | រោគាពាធ | ៥៦៧២ ក.ធ | ៨៨៨១ |
| ២៥ | នួ វណ្ណនី | ៥៥ | ប | បឋម | ការិ.អយក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ | ២១.០១.១៣ | រោគាពាធ | ០២៤៩ ក.ស្ព | ៨៨៨២ |
| ២៦ | ភុំ សុករ៉ា | ៦១ | ស | បឋម | និវត្តជន ស្រុកច្បារមន ខេត្តកំពង់ស្ពឺ | ០៨.០៣.១៣ | រោគាពាធ | ១០៥១ ក.ស្ព | ៨៨៨៣ |
| ២៧ | សក សម្បត្តិ | ៣៥ | ប | មូលដ្ឋាន | អនុ.គិរីវ័ន្ត ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ | ១៧.០១.១៣ | រោគាពាធ | ៤៤៨៥ ក.ស្ព | ៨៨៨៤ |
| ២៨ | ញ៉ែម សុភាព | ៥៥ | ប | បឋម | សាលាគរុកោសល្យ ខេត្តកំពង់ស្ពឺ | ១៩.០១.១៣ | រោគាពាធ | ០០៧១ ក.ស្ព | ៨៨៨៥ |
| ២៩ | សៅ សុន | ៦៨ | ប | បឋម | និវត្តជន ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | ០៤.០៣.១៣ | រោគាពាធ | ២៥៦៨ ក.ស្ព | ៨៨៨៦ |
| ៣០ | ប៉ាង ផេន | ៤២ | ប | មូលដ្ឋាន | អនុ.អង្គមេត្រី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | ២៣.០២.១៣ | រោគាពាធ | ២១៣១ ក.ស្ព | ៨៨៨៧ |
| ៣១ | ហ៊ឹម សារឿន | ៤០ | ប | បម | បឋមទួលសុភី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | ០៧.៣.១៣ | រោគាពាធ | ២១៧៤ក.ស្ព | ៨៨៨៨ |
| ៣២ | ផាត់ សីលា | ២៦ | ស | បឋម | បឋមសន្សំកុសល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | ២៧.០១.១៣ | គ្រោះថ្នាក់ចរាចរ | ៦២៨១ក.ស្ព | ៨៨៨៩ |
| ៣៣ | រ៉េត ថានីន | ៥៨ | ប | បឋម | បឋមជីបេះ ស្រុកមេមត់ ខេត្តកំពង់ចាម | ២២.០១.១៣ | រោគាពាធ | ៦២៤ ក.ច | ៨៨៩០ |
| ៣៤ | កុច ផុន | ៤០ | ប | មូលដ្ឋាន | វិ.បន. ហ.ស.មេមត់ ស្រុកមេមត់ ខេត្តកំពង់ចាម | ២៣.០១.១៣ | រោគាពាធ | ៥២៣ ក.ច | ៨៨៩១ |
| ៣៥ | យក់ ហ៊ាន់ | ៦៩ | ប | មធ្យម | និវត្តជន បឋម ប្រជាកុមារ ក្រុងសួង ខេត្តកំពង់ចាម | ២០.១២.១២ | រោគាពាធ | ៨៧១៦ ក.ច | ៨៨៩២ |
| ៣៦ | សីវ ទិត្យ | ៦៣ | ប | គ្រូ. | និវត្តជន វិ.ដងទង់ ស្រុកដងទង់ ខេត្តកំពត | ២៩.០៣.១៣ | រោគាពាធ | ២៥៦៨ ក.ព | ៨៨៩៣ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣៧ | ពេជ សុធី | ៧៥ | ប | គ្រូ. | និវត្តជន បឋមកំពតក្រុង ខេត្តកំពត | ០៥.០៤.១៣ | រោគាពាធ | ០៨៧ ក.ព | ៨៨៩៤ |
| ៣៨ | សួរ សុគីម | ២១ | ប | បឋម | បឋមជីផាត ការិ.អយក ស្រុកថ្មបាំង ខេត្តកោះកុង | ១៧.០៣.១៣ | ខ្យល់គរ | ៦៨៩ ក.ក | ៨៨៩៥ |
| ៣៩ | រស់ គាំ | ៧០ | ប | បឋម | និវត្តជន ស្រុកស្វាយទាប ខេត្តស្វាយរៀង | ២១.០២.១៣ | ជំងឺហត់ | ៣១៨០ ស្វ.រ | ៨៨៩៦ |
| ៤០ | យិន ពៅ | ៦៩ | ប | បឋម | និវត្តជន ស្រុករមាសហែក ខេត្តស្វាយរៀង | ២៤.០២.១៣ | ជំងឺឈឺរីងរៃ | ៥០១០ ស្វ.រ | ៨៨៩៧ |
| ៤១ | សឹង យេ | ៦៤ | ប | បឋម | និវត្តជន ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង | ០៨.០៣.១៣ | មហារីកថ្លើម | ៤៣៨ ស្វ.រ | ៨៨៩៨ |
| ៤២ | ប៉ែន ឈុំ | ៨០ | ប | បឋម | និវត្តជន ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង | ១១.០៣.១៣ | ជរាពាធ | ៣៦៣៦ ស្វ.រ | ៨៨៩៩ |
| ៤៣ | ស៊ីវ សមសាក់ | ៦៩ | ប | បឋម | និវត្តជន បឋមសំរោង ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ | ០៤.០៣.១៣ | រោគាពាធ | ១៨៥២ ប.ជ | ៨៩០០ |
| ៤៤ | សិក ចាម | ៣៩ | ប | បឋម | បឋមតាវង់ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ | ២០.០៣.១៣ | រោគាពាធ | ១៧៣២ ប.ជ | ៨៩០១ |
| ៤៥ | ណេន ស៊ក់ | ៤៨ | ប | បឋម | បឋម ស្វាយខ្មៅ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ | ៣១.០៣.១៣ | គ្រោះថ្នាក់ចរាចរ | ៣០៦០ ប.ជ | ៨៩០២ |
| ៤៦ | នាវ ចន្ថា | ៤៨ | ប | បឋម | បឋម បន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តសៀមរាប | ០១.០៤.១៣ | រោគាពាធ | ៣៣២៦ ប.ជ | ៨៩០៣ |
| ៤៧ | គីម ចន្ថា | ៤២ | ស | ម.ប.ភ | វិទ្យាល័យ ទួលស្វាយព្រៃ រាជធានីភ្នំពេញ | ២០.០៣.១៣ | មហារីកខួរក្បាល | ៥៧២៧ ភ.ព | ៨៩០៤ |
| ៤៨ | ឈុន អ៊ឹម | ៥៦ | ស | បឋម | បឋមសិក្សាព្រះពន្លា រាជធានីភ្នំពេញ | ២៦.០៣.១៣ | ជំងឺថ្លើម | ១១៧២ ភ.ព | ៨៩០៥ |
| ៤៩ | សុខ ធាន | ៦១ | ប | បឋម | បឋមអូរក្រសារ ក្រុងកែប ខេត្តកែប | ២៣.០៣.១៣ | លើសឈាម | ១០៦ ខ.ក | ៨៩០៦ |
| ៥០ | សែម សុផល | ៣៨ | ប | បឋម | ការិ.បឋម មអយក ខេត្តកណ្តាល | ១០.០៣.១៣ | ខ្យល់គរ | ២០៥៣ ក.ណ | ៨៩០៧ |
| ៥១ | សុខ ឃុន | ៥៧ | ប | បឋម | បឋមវត្តថ្មី ស្រុកមុខកំពូល ខេត្តកណ្តាល | ១១.០៣.១៣ | រោគាពាធ | ១១១៩ ក.ណ | ៨៩០៨ |
| ៥២ | អៀម សាអ៊ឹម | ៦៨ | ស | គ្រូ. | និវត្តជន បឋមស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល | ១៤.០៣.១៣ | រោគាពាធ | ៣១៨៩ ក.ណ | ៨៩០៩ |
| ៥៣ | មាស សោភ័ណរិទ្ធ | ៥៨ | ស | ម.ប.ភ | អនុវិទ្យាល័យ អនុវត្ត ក្រុងតាខ្មៅ ខេត្តកណ្តាល | ១៥.០៣.១៣ | រោគាពាធ | ៣៨៨៨ ក.ណ | ៨៩១០ |
| ៥៤ | ចាន់ សុខន | ៧៥ | ស | គ្រូ. | និវត្តជន បឋម ទួលស្វាយព្រៃ ការគ្រប់គ្រងគណៈកម្មាធិការកណ្តាល | ១៦.០៣.១៣ | រោគាពាធ | ២០៩៨៥ គ.ក | ៨៩១១ |
| ៥៥ | ប្រាក់ ផានី | ៧៦ | ស | គ្រូ. | នា.សារមន្ទីរជាតិ ក្រសួងវប្បធម៌ ការគ្រប់គ្រងគណៈកម្មាធិការកណ្តាល | ០៤.០៤.១៣ | រោគាពាធ | ៤៥០១ គ.ក | ៨៩១២ |
| **ល.រ** | **គោត្តនាម_នាម** | **អាយុ** | **ភេទ** | **មុខរបរ** | **អង្គភាពបំរើការ** | **ថ្ងៃខែឆ្នាំមរណៈ** | **មូលហេតុ** | **លេខប័ណ្ណ** | **ផ្សេងៗ** |
| **ខ.មរណភាពគូស្រករ** | | | | | | | | | **សពទី** |
| ១ | កុល ប៉ូលីណា | ៣៩ | ស | កសិករ | ភរិយាលោក ណេន វ៉ង់ វិទ្យា.ស.អ ព្រៃសណ្តែក ស្រុកទ្រាំង ខេត្តតាកែវ | ០៦.០២.១៣ | គាំងបេះដូង | ៣៦១ ត.ក | ៥២៥៥ |
| ២ | សតាំង ញ៉ាន | ៥៨ | ស | មេផ្ទះ | ប្រពន្ធលោក សី សំអែល បឋមពងទឹក ក្រុង សំរោង ខេត្តឧត្តរមានជ័យ | ០២.០៨.១១ | រោគាពាធ | ៨១ ឧ.ត | ៥២៥៦ |
| ៣ | សរិត ពុទ្ធី | ៥០ | ស | មេផ្ទះ | ប្រពន្ធលោក ម៉ុន ហៃ មន្ទីរការងារ ខេត្តឧត្តរមានជ័យ | ០២.១០.១១ | រោគាពាធ | ១៦ ឧ.ត | ៥២៥៧ |
| ៤ | ឡុង លើម | ៥៥ | ស | មេផ្ទះ | ប្រពន្ធលោក មាស វណ្ណី និវត្តជន ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ | ១៧.០២.១២ | រោគាពាធ | ១៥៩ ឧ.ត | ៥២៥៨ |
| ៥ | ប៊្លុង អ៊ូច | ៥៦ | ស | មេផ្ទះ | ប្រពន្ធលោក តូច សុន និវត្តជន ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ | ១៨.០២.១២ | រោគាពាធ | ១៥១ ឧ.ត | ៥២៥៩ |
| ៦ | ទៀន ធា | ៥៣ | ស | មេផ្ទះ | ភរិយាលោក អ៊ុន ឈៀង និវត្តជន បាណន់ ខេត្តបាត់ដំបង | ១១.០២.១៣ | រោគាពាធ | ៣៣៧០ ប.ប | ៥២៦០ |
| ៧ | សៀន ប៊ុនណា | ៥៤ | ប | កសិករ | ប្តីអ្នកគ្រូ យី គឹមហ៊ន បឋម អាត់ស៊ូ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ | ០១.០២.១៣ | រោគាពាធ | ១៨២២ ក.ធ | ៥២៦១ |
| ៨ | ហួន ជុនលី | ៦៣ | ប | កសិករ | ប្តីអ្នកគ្រូ យ៉យ សុផល បឋម ព្រះនាង ស្រុកស្ទោង ខេត្តកំពង់ធំ | ១៦.០២.១៣ | រោគាពាធ | ១៩៨៩ ក.ធ | ៥២៦២ |
| ៩ | ទោម សួរ | ៦៥ | ស | កសិករ | ប្រពន្ធលោកគ្រូ ម៉ី រឿន និវត្តជន បឋមសំបូរ ស្រុកស្ទោង ខេត្តកំពង់ធំ | ០១.០២.១៣ | រោគាពាធ | ២២៥២ ក.ធ | ៥២៦៣ |
| ១០ | អ៊ុង សារ៉ាត់ | ៤៦ | ស | បឋម | ប្រពន្ធលោក ប៊ិច ពៅ អនុ. ស្ពឺ ស្រុកបាភ្នំ ខេត្តព្រៃវែង | ០៩.០២.១៣ | ជំងឺបេះដូង | ៧១២៨ ព.វ | ៥២៦៤ |
| ១១ | ចិន សារឿន | ៤០ | ប | បឋម | ប្តីលោកស្រី ពត ឡាត់ បឋមបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង | ២៥.០៣.១៣ | គ្រោះថ្នាក់ចរាចរ | ៤៦៤៤ ព.វ | ៥២៦៥ |
| ១២ | ឡឿក ស៊ីណាត | ៦០ | ស | កសិករ | ប្រពន្ធលោក ថាន់ ថៃ និវត្តជន អនុ. ស្ពឺ ស្រុកបាភ្នំ ខេត្តព្រៃវែង | ១៩.០២.១៣ | រោគាពាធ | ៤២០១ ព.វ | ៥២៦៦ |
| ១៣ | អ៊ីត សារឹម | ៥៥ | ស | កសិករ | ភរិយាលោក សុន សារិន បឋមអំពែភ្នំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ | ២៨.១២.១២ | រោគាពាធ | ៣៧៥៧ ក.ស្ព | ៥២៦៧ |
| ១៤ | ហេង សេម | ៧៣ | ស | កសិករ | ភរិយាលោក ស៊ុម សារ៉ាន និវត្តជន ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | ០៦.០២.១៣ | រោគាពាធ | ២២៩៧ ក.ស្ព | ៥២៦៨ |
| ១៥ | ស្វាយ ស៊ីណាត | ៦៩ | ស | កសិករ | ភរិយាលោក ម៉ៅ ស៊ុង និវត្តជន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ | ០៨.០១.១៣ | រោគាពាធ | ០៧៦៤ ក.ស្ព | ៥២៦៩ |
| ១៦ | ញ៉ែម សុភាព | ៥៥ | ប | គ្រូ. | ប្តីអ្នកគ្រូ ទិល វណ្ណា សាលាគរុសកោសល្យ ខេត្តកំពង់ស្ពឺ | ១៩.០១.១៣ | រោគាពាធ | ០០៦៩ ក.ស្ព | ៥២៧០ |
| ១៧ | មាស សុផៃ | ៤៤ | ប | កសិករ | ប្តីអ្នកស្រី កុច ពុទ្ធារី វិ.បន ហ.ស មេមត់ ស្រុកមេមត់ ខេត្តកំពង់ចាម | ២៩.០១.១៣ | រោគាពាធ | ៥២១ ក.ច | ៥២៧១ |
| ១៨ | ចេង សុខា | ៥៧ | ស | កសិករ | ប្រពន្ធលោក អ៊ុច មួយសែ បឋមប្រសែក្រោម ក្រុងសួង ខេត្តកំពង់ចាម | ២៨.០២.១៣ | រោគាពាធ | ៩៤៥៤ ក.ច | ៥២៧២ |
| ១៩ | គ្រួច ស៊ាត | ៧០ | ស | ធ្វើស្រែ | ប្រពន្ធលោក នង ស៊ាន បឋមស្ទឹង ស្រុកពញាក្រែក ខេត្តកំពង់ចាម | ២១.០២.១៣ | ជរាពាធ | ៦៩៧១ ក.ច | ៥២៧៣ |
| ២០ | ស៊្វ ចាន់ធា | ៤៥ | ប | កសិករ | ប្តីអ្នកស្រី លី ចាន់ធីតា បឋមអង្គរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម | ២២.០២.១៣ | ឡើងឈាម | ១៦៨ ក.ច | ៥២៧៤ |
| ២១ | ស្វាយ សុខា | ៥៣ | ស | កសិករ | ប្រពន្ធលោកលួង ប៊ុនថេង បឋមភ្នំប្រុស ស្រុកកំពង់សៀម ខេត្តកំពង់ចាម | ២៨.០២.១៣ | រោគាពាធ | ៤៥៨៨ ក.ច | ៥២៧៥ |
| ២២ | លឹម ទ្រី | ៥៣ | ប | កសិករ | ប្តីអ្នកស្រី អ៊ឹង ស៊ីវួច វិ.ព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម | ០៤.០៣.១៣ | ជំងឺថ្លើម | ៧១៩០ ក.ច | ៥២៧៦ |
| ២៣ | ទេព យឹម | ៧១ | ស | មេផ្ទះ | ប្រពន្ធលោកគ្រូ ម៉ែន សំផុន និវត្តជន បឋមកោះស្លា ស្រុកឈូក ខេត្តកំពត | ១៨.០៣.១៣ | រោគាពាធ | ២១៩៦ ភ.ព | ៥២៧៧ |
| ២៤ | ស៊ី ម៉ុម | ៦០ | ស | មេផ្ទះ | ប្រពន្ធលោកគ្រូ ឈឹម មាន និវត្តជន បឋម អង្គគយ ស្រុកឈូក ខេត្តកំពត | ១២.០៣.១៣ | រោគាពាធ | ៣៦៦២ ភ.ព | ៥២៧៨ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២៥ | ឯម ប៊ុនធឿន | ៥៨ | ប | ឯកជន | ប្ដីអ្នកគ្រូ ឱម សុផានី បឋមសិក្សា វត្តកោះ រាជធានីភ្នំពេញ | ២២.០២.១៣ | លើសឈាម | ៣០៨៩ ភ.ព | ៥២៧៩ |
| ២៦ | អៀ ម៉េងហ៊ាង | ៥៤ | ប | កសិករ | ប្ដីអ្នកគ្រូ ប៊ូ ផល្លា បឋមសិក្សា ដង្កោ រាជធានីភ្នំពេញ | ០៩.០៣.១៣ | ជំងឺក្រពះ | ៨០៣២ ភ.ព | ៥២៨០ |
| ២៧ | ចាន់ ហាន | ៦២ | ស | លក់ដូរ | ប្រពន្ធលោកគ្រូ កុយ ឃឹម បឋមសិក្សា ច្បារអំពៅ រាជធានីភ្នំពេញ | ២០.០៣.១៣ | គាំងបេះដូង | ៧៨៣ ភ.ព | ៥២៨១ |
| ២៨ | ប៉ាល់ ប៊ុយប៊ុណ្ណាង | ៦១ | ប | កសិករ | ប្ដីអ្នកគ្រូ ឡាយ ណាឌី និវត្តជន ខណ្ឌទួកគោក រាជធានីភ្នំពេញ | ០៧.០៣.១៣ | រោគាពាធ | ១៤៥៣ ភ.ព | ៥២៨២ |
| ២៩ | ហ៊ាន ណារឿន | ៦១ | ស | មេផ្ទះ | ប្រពន្ធលោកគ្រូ ម៉ឹង ថា អនុវិទ្យាល័យ បែកចាន ស្រុក អង្គស្នួល ខេត្តកណ្ដាល | ០៤.០៣.១៣ | លើសឈាម | ៨៤៦០ ក.ណ | ៥២៨៣ |
| ៣០ | ប្រាក់ ផានី | ៧៦ | ស | គ្រូ | ប្រពន្ធលោក គឹម នៅ ការគ្រប់គ្រងគណៈកម្មាធិការកណ្ដាល | ០៤.០៣.១៣ | រោគាពាធ | ៤៤៩៩ ក.ណ | ៥២៨៤ |

មេត្តាប្រមូលភាគទានឧបត្ថម្ភប្រចាំ ខែ ឧសភាឆ្នាំ ២០១៣ ឱ្យទាន់ពេលវេលា ដើម្បីដោះស្រាយជូនគ្រួសារសព។

**ចំណាំ**: ត្រូវបង់ប្រាក់ឧបត្ថម្ភសពសមាជិក: ៥៥ ន × ៤០៖: ២២០០៖

សពគូស្រករ : ៣០ ន × ២០៖: ៦០០ ៖

ភាគទានប្រចាំខែ :២០០៖

ភាគទានសាងសង់ផ្ទះគ្រូបង្រៀន : ៣០០៖

**សរុប : ៣.៣០០៖**

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែ ឧសភាឆ្នាំ ២០១៣

**ជ.គណៈកម្មាធិការកណ្ដាល**

**អគ្គលេខាធិការរង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សមាគមបុគ្គលិកសិក្សាខ្មែរ**

**គណៈកម្មាធិការកណ្ដាល**

**លេខ : ១៣/១៣ គ.ក**

**សេចក្ដីជូនដំណឹងមរណភាពប្រចាំខែ មិថុនា ឆ្នាំ២០១៣**

តាងនាមសមាគមបុគ្គលិកសិក្សាទាំងមូលគណៈកម្មាធិការកណ្ដាលនៃ ស.ប.ស.ខ.
សូមសំដែងសេចក្ដីសោកស្ដាយជាទីបំផុត ចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ
ហើយសូមចូលរួមកាន់ទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម_នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបំរើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| **ក.មរណៈភាពសមាជិក** | | | | | | | | | **សពទី** |
